សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

សារណាបញ្ចប់ការសិក្សា

ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ

ឆ្នាំ ២០២០

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ជាវ ម្ករិច**

ញ៉ឹក ឈីសម្បត្តិ

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉ែត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំចូលរៀន ២០១៧

ជំនាន់ទី ១៤ ឆ្នាំសរសេរសារណា ២០២១

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

សារណាបញ្ចប់ការសិក្សា

ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ ឆ្នាំ ២០២០

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ជាវ ហ្គិច**

ញ៉ឹក ឈីសម្បត្តិ

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉ែត**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំចូលរៀន ២០១៧

ជំនាន់ទី ១៤ ឆ្នាំសរសេរសារណា ២០២១

សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំ **ជាវ ហ៊ិច** និង **ញឹក ឈីសម្បត្តិ** សូមលំឱនកាយក្រាបថ្វាយបង្គំដោយកិច្ចប្រណិប័តន៍ សម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ៖

លោកឪពុក ញឹក ឈាងឡុង និង អ្នកម្តាយ ចែ ណារិន

លោកឪពុក ឡេង ហាវ និង អ្នកម្តាយ លី សុខគាង

ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ ថែរក្សា អប់រំទូន្មានប្រៀនប្រដៅកូនបានសិក្សារៀនសូត្រហូតទទួលបាននូវជោគជ័យដូចបច្ចុប្បន្ននេះ នេះជាគុណូបការៈជាអនេកប្បការ និងវិសេសវិសាលខ្ពង់ខ្ពស់ថ្លៃថ្លាមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរ។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំក៏សូមធ្វើការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យរួមទាំងលោកគ្រូអ្នកគ្រូដែលបម្រើការនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រួមទាំងថ្នាក់ដឹកនាំនៃរដ្ឋបាលរាជធានីភ្នំពេញដែលបានអនុញ្ញាត និងផ្តល់ឱកាសជាច្រើនដល់ក្រុមយើងខ្ញុំបានចុះកម្មសិក្សាដើម្បីទទួលបាននូវចំណេះដឹង និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែង។ សូមថ្លែងអំណរគុណដោយឡែកជូនចំពោះលោក **សេង វណ្ណៈ** នាយករដ្ឋបាលនៃសាលារាជធានីភ្នំពេញ រួមទាំង មន្ត្រីរាជការគ្រប់កម្រិតទាំងអស់ក្នុងទីចាត់ការដែលបានអប់រំណែនាំ តម្រង់ទិស ផ្តល់ឯកសារពាក់ព័ន្ធ និងចែករំលែកបទពិសោធន៍ជាច្រើនដល់យើងខ្ញុំក្នុងអំឡុងពេលការចុះស្រាវជ្រាវ ទោះបីជាស្ថិតក្នុងស្ថានភាពដ៏លំបាកក្តីក្នុងពេលកូវីត-១៩ នេះយ៉ាងណាក៏ដោយ។

ជាពិសេស សូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉ែត** លោកបណ្ឌិត បានបញ្ចប់ការសិក្សាដោយជោគជ័យនៅសាកលវិទ្យាល័យ M.V Lomonosov Moscow Stute នៅប្រទេសរុស្ស៊ី ក្នុងការចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ការណែនាំ តម្រង់ទិស សម្របសម្រួល និងផ្តល់ដំបូន្មានល្អៗដល់ក្រុមយើងខ្ញុំដែលជាមូលដ្ឋានគំនិតដ៏សំខាន់ក្នុងការសរសេរប្រធានបទមួយនេះឱ្យលេចចេញជារូបរាង។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនស្នាដៃ និងគុណតម្លៃទាំងឡាយ ដែលបានទទួលពីការសិក្សាស្រាវជ្រាវមួយនេះ ជូនចំពោះអស់លោកអ្នកដែលមានគុណ ដូចដែលយើងខ្ញុំបានរៀបរាប់ខាងលើ។ យើងខ្ញុំសូមប្តេជ្ញាចិត្តថានឹងយកនូវ ចំណេះដឹង បញ្ញា ស្មារតី កម្លាំងកាយ ចិត្ត ដែលមានទៅជួយសង្គមកម្ពុជាមួយនេះឱ្យសមនឹងការតបស្នងជួយជ្រោមជ្រែងដ៏មានតម្លៃរបស់អ្នកទាំងអស់គ្នា។ ជាមួយនឹងគ្នានេះដែរក៏សូមប្រសិទ្ធពរជ័យជូនដល់អស់លោក លោកស្រី ឱ្យទទួលនូវសុខសុភមង្គលទាំងផ្លូវកាយ និងផ្លូវចិត្តគ្រប់ពេលវេលាតរៀងទៅ។

អារម្ភកថា

សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ ឆ្នាំ២០២០"** គឺជាប្រធានបទ មួយដែលត្រូវបានសិក្សាស្រាវជ្រាវដោយយើងខ្ញុំទាំងពីរដែលជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការដឹកនាំរបស់លោកសាស្ត្រាចារ្យ **បណ្ឌិត ឈុន ណារ៉ែត** ។

សារណាមួយនេះពិតជាមានសារៈសំខាន់បំផុតសម្រាប់និស្សិតរដ្ឋបាលសាធារណៈដូចជាយើងខ្ញុំ ក្នុងការសិក្សាឆ្វេងយល់ឱ្យកាន់ស៊ីជម្រៅ និងចងក្រងទុកជាឯកសារ។ យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការចំណាយនូវកម្លាំងកាយចិត្ត ពេលវេលា និងធនធានផ្ទាល់ខ្លួន ដើម្បីរៀបចំចងក្រងនូវកិច្ចការនៃសារណាមួយនេះឱ្យលេចចេញជារូបរាងឡើង ព្រោះកិច្ចការមួយនេះបានធ្វើឱ្យយើងខ្ញុំចេះធ្វើការសិក្សាស្រាវជ្រាវយ៉ាងសកម្មដែលបានបង្កើននូវចំណេះដឹងមូលដ្ឋាន បណ្តុះគំនិតប្រាជ្ញា និងមានការយល់ដឹងកាន់តែច្បាស់អំពីប្រធានបទមួយនេះ។

យើងខ្ញុំសង្ឃឹម និងរំពឹងទុកជាមុនថាកិច្ចការមួយនេះនឹងអាចក្លាយជាប្រយោជន៍សម្រាប់មជ្ឈដ្ឋានអ្នកស្នេហាការសិក្សាទាំងឡាយ មិត្តនិស្សិត ក៏ដូចជាសិស្សានុសិស្សជំនាន់ក្រោយ ដោយចូលរួមក្នុងការបង្កើននូវពុទ្ធិ ចំណេះដឹងមូលដ្ឋានរបស់អ្នកគ្រប់គ្នា ។ តាមរយៈសារណានេះដែរក៏អាចចូលរួមចំណែកក្នុងផ្សព្វផ្សាយ អំពីបេសកកម្ម តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ ព្រមទាំងស្នាដៃ និងសមិទ្ធផលដែលរដ្ឋបាលសាលារាជធានីភ្នំពេញសម្រេចបាននាពេលកន្លងមក និងសមិទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការងារគ្រប់គ្រងរដ្ឋបាលរបស់សាលារាជធានីភ្នំពេញក្នុងឆ្នាំ ២០២០កន្លងទៅថ្មីៗនេះ។

ដោយសារចំណេះដឹងនៅមានកម្រិតដូច្នេះ ក្រុមយើងខ្ញុំនៅជឿជាក់ថាកំហុសឆ្គងនៅតែកើតមានឡើងឡើងដោយជៀសពុំរួចនោះឡើយ ទាំងអត្ថន័យ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាឃ្លោង ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការចងក្រងនៅមានកម្រិតផងនោះ ។

អាស្រ័យហេតុនេះ យើងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលនឹងអាចកើតមានឡើងដោយប្រការណាមួយពីសំណាក់លោកគ្រូសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ហើយក៏រីករាយ និងទទួលយកនូវការរិះគន់ដើម្បីជាទុនក្នុងការកែលម្អ និងធ្វើឱ្យការសិក្សាស្រាវលើកក្រោយមានភាពល្អប្រសើរឡើង។

រាជធានីភ្នំពេញ ថ្ងៃសុក្រ ៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ត្រូវនឹង ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១

និស្សិតឈ្មោះ

ជាវ ហ្គិច ញ៉ឹក ឈីសម្បត្តិ

មាតិកា

ទំព័រ

បញ្ជីតារាង.....iv

សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ២

៣. គោលបំណងនៃការស្រាវជ្រាវ..... ៣

៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ..... ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ៤

៦. វិធីសាស្ត្រស្រាវជ្រាវ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៥

ជំពូកទី១

សិក្សាទ្រឹស្តីរដ្ឋបាលសាធារណៈ

១.១ ទ្រឹស្តីនៃរដ្ឋបាលសាធារណៈ.....៦

១.១.១ និយមន័យរដ្ឋបាលសាធារណៈ.....៦

១.១.២ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា..... ៧

១.២ រចនាសម្ព័ន្ធរដ្ឋបាលនៅកម្ពុជា..... ១០

១.២.១ រដ្ឋបាលថ្នាក់ជាតិ (រដ្ឋបាលកណ្តាល)..... ១០

១.២.២ រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលមូលដ្ឋាន)..... ១២

១.៣ ប្រវត្តិរដ្ឋបាលសាធារណៈនៅកម្ពុជា..... ១៣

១.៣.១ មុនសម័យបារាំង..... ១៣

១.៣.២ សម័យបារាំង ១៣

១.៣.៣ រដ្ឋបាលសាធារណៈទំនើបក្រោយសម័យបារាំង..... ១៤

ជំពូកទី២

ដំណើរការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ

២.១ ទិដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ..... ១៧

២.១.១ ប្រវត្តិរាជធានីភ្នំពេញ ១៧
២.១.២ ទីតាំងភូមិសាស្ត្រ ១៧
២.១.៣ ស្ថានភាពប្រជាជន ១៨
២.២ ការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ ១៨
២.២.១ រចនាសម្ព័ន្ធរដ្ឋបាលសាលារាជធានីភ្នំពេញ ១៨
២.២.២ អំពីក្រុមប្រឹក្សាសាលារាជធានីភ្នំពេញ ១៩
២.២.២.១ សិទ្ធិអំណាចក្រុមប្រឹក្សារាជធានី ២០
២.២.២.២ របៀបរបបការងាររបស់ក្រុមប្រឹក្សារាជធានី ២១
២.២.២.៣ កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ២២
២.២.២.៤ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ២២
២.២.៣ គណៈអភិបាលរាជធានី ២៣
២.២.៣.១ តួនាទីគណៈអភិបាលរាជធានី ២៣
២.២.៣.២ របៀបរបបការងារគណៈអភិបាលរាជធានី ២៥
២.២.៤ ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី ២៦
២.២.៥ នាយករដ្ឋបាលរាជធានីភ្នំពេញ ២៧
២.២.៦ ទីចាត់ការ និងការិយាល័យចំណុះ ២៧
២.២.៦.១ ទីចាត់ការ ២៩
២.២.៦.២ របៀបរបបការងាររបស់ទីចាត់ការ និងការិយាល័យចំណុះ ២៩
២.២.៧ ទំនាក់ទំនងរវាងរាជធានី ជាមួយខណ្ឌ សង្កាត់ និងស្ថាប័ននានា ៣១

ជំពូកទី៣

សមិទ្ធផលការងារសម្រេចបានរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ ឆ្នាំ២០២០

៣.១ ការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ ៣៥
៣.១.១ ការងាររដ្ឋបាល ៣៥
៣.១.២ ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ៣៦
៣.១.៣ ការងារផែនការ និងការគាំទ្រមូលដ្ឋាន ៣៧
៣.១.៤ ការគ្រប់គ្រងធនធានមនុស្ស ៣៨
៣.១.៥ ការងារអភិវឌ្ឍន៍ទីក្រុង និងអន្តរវិស័យ ៣៩

៣.១.៦ ការងារហិរញ្ញវត្ថុ ៤០
៣.១.៧ ការងារអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ៤១
៣.២ ការងាររដ្ឋបាលខណ្ឌ និងសង្កាត់ ៤៣
៣.២.១ ការងាររដ្ឋបាលខណ្ឌ ៤៣
៣.២.២ ការងាររដ្ឋបាលសង្កាត់ ៤៦

ជំពូកទី៤
បញ្ហាប្រឈម និងដំណោះស្រាយ

៤.១ បញ្ហាប្រឈម ៥១
៤.២ ដំណោះស្រាយ ៥២
៤.៣ ទិសដៅការងារឆ្នាំបន្ទាប់ ៥៤
៤.៣.១ រដ្ឋបាលរាជធានី ៥៤
សេចក្តីសន្និដ្ឋាន ៥៧
អនុសាសន៍ ៥៩
ឯកសារយោង
ឧបសម្ព័ន្ធ

បញ្ជីតារាង

ទំព័រ

តារាងទី១៖ ស្ថានភាពគ្រប់គ្រងរដ្ឋបាលដែនដី ១៧
តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ (ជំរឿនប្រជាជន ឆ្នាំ២០១៩) ១៨
តារាងទី៣៖ រចនាសម្ព័ន្ធរដ្ឋបាលសាលារាជធានីភ្នំពេញ ១៩
តារាងទី៤៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ ៣៥
តារាងទី៥៖ ការផ្សព្វផ្សាយព័ត៌មាន ៣៦
តារាងទី៦៖ ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ៣៧
តារាងទី៧៖ គម្រោងសកម្មភាពរបស់រដ្ឋបាលរាជធានីភ្នំពេញ ៣៧
តារាងទី៨៖ គម្រោងសកម្មភាពរបស់រដ្ឋបាលខណ្ឌ សង្កាត់ ៣៧
តារាងទី៩៖ ស្ថិតិក្រុមប្រឹក្សា គណៈអភិបាលមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ៣៨
តារាងទី១០៖ ទីតាំងអាជីវកម្មដែលបានអនុញ្ញាតច្បាប់ពីរដ្ឋបាលរាជធានី ៤០
តារាងទី១១៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ ៤១
តារាងទី១២៖ ការផ្តល់សេវាសាធារណៈតាមច្រកចេញចូលតែមួយ ៤១

សេចក្តីផ្តើម

សេចក្តីផ្តើម

១. ចំណាំបញ្ហានៃការស្រាវជ្រាវ

រាជធានីភ្នំពេញគឺជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ទេសចរណ៍ វប្បធម៌ និងការទូតដែលមានការអភិវឌ្ឍលើគ្រប់វិស័យ។ ជាពិសេសរាជនីភ្នំពេញគឺជាតួអង្គសំខាន់មួយក្នុងវិស័យរដ្ឋបាលសាធារណៈដែលដើរតួនាទីជាមណ្ឌលរដ្ឋបាលផង និងសមូហភាពដែនដីផងក្នុងការអនុវត្តការគ្រប់គ្រងរដ្ឋបាលបែបថ្មី ។ ការកែទម្រង់រិមជ្ឈការ និងវិសហមជ្ឈការ គឺជាផ្នែកមួយដ៏សំខាន់នៃក្របខ័ណ្ឌគោលនយោបាយ ដែលចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ តាមរយៈ "**ការផ្តល់សេវាសាធារណៈ**" ឱ្យកាន់តែមានប្រសិទ្ធភាពដល់ប្រជាពលរដ្ឋ។ មូលដ្ឋានដ៏សំខាន់សម្រាប់ការអនុវត្តកំណែទម្រង់នេះ រួមមាន ច្បាប់ស្តីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការកែទម្រង់រិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ២០០៥, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឆ្នាំ២០០៨ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩។ ច្បាប់ និងក្របខ័ណ្ឌយុទ្ធសាស្ត្រទាំងនេះបានផ្តល់នូវ គោលការណ៍ណែនាំ និងផ្តល់ជាផែនទីបង្ហាញផ្លូវក្នុងការផ្ទេរធនធាន និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨ បានផ្តល់ជាក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងគោលដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍ "**រដ្ឋបាលឯកភាព**" ដើម្បីបង្កើតជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈការកំណត់តួនាទី មុខងារ និងសិទ្ធិអំណាចទៅតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

សមិទ្ធផលដែលជាគន្លឹះដែលសម្រេចបានពីការកំណែទម្រង់នេះគឺ មូលដ្ឋានគ្រឹះនៃប្រព័ន្ធគ្រប់គ្រងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត និងដាក់ឱ្យអនុវត្តនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្នុងនោះរួមមាន បែបបទ និងនីតិវិធីបំពេញការងារ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធកសាងផែនការ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធទំនាក់ទំនងការងារលក្ខណៈអន្តររដ្ឋបាល យន្តការផ្តល់សេវាតាមច្រកចេញចូលតែមួយ យន្តការទទួល និងដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ និងប្រព័ន្ធតាមដានត្រួតពិនិត្យ និង របាយការណ៍ជាដើម កំពុងត្រូវបានអនុវត្ត និងកែលម្អជាបណ្តើរៗរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ។ យុទ្ធសាស្ត្រពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក៏កំពុងត្រូវបានបញ្ជ្រាបឱ្យកាន់តែស៊ីជម្រៅទៅក្នុងរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីការងាររបស់រដ្ឋបាលថ្នាក់

ក្រោមជាតិ ក្របខ័ណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានដាក់ឱ្យអនុវត្តដែលក្នុងនោះមុខងារមួយចំនួនក៏ត្រូវបានផ្ទេរជាបណ្តើរៗ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងក្នុងបែបផែន ការប្រគល់ និងការធ្វើប្រតិភូកម្មក្នុងលក្ខណៈជាការអនុវត្តសាកល្បងផងដែរ។

២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធានាថាប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ក្នុងប្រទេសកម្ពុជាអាចដំណើរការទៅបានរលូនប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយភាពក្រីក្រ ព្រមទាំងការផ្តល់សេវាសាធារណៈពីរដ្ឋដល់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការអភិវឌ្ឍជាបន្តបន្ទាប់នៃរដ្ឋបាលសាធារណៈ។ ការងារកែទម្រង់ដ៏មានសារៈសំខាន់មួយដែលកំពុងបន្តតួនាទីជាសសរស្តម្ភមួយ សម្រាប់ធានាជោគជ័យនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នេះគឺមាន ការកែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ។ ការកែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការគឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃក្របខ័ណ្ឌគោលនយោបាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានតាមរយៈនៃសិទ្ធអំណាចមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងចាត់ចែងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋមូលដ្ឋាននីមួយៗបានទាន់ពេលប្រកបទៅដោយគុណភាព ប្រសិទ្ធភាព និងគណនេយ្យភាព។ រដ្ឋបាលនៃសាលារាជធានីភ្នំពេញគឺជារដ្ឋបាលថ្នាក់ក្រោមជាតិមួយដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។

ដោយសារស្ថានភាពកាលៈទេសៈនៃពេលវេលា ក៏ដូចជាស្ថានភាពប្រជាជន ស្ថានភាពការងារមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំធ្វើឲ្យមានការទទួលបានសមិទ្ធផលក៏ដូចជាលទ្ធផលនៃការងារផ្សេងៗ ព្រមទាំងបង្កប់នូវបញ្ហាប្រឈមថ្មីៗ ដែលកើតចេញពីការគ្រប់គ្រង អនុវត្តន៍ការងាររដ្ឋបាលរបស់សាលារាជធានីភ្នំពេញក៏មានភាពប្រែប្រួលទៅតាមនោះដែរ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២០នេះដោយមានការរីករាលដាលនៃជម្ងឺកូវីត-១៩ ដែលគ្រោះថ្នាក់ និងប៉ះពាល់ដល់ការរស់នៅ និងអាយុជីវិតរបស់ប្រជាពលរដ្ឋទូទាំងពិភពលោក ក៏ដូចជាប្រជាពលរដ្ឋកម្ពុជា និងរាជធានីភ្នំពេញដែលធ្វើឲ្យយើងផ្សាំខ្លួនទៅនឹងស្ថានភាពសង្គមដែលបានតម្រូវដាច់ខាតនូវការវិវឌ្ឍតឈប់ពិសេសបច្ចេកវិទ្យា និងឧបករណ៍អេឡិចត្រូនិកដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសម័យឌីជីថលនាំមកតាមរយៈសាកលភាវូបនីយកម្មលើពិភពលោក។

ការអនុវត្តការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញនាពេលកន្លងមក ចាប់តាំងពីបុរាណកាលរហូតមកទល់នឹងពេលបច្ចុប្បន្ន ដែលត្រូវបានឆ្លងកាត់ឧបសគ្គជាច្រើនយ៉ាង និងប្រើប្រាស់ពេលវេលាជាច្រើនអនេកក្នុងគោលបំណងដកពិសោធន៍ ដោយទទួលបានលទ្ធផលវិជ្ជមានជាច្រើនទន្ទឹមនឹងនេះការងារនេះជួបប្រទះនឹង

បញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយប្រកបដោយប្រសិទ្ធភាព។ ដោយផ្អែកលើមធ្យោបាយគ្រប់គ្រងរដ្ឋបាលជាច្រើនឆ្នាំកន្លងមក យើងខ្ញុំបានកំណត់នូវចំណោទបញ្ហានៃការស្រាវជ្រាវដូចខាងក្រោម៖

១- តើរដ្ឋបាលនៃសាលារាជធានីភ្នំពេញបានសម្រេចសមិទ្ធផលអ្វីខ្លះនៅក្នុងឆ្នាំ២០២០?

២-តើការគ្រប់គ្រង និងបំពេញការងាររបស់រដ្ឋបាលរាជធានីភ្នំពេញមានដំណើរការយ៉ាងណាខ្លះ?

៣-តើមានបញ្ហាប្រឈម និងដំណោះស្រាយអ្វីខ្លះក្នុងការអនុវត្តគ្រប់គ្រងការងាររបស់សាលារាជធានីភ្នំពេញក្នុងឆ្នាំ២០២០?ហើយមានទិសដៅការងារអ្វីបន្ថែមទៀតនៅឆ្នាំបន្ទាប់ដើម្បីទទួលបានលទ្ធផលកាន់តែប្រសើរឡើង?

៣. គោលបំណងនៃការស្រាវជ្រាវ

បានជាក្រុមរបស់យើងខ្ញុំជ្រើសរើសយកប្រធានបទ **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ"**មកសិក្សាស្រាវជ្រាវដោយហេតុថាពួកយើងមានគោលបំណងដូចខាងក្រោម៖

១. សិក្សាស្វែងយល់អំពីដំណើរការទូទៅនៃការគ្រប់គ្រង និងអនុវត្តន៍កិច្ចការរដ្ឋបាលរបស់សាលារាជធានីភ្នំពេញពេលបច្ចុប្បន្ននេះ។

២.សិក្សាលើបច្ចុប្បន្នភាពរបស់រដ្ឋបាលសាលារាជធានីភ្នំពេញដែលមានការអភិវឌ្ឍលើគ្រប់វិស័យដូចជា៖

- ការអភិវឌ្ឍនៃការគ្រប់គ្រង រៀបចំ ចាត់ចែងលើការងាររដ្ឋបាល
- ការអភិវឌ្ឍរាជធានីភ្នំពេញ ដូចជាហេដ្ឋារចនាសម្ព័ន្ធ និងការរីកចំរើនផ្នែកសេដ្ឋកិច្ច

៣. សមិទ្ធផលនៃការគ្រប់គ្រងរបស់រដ្ឋបាលសាលារាជធានីភ្នំពេញដែលសម្រេចបាននៅក្នុងឆ្នាំ២០២០

៤.សិក្សាស្វែងយល់អំពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានព្រមទាំងបញ្ហាប្រឈម ដំណោះស្រាយដែលបានជួបប្រទះនៅក្នុងឆ្នាំ២០២០ និងលើកទិសដៅការងារសម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់។

៤. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានកំណត់អំពី វិសាលភាពដែលយោងទៅតាមកម្រិត និងក្នុងរយៈពេលនៃការស្រាវជ្រាវប្រធានបទ **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ"** ។ ការស្រាវជ្រាវនេះផ្តោតទៅលើការ អនុវត្តមុខងារ និងតួនាទីរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តមុខងារ និងគោលនយោបាយ ក៏ដូចជាយុទ្ធសាស្ត្រដែលចេញដោយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ក្នុងការស្រាវជ្រាវទៅលើ ប្រធានបទ **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ"** ស្ថិតក្នុងរយៈពេលជាក់លាក់មួយគឺក្នុង ឆ្នាំ២០២០។

ការសិក្សាស្រាវជ្រាវអំពីប្រធានបទ **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ"** នេះមានវិសាលភាពលើ ៖

- រចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ

- សមិទ្ធផលការងារសម្រេចបានរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ ឆ្នាំ២០២០
- បញ្ហាប្រឈម និងដំណោះស្រាយ

៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាពីប្រធានបទរបស់យើងពិតជាមានសារៈសំខាន់ ផ្អែកលើចំណុចមួយចំនួនដូចខាងក្រោម៖

- អ្នកអានគ្រប់រូបអាចដឹងឱ្យកាន់តែច្បាស់អំពី **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ"** ដែលរាល់សកម្មភាពទាំងអស់នេះសុទ្ធសឹងតែជាអ្វីដែលប្រជាជនគ្រប់រូបគួរតែដឹង។
- ការសិក្សាលើប្រធានបទនេះមានសារៈសំខាន់ដល់ពួកយើងផងដែរ ដោយហេតុថាការសិក្សាលើប្រធានបទនេះបានអនុញ្ញាតឱ្យយើងបានស្វែងយល់ពីខ្លឹមសារនៃប្រធានបទ និងព័ត៌មានបន្ថែមដែលបានមកពី ការស្រាវជ្រាវ និងបានជាបទពិសោធន៍ក្នុងការសរសេរ និងបំណិនបន្ថែមនៅក្នុងជីវិត។ មួយវិញទៀត ការសរសេរអត្ថបទសិក្សាស្រាវជ្រាវនេះ គឺជាគោលបំណងរបស់ពួកយើងតាំងពីថ្នាក់មូលដ្ឋានមកម្ល៉េះ ហេតុដូចនេះហើយ ការសរសេរនេះគឺមានអត្ថន័យយ៉ាងជ្រៀលជ្រៅសម្រាប់ពួកយើងដោយមិនមែនត្រឹមតែជាកាតព្វកិច្ចក្នុងការបញ្ចប់ការសិក្សាប៉ុណ្ណោះទេ។
- ជាមួយគ្នាផងដែរ ការស្រាវជ្រាវមួយនេះបានផ្តល់ នូវពុទ្ធិតាមរយៈ ការស្វះស្វែងទាញយកប្រភពព័ត៌មានដកស្រង់នូវខ្លឹមសារល្អៗដែលទាក់ទងទៅនឹង **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ"** ព្រមទាំងប្រភពនៃលិខិតបទដ្ឋានគតិយុត្តនានា ជាពិសេសកិច្ចការមួយនេះអាចឱ្យយើងខ្ញុំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។
- ទន្ទឹមនឹងនេះដែរកិច្ចការមួយនេះក៏អាចចូលរួមចំណែកក្នុងផ្សព្វផ្សាយអំពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធ ព្រមទាំងស្នាដៃ និងសមិទ្ធផលផ្សេងៗដែលសម្រេចកន្លងមកលើគ្រប់ផ្នែករួមទាំងសមិទ្ធផលសំខាន់ៗពាក់ព័ន្ធនឹងការងារកែទម្រង់រដ្ឋបាលសាធារណៈដល់សាធារណៈជនឱ្យបានដឹង។ ក្រៅពីនេះកិច្ចការមួយនេះនឹងផ្តល់ជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយសម្រាប់យកទៅសិក្សា និងសិក្សាស្រាវជ្រាវបន្តផងដែរ។

៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើ **"ការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ"** ដើម្បីប្រមូលព័ត៌មាន និងទិន្នន័យសម្រាប់ធ្វើការផលិតចងក្រង និងសរសេរសារណាមួយនេះឲ្យមានភាពប្រសើរគឺមានសកម្មភាពស្រាវជ្រាវដូចជា៖

- លិខិតបទដ្ឋានគតិយុត្តនានាដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងច្បាប់ផ្សេង.....

- ប្រមូលព័ត៌មាននៅបណ្ណាល័យជាតិ បណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ការចុះទៅសិក្សាស្រាវជ្រាវនៅសាលារាជធានីភ្នំពេញ
- ការជួបសម្ភាសន៍ និងការណែនាំផ្ទាល់ពីមន្ត្រីនៅតាមទីចាត់ការនីមួយៗ
- ការជួបសម្ភាសន៍ និងការណែនាំផ្ទាល់របស់សាស្ត្រាចារ្យដឹកនាំ
- ប្រមូលឯកសារទិន្នន័យជាច្រើនទៀតតាមរយៈប្រព័ន្ធអេឡិចត្រូនិច មានប្រព័ន្ធអ៊ីនធឺណេត បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានាជាច្រើនថែមទៀត។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្រោយពីបានពិភាក្សាគ្នា និងការស្វែងរកនូវប្រភពឯកសារពាក់ព័ន្ធនានា ព្រមទាំងទទួលបាននូវការណែនាំ និងឯកភាពពីសាស្ត្រាចារ្យណែនាំរួចមក យើងខ្ញុំបានសម្រេចបែងចែករចនាសម្ព័ន្ធនៃការស្រាវជ្រាវ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូកទី១ ៖ សិក្សាទ្រឹស្តីរដ្ឋបាលសាធារណៈ
- ជំពូកទី២ ៖ ដំណើរការគ្រប់គ្រងរដ្ឋបាលនៃសាលារាជធានីភ្នំពេញ
- ជំពូកទី៣ ៖ សមិទ្ធផលការងារសម្រេចបានរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ ឆ្នាំ២០២០
- ជំពូកទី៤ ៖ បញ្ហាប្រឈម និងដំណោះស្រាយ
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

ជំពូកទី១
សិក្សាទ្រឹស្តីនៃរដ្ឋបាលសាធារណៈ

ជំពូកទី១

សិក្សាទ្រឹស្តីនៃរដ្ឋបាលសាធារណៈ

១.១ ទ្រឹស្តីនៃរដ្ឋបាលសាធារណៈ

១.១.១ និយមន័យរដ្ឋបាលសាធារណៈ

រដ្ឋបាលសាធារណៈ មានសកម្មភាពយូរណាស់មកហើយតែពាក្យរដ្ឋបាលសាធារណៈទើបតែឃើញគេប្រើប្រាស់នៅក្នុងចុងសតវត្សរ៍ទី ១៨ នៅក្នុងប្រទេសបារាំងដែលមានអត្ថន័យសំដៅទៅលើគ្រប់សកម្មភាពរបស់រដ្ឋលើកលែងតែការថែរក្សាសន្តិសុខ ការការពារជាតិ និងការទូត។ នៅក្នុងសម័យនោះរដ្ឋបាលសាធារណៈបង្កប់នូវគំនិតត្រួតត្រានិយមពោល មិនមានគំនិតអភិរក្សនិយមបម្រើដល់ប្រយោជន៍ទូទៅដូចក្នុងសម័យកាលបច្ចុប្បន្នឡើយ។ រដ្ឋបាលសាធារណៈមានអត្ថន័យទូលាយតែខ្ញុំលើកយកអត្ថន័យសំខាន់ៗបីមកបង្ហាញគឺ៖

- **ន័យអក្សរសាស្ត្រ៖** ពាក្យរដ្ឋបាល បានមកពីរដ្ឋ និងអភិបាល។ រដ្ឋមានន័យថាដែន ឬ ប្រទេសចំណែកអភិបាល មានន័យថា អ្នកគ្រប់គ្រង អ្នកបីបាច់ថែរក្សា អ្នកថែរក្សា។ ដូច្នេះ **រដ្ឋបាល** មានន័យថាអ្នករក្សាដែន ឬ ប្រទេស[1]។
- **ន័យទូលំទូលាយបែបបច្ចេកទេស៖** ពាក្យរដ្ឋបាលត្រូវបានគេយល់គ្រប់គ្នាថាជាសកម្មភាពទៅជាការគ្រប់គ្រងរដ្ឋ ព្រោះជួនកាលគេបានប្រើជាសកម្មភាព ជួនកាលវាជាលក្ខណៈអង្គការហើយថែមទាំងប្រើលើវិស័យឯកជន និងវិស័យសាធារណៈទៀតផង[2]។
- **ន័យចង្អៀតបែបបច្ចេកទេស៖** ពាក្យរដ្ឋបាលសំដៅលើរដ្ឋបាលសាធារណៈ។ យើងអាចប្រើពាក្យថា រដ្ឋការ ឬ រាជការ ដែលនាំឲ្យមានការភ័ន្តច្រឡំជាមួយពាក្យរដ្ឋបាលក្នុងវិស័យឯកជននោះទេ។

  រដ្ឋបាលសាធារណៈ៖ គឺវិស័យសិក្សាស្រាវជ្រាវដែលមានគោលបំណងជាសំខាន់ធ្វើឲ្យរាជរដ្ឋាភិបាលអាចដំណើរការបានតាមរយៈការរីកចម្រើនការគ្រប់គ្រង និងគោលនយោបាយក្រៅពីនេះមានការផ្តល់និយមន័យរដ្ឋបាលផ្សេងៗជាច្រើនទៀតដូចជា៖

  - រដ្ឋបាលសាធារណៈ ជាការគ្រប់គ្រងលើកម្មវិធីសាធារណៈ (The management of public program)
  - រដ្ឋបាលសាធារណៈ ជាការបកស្រាយនយោបាយទៅជាទិដ្ឋភាពជាក់ស្តែង (The translation of politics in to the reality) ដែលប្រជាពលរដ្ឋបានឃើញជារៀងរាល់ថ្ងៃ

[1] សម្តេចព្រះសង្ឃរាជ ជួន ណាត , វចនានុក្រមខ្មែរ

[2] ហៀង សាង ,នីតិរដ្ឋបាលទូទៅ,បោះពុម្ពលើកទី៣ ឆ្នាំ២០០១

- រដ្ឋបាលសាធារណៈ គឺជាការសិក្សាលើការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាល (The studies of government decision making)
- ការធ្វើការវិភាគលើនយោបាយរដ្ឋាភិបាល(Analysis its policy)ធាតុចូលផ្សេងៗ(Inputs) ដែលបង្កើតគោលនយោបាយ និងធាតុចូលផ្សេងៗទៀតដែលបង្កើតគោលនយោបាយជម្រើស[3]។

ការសិក្សារដ្ឋបាលសាធារណៈ បានផ្តល់ប្រយោជន៍ច្រើនវាជួយឲ្យយើងទទួលបានចំណេះដឹងអំពីការអនុវត្តនូវគោលនយោបាយសាធារណៈ។ គោលនយោបាយសាធារណៈនេះគឺជាផែនការសកម្មរបស់រាជរដ្ឋាភិបាលធ្វើឡើងដើម្បីដោះស្រាយរាល់បញ្ហាក្សាសណ្តាប់ធ្នាប់សង្គម ពង្រឹងស្ថិរភាពនយោបាយ និងពង្រីកការអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីដឹកនាំប្រទេសជាតិឲ្យស្របទៅតាមបន្ទាត់គោលនយោបាយរាជរដ្ឋាភិបាលដែលបានសន្យាមុនពេលជាប់ឆ្នោត[4]។ គោលនយោបាយរបស់គណបក្សនយោបាយណាមួយនឹងបានក្លាយជាគោលនយោបាយជាតិនៅពេលដែលគណបក្សនោះជាប់ឆ្នោត។

ទោះជាយ៉ាងណាក្តីទាក់ទងនឹងការផ្តល់និយមន័យពីរដ្ឋបាលសាធារណៈ មកទល់នឹងពេលបច្ចុប្បន្ននេះពុំទាន់មានការឯកភាពគ្នាទាំងស្រុងនោះទេ ព្រោះវាជាមុខវិជ្ជាដែលមានវិសាលភាពធំទូលាយងាយស្រួលយល់ជាងការឲ្យនិយមន័យ។ ជាទូទៅនៅពេលដែលគេសិក្សាពីរដ្ឋបាលសាធារណៈគេតែងលើកយកនូវទស្សនៈរបស់បុគ្គលល្បីដែលបានលើកឡើងពីរដ្ឋបាលសាធារណៈដើម្បីពន្យល់បកស្រាយ និងប្រៀបធៀប។

១.១.២ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា

❖ **ប្រព័ន្ធមជ្ឈការ(Centralization)**

ការគ្រប់គ្រងបែបមជ្ឈការ គឺជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមួយប្រភេទ ដែលរដ្ឋបាលកណ្តាលដឹកនាំរដ្ឋាភិបាលដោយផ្ទាល់ (អំណាចប្រមូលផ្តុំ) ពោលរដ្ឋគឺជាអ្នកដែលមានសិទ្ធិអំណាចផ្តាច់មុខទៅលើការងារគ្រប់គ្រង និងសម្រេចលើកិច្ចការងាររដ្ឋបាលរបស់ប្រទេសនោះដែលមានរាជរដ្ឋាភិបាលគឺជាអ្នកដឹកនាំរួមទាំងមាន ក្រសួង ស្ថាប័ន អាជ្ញាធររបស់រដ្ឋនានាជាសេនាធិការ។ រាល់កិច្ចការងារទាំងអស់ត្រូវឆ្លងកាត់ការសម្រេចរបស់រដ្ឋបាលកណ្តាល។

អំណាចកណ្តាលគឺជា អំណាចរបស់អង្គការនីតិប្រតិបត្តិ (រាជរដ្ឋាភិបាល) ដែលមានគណៈរដ្ឋមន្ត្រីមួយ។

[3] សៅ ឡាយ, សេចក្តីផ្តើមរដ្ឋបាលសាធារណៈ ឆ្នាំ២០១៤ ទំព័រទី១

[4] បណ្ឌិត ឈុន ណារ៉ែត និង ខៀវ វិជ្ជានន្ទ, គោលនយោបាយសាធារណៈ និងដំណើរការធ្វើច្បាប់ ឆ្នាំ២០១៩ ទំព័រទី៤

គណៈរដ្ឋមន្ត្រីនេះកាន់កាប់ដោយនាយករដ្ឋមន្ត្រីអមដោយ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការជាសមាជិក។[5]

ចំណែកមជ្ឈការវិញគឺជាអំណាចដែលប្រមូលផ្តុំមួយនៅក្នុងកណ្តាប់ដៃអំណាចកណ្តាលទាំងអស់។ តាមការងារជាក់ស្តែងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងបញ្ហា ប្រើប្រាស់យោធា នគរបាល កម្លាំងប្រដាប់អាវុធផ្សេងៗទៀត និងរដ្ឋបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន។[6]

ប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការនេះវាក៏នាំឱ្យអាជ្ញាធររដ្ឋបាលកណ្តាលមានភាពរឹងមាំហើយការតែងតាំងបុគ្គលឲ្យបម្រើការនៅថ្នាក់មូលដ្ឋានសុទ្ធតែជាមនុស្សមានសមត្ថភាព និងមានឯកភាពជាតិ។ទន្ទឹមនឹងនេះប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការអាចបង្កនូវភាពយឺតយ៉ាវនៅក្នុងការសម្រេច ដែលមិនយល់សភាពការណ៍ព្រមទាំងខ្វះលទ្ធិប្រជាធិបតេយ្យជាដើម។

- **ប្រព័ន្ធវិមជ្ឈការ**

វិមជ្ឈការគឺសំដៅទៅលើការផ្ទេរនូវមុខងារ និងធនធានមួយចំនួនរបស់រាជរដ្ឋាភិបាលទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិដែលជាប់ឆ្នោត ហើយក្រុមប្រឹក្សានេះត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ វិមជ្ឈការ ជាការផ្តល់នូវអំណាច និងឆន្ទានុសិទ្ធិពេញលេញដល់ក្រុមប្រឹក្សាដើម្បីធ្វើសេចក្តីសម្រេចចិត្ត ដែលឆ្លុះបញ្ចាំងពី សេចក្តីត្រូវការ ផលប្រយោជន៍ និងតថភាពនៅមូលដ្ឋាន។ ប៉ុន្តែអំណាច និងឆន្ទានុសិទ្ធិដែលក្រុមប្រឹក្សាទទួលបានត្រូវមានដែនកំណត់។[7]

<u>ទី១</u> ៖ វិមជ្ឈការ ត្រូវតែមានអាជ្ញាធរថ្នាក់ក្រោមជាតិមួយ ត្រូវបានបោះឆ្នោតជ្រើសរើសឡើង ដើម្បីជាមធ្យោបាយសម្រាប់អនុវត្តការងារ។ ជាគោលការណ៍ វិមជ្ឈការអាចអនុវត្តចំពោះរដ្ឋបាលនានានៅក្នុងថ្នាក់ក្រោមជាតិទាំងអស់ឲ្យតែរដ្ឋបាលទាំងនោះបោះឆ្នោតជ្រើសរើសឡើង។

<u>ទី២</u> ៖ វិមជ្ឈការ តម្រូវឱ្យរាជរដ្ឋាភិបាលលះបង់ និងផ្ទេរភាពជាម្ចាស់លើមុខងារសមស្របទៅឱ្យក្រុមប្រឹក្សាដែលបានជាប់ឆ្នោត។ មុខងារអាចមានអត្ថន័យច្រើនយ៉ាងអាចជាសេវាដែលត្រូវបានផ្តល់ទៅឱ្យប្រជាពលរដ្ឋ។ លើសពីនេះទៅទៀតក៏មានមុខងារដែលទាក់ទងនឹងវិស័យនានា ដូចជាមុខងារធ្វើផែនការរៀបចំថវិកា ការធ្វើលទ្ធកម្ម ការត្រួតពិនិត្យ និងការវាយតម្លៃគ្រប់គ្រងបុគ្គលិក និងការចេញដីការជាដើម។

[5] មាត្រា ១១៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ ឆ្នាំ១៩៩៣

[6] មាត្រា ២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ១៩៩៤

[7] សាស្ត្រាចារ្យ ហៀង សាង សហត្ថិភាពរដ្ឋបាលដែនដីនៃកម្ពុជា ឆ្នាំ២០១៨

ជាគោលការណ៍រាជរដ្ឋាភិបាលធ្វើការត្រួតពិនិត្យលើមុខងារទាំងនោះដើម្បីធានាឱ្យបានថាតើសកម្មភាពអ្វីដែលផ្ទុយ ឬ ប្រឆាំងទៅនឹងផលប្រយោជន៍ជាតិ?

<u>ទី៣</u> ៖ នៅក្នុងវិមជ្ឈការ ក្រុមប្រឹក្សាជាប់ឆ្នោត ត្រូវតែទទួលបាននូវការផ្ទេរធនធានចាំបាច់ ដើម្បីសម្រេចអនុវត្ត និងគ្រប់គ្រងនូវមុខងាររបស់ខ្លួន។ ធនធានទាំងនោះរួមមាន៖ ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិចាំបាច់ដើម្បីអនុវត្តនូវមុខងារនីមួយៗ។

វិមជ្ឈការមានគោលបំណងផ្តល់នូវស្វ័យភាពមូលដ្ឋាន។ ប៉ុន្តែមិនមែនភាពជាអធិបតេយ្យដល់ក្រុមប្រឹក្សាជាប់ឆ្នោតធ្វើជាតំណាងឲ្យសហគមន៍មូលដ្ឋានរបស់ពួកគេ ហើយក្រុមប្រឹក្សានេះមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះសហគមន៍មូលដ្ឋានរបស់ពួកគេលើការអនុវត្តនូវមុខងាររបស់ខ្លួន។ វិមជ្ឈការមិនមានន័យថាជាការផ្តាច់ក្រុមប្រឹក្សាពីថ្នាក់ក្រោមជាតិ ឬ ពីអង្គភាពរបស់ថ្នាក់ជាតិ ឬ ពីថ្នាក់ផ្សេងៗនោះទេ។ វិមជ្ឈការត្រូវបានកសាងឡើងដោយបានផ្អែកទៅលើអភិក្រមយ៉ាងរឹងមាំដើម្បីសម្របសម្រួល កិច្ចសហការគ្នា និងការពឹងផ្អែកលើគ្នាទៅវិញទៅមកវាងថ្នាក់អភិបាលកិច្ចផ្សេងៗ។ ប៉ុន្តែថ្នាក់នីមួយៗនៅតែមានស្វ័យភាពរៀងៗខ្លួននៅក្នុងការអនុវត្តអាណត្តិ និងមុខងាររបស់ខ្លួន។

- **ប្រព័ន្ធវិសហមជ្ឈការ**

ប្រព័ន្ធវិសហមជ្ឈការ ត្រូវបានសំដៅទៅលើការធ្វើប្រតិភូកម្មការងារពីថ្នាក់ជាតិទៅឲ្យអង្គភាពថ្នាក់ក្រោមជាតិដទៃទៀត។[8] ឬ ន័យមួយបែបទៀតវិសហមជ្ឈការ គឺជាបច្ចេកទេសគ្រប់គ្រងរដ្ឋបាលដែលអាជ្ញាធររដ្ឋបាលកណ្តាល រំលែកកិច្ចការមួយចំនួនទៅឲ្យអាជ្ញាធររដ្ឋបាលមូលដ្ឋានធ្វើការសម្រេចដោយខ្លួនឯងផ្ទាល់តាមការកំណត់ហើយ សម្រេចតាងនាមអាជ្ញាធររដ្ឋបាលកណ្តាល។

ដូច្នេះអាជ្ញាធរមូលដ្ឋានធ្វើការសម្រេចកិច្ចការចាំបាច់ និងបន្ទាន់ខ្លះៗនៅនឹងកន្លែង (មូលដ្ឋាន)ដោយមិនចាំបាច់សុំការអនុញ្ញាតក្នុងការសម្រេចពីអាជ្ញាធររដ្ឋបាលកណ្តាលដូចមុនឡើយ ពីព្រោះអាជ្ញាធរមូលដ្ឋាននៅពេលនេះទទួលបានសិទ្ធិអំណាចក្នុងការសម្រេចតាមការកំណត់ឱ្យក្នុងលក្ខខណ្ឌដែលចែងច្បាស់លាស់ហើយ។

ការគ្រប់គ្រងរដ្ឋបាលប្រភេទនេះគឺជាការគ្រប់គ្រងតាមហានានុក្រមរដ្ឋបាល ដែលអំណាចកណ្តាល បានផ្តល់ឱ្យរដ្ឋបាលក្រោមជាតិសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។

ការរំលែកអំណាចកណ្តាលក្នុងការសម្រេចនេះគឺគេប្រើវិធីមួយហៅថាប្រតិភូកម្មចែកចេញជាពីរគឺ៖

[8] សាស្ត្រាចារ្យ ហៀង សាង និងអនុបណ្ឌិត ប៉ែង ឆុង ការគ្រប់គ្រងរដ្ឋបាលដែនដី ឆ្នាំ២០១២

- **ប្រតិភូកម្មអំណាច៖** គឺវាមានការផ្ទេរសមត្ថកិច្ចមួយផ្នែកឱ្យទៅកាន់អាជ្ញាធររដ្ឋបាលទាំងឡាយនៅក្នុងឋានានុក្រមរដ្ឋបាលរបស់ខ្លួនប៉ុណ្ណោះ ។ ហើយប្រតិភូកម្មអំណាចធ្វើទៅបានគឺលុះត្រាតែមានលិខិតបទដ្ឋានគតិយុត្តចែងប៉ុណ្ណោះ។
- **ប្រតិភូកម្មហត្ថលេខា៖** គឺជាវិធីមួយដែលតាមរយៈនេះ អាជ្ញាធររដ្ឋបាលនីមួយៗបានប្រគល់ទៅឱ្យសហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជំនួសទៅលើសេចក្តីសម្រេចខ្លះ ដែលនេះជាភាពងាយស្រួល មួយផ្នែកការងារគ្រប់គ្រងរដ្ឋបាល ដោយពុំចាំបាច់ធ្វើប្រតិភូកម្មអំណាចទៀតទេ។ សហការីនេះមិនអាចផ្ទេរការចុះហត្ថលេខាជំនួសទៅឱ្យជនទីបីបានឡើយ។ ប្រតិភូកម្មហត្ថលេខានេះត្រូវប្រគល់ឱ្យចំឈ្មោះបុគ្គលដែលជាសហការីដោយបញ្ជាក់ពីឋានៈតួនាទីឲ្យបានច្បាស់លាស់ ហើយត្រូវធ្វើសាជាថ្មី បើមានការផ្លាស់ប្តូរបុគ្គល។ ការធ្វើប្រតិភូកម្មហត្ថលេខា គឺមានតែលើការចុះហត្ថលេខាប៉ុណ្ណោះដោយគ្មានប៉ះពាល់ទៅដល់ការបែងចែកអំណាចនោះទេ។ អាជ្ញាធរដែលបានផ្ទេរហត្ថលេខាដែលអាចរក្សាសិទ្ធិចុះហត្ថលេខាវិញគ្រប់ពេលវេលា។[9]

១.២ រចនាសម្ព័ន្ធរដ្ឋបាលនៅកម្ពុជា

អាជ្ញាធររដ្ឋបាលជាបុគ្គលមានសមត្ថកិច្ចដឹកនាំការងារតាមក្រសួង និងស្ថាប័នរដ្ឋ។ រដ្ឋបាលកណ្តាលមានតួនាទីបំពេញមុខងាររដ្ឋបាលនៅលំដាប់ថ្នាក់លើ និងស្ថិតនៅក្នុងក្របខ័ណ្ឌជាតិទាំងមូល ហើយគេមិនអាចប្រគល់អំណាចដោយគ្មានទិសដៅ និងគ្មានកាតព្វកិច្ចនោះទេ។ អំណាចកណ្តាលមានសមត្ថកិច្ចទូទៅលើដែនដីនៃប្រទេស។ បើនិយាយពីសកម្មភាពរបស់រដ្ឋ គឺអាជ្ញាធរនៃ អំណាចកណ្តាលជាអ្នកដឹកនាំដោយផ្ទាល់ ឬ តាមរយៈតំណាងទាំងឡាយរបស់រដ្ឋាភិបាលនៅតាមដែនដីនីមួយៗ។ ដោយតាមរយៈនេះប្រព័ន្ធរដ្ឋបាលទូទៅត្រូវបានកំណត់ជាពីរថ្នាក់រួមមាន៖ រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

១.២.១ រដ្ឋបាលថ្នាក់ជាតិ (រដ្ឋបាលកណ្តាល)

រដ្ឋបាលកណ្តាល គឺជាការប្រមូលផ្តុំនូវអាជ្ញាធររួមបណ្តុលគ្នាបានជាអំណាចនីតិប្រតិបត្តិដើម្បីធានាទៅលើការគ្រប់គ្រង និងដឹកនាំប្រទេស។

រដ្ឋបាលកណ្តាលត្រូវបានកំណត់ឱ្យមានស្ថាប័នដូចជា៖ ព្រះមហាក្សត្រ និងរាជរដ្ឋាភិបាល។

[9] ឧត្តមសិក្សាជាន់ខ្ពស់ ង៉ឹយ ធឿន នីតិរដ្ឋបាល ឆ្នាំ២០១៧

❖ **ព្រះមហាក្សត្រ**

ការកំហិតអំណាចរបស់ព្រះមហាក្សត្រ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ចាប់តាំងពីមាត្រាដំបូងក្នុង ជំពូកទី២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលចែងពីព្រះមហាក្សត្រ។ ផ្អែកតាមមាត្រា៧ វាក្យខ័ណ្ឌទី១ ចែង ថា"ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ" ។[10] អត្ថន័យនៃមាត្រានេះត្រូវ បានពង្រឹងបន្ថែមដោយមាត្រា១៧ ដែលចែងពីការមិនអាចកែប្រែបាន។ ការចែងរបៀបនេះ វាកាត់ផ្តាច់ទាំងស្រុង ជាមួយនឹងប្រពៃណីរាជានិយមខ្មែរ ដែលរហូតមកដល់ឆ្នាំ១៩៧០ បានថែរក្សានូវគោលការណ៍មួយ គឺអំណាច ទាំងអស់ជារបស់ព្រះមហាក្សត្រ ហើយព្រះមហាក្សត្រអាចផ្ទេរអំណាចនេះបាន (អាចចាត់តាំងរាជ្ជទាយាទ) ។

ទោះជាយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញក៏បានចែងពីអំណាចមួយចំនួនរបស់ព្រះមហាក្សត្រ ដែលវាមិនមែន ជាអំណាចផ្នែកនយោបាយ តែវាជាអំណាចផ្នែករដ្ឋបាល ដោយគេបានបង្កើតឲ្យមានក្នុងលក្ខណៈជាទម្រង់ ហើយយើងនឹងលើកមកធ្វើការសិក្សាជាពេលបន្ទាប់នេះ។

- អំណាចទាក់ទងនឹងរាជរដ្ឋាភិបាល
- អំណាចទាក់ទងនឹងកិច្ចការយោធា
- អំណាចទាក់ទងនឹងកិច្ចការការទូត
- អំណាចទាក់ទងនឹងអង្គការនីតិបញ្ញត្តិ
- អំណាចទាក់ទងនឹងតុលាការ

❖ **រាជរដ្ឋាភិបាល**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាអង្គការនីតិប្រតិបត្តិដែលមានសមត្ថកិច្ចកំណត់ហើយនិង អនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

រាជរដ្ឋាភិបាល ដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ស្របតាមកម្មវិធីនយោបាយរបស់ខ្លួន។ រាជរដ្ឋាភិបាល ត្រូវ ការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។

តាមមាត្រា៧នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨ត្រូវបានចែងថា រាជរដ្ឋាភិបាលគ្រប់គ្រង ដឹកនាំ បញ្ជាប្រើប្រាស់រដ្ឋបាលសាធារណៈគ្រប់ថ្នាក់ រួមទាំងកងយោធពល ខេមរភូមិន្ទ នគរបាលជាតិ និងកម្លាំងប្រដាប់អាវុធផ្សេងៗទៀតក្នុងការធ្វើសកម្មភាពរបស់ខ្លួន[11]។

- គណៈរដ្ឋមន្ត្រី

[10] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រឆ្នាំ(១៩៩៣)

[11] មាត្រា៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង

១.២.២ រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលមូលដ្ឋាន)

នៅមុនឆ្នាំ២០០៩ យោងមាត្រា១៤៥ នៃរដ្ឋធម្មនុញ្ញចែងថាទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបែងចែកជា ខេត្ត ក្រុង។ ខេត្តចែកជាស្រុក ហើយស្រុកចែកជាឃុំ។ ក្រុងចែក ជាខណ្ឌ ហើយខណ្ឌចែកជាសង្កាត់។

ចាប់ពីឆ្នាំ ២០០៩មក តាមមាត្រា១៤៥ថ្មី នៃរដ្ឋធម្មនុញ្ញ និងបំពេញបន្ថែមដោយច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានចែងបញ្ជាក់ត្រង់មាត្រា៤ ភ្នំពេញជារាជធានី នៃព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញ ចែកជាខណ្ឌ។ ខណ្ឌចែកជាសង្កាត់។ មាត្រា៥ ខេត្តចែកជាក្រុង និងជាស្រុក។ ក្រុងចែកជាសង្កាត់។ ស្រុក ចែកជាឃុំ និងជាសង្កាត់។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ តាមមាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់ឲ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ មានដែនដី ប្រជាពលរដ្ឋ និងមានក្រុមប្រឹក្សាមួយជាតំណាង។ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវបានដឹកនាំដោយក្រុមប្រឹក្សា និងគណៈអភិបាល) ។

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៖ រាជធានី ខេត្ត គឺជាថ្នាក់រដ្ឋបាលដែនដីមួយដែលខ្ពស់បំផុតនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។

ក្រុង ស្រុក ខណ្ឌ គឺជាថ្នាក់រដ្ឋបាលដែនដីបន្ទាប់ពីរាជធានី-ខេត្ត ដែលត្រូវបង្កើតឡើងដោយ អនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវកសាងឱ្យបាននូវរបៀបរបបធ្វើការងារផ្ទៃក្នុងឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានត្រឹមត្រូវនូវរបៀបរបបការងារនោះ។

ឃុំ សង្កាត់ ក៏ជាក់រដ្ឋបាលដែនដីមួយរបស់ព្រះជាណាចក្រកម្ពុជាដែរ។ ការប្រព្រឹត្តិ ឃុំ សង្កាត់ទាំងអស់តាមរយៈនយោបាយវិមជ្ឈការ។ ការបំពេញភារកិច្ចរបស់ឃុំ សង្កាត់ គឺត្រូវផ្អែកលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ ព្រមទាំងត្រូវមានអព្យាក្រឹតភាពក្នុងការធ្វើសកម្មភាពការងាររបស់ខ្លួន។ ការបង្កើតការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់សង្កាត់នៅក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់រាជធានី ខេត្តពាក់ព័ន្ធ ត្រូវសម្រេចដោយអនុក្រឹត្យ តាមសំណើរបស់

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ តែបើមានការប៉ះពាល់ដល់ព្រំប្រទល់របស់រាជធានី ខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រីផ្អែកលើសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

១.៣ ប្រវត្តិរដ្ឋបាលសាធារណៈនៅកម្ពុជា

តាមការសិក្សាស្រាវជ្រាវ[12] ប្រទេសកម្ពុជាដែលមានប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានជាយូរណាស់មកហើយ ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននេះ មានការប្រែប្រួលពីរបបនយោបាយមួយទៅរបបនយោបាយមួយទៀតផ្អែកទៅតាមស្ថានភាពនយោបាយ ប្រជាសាស្ត្រ ភូមិសាស្ត្រ សេដ្ឋកិច្ច និងសង្គមនៅក្នុងសម័យកាលនីមួយៗ។

១.៣.១ មុនសម័យបារាំង

ប្រទេសកម្ពុជាដឹកនាំតាមរបបរាជានិយម អំណាចទាំងអស់រួមមាន អំណាចនយោបាយ អំណាចរដ្ឋបាល ស្ថិតនៅក្រោមព្រះមហាក្សត្រ ច្បាប់យកចេញពីគម្ពីវេទ និងទំនៀមទម្លាប់មកប្រតិបត្តិ។ ព្រះមហាក្សត្របានចេញព្រះរាជក្រឹត្យតែក្នុងវិស័យរដ្ឋបាល និងក្នុងនីតិវិធីតុលាការខ្លះប៉ុណ្ណោះ។

១.៣.២ សម័យបារាំង

នៅក្នុងឆ្នាំ១៨៩៧ក្រុមប្រឹក្សារដ្ឋមន្ត្រីមួយបានបង្កើតឡើងដែលរួមមានរដ្ឋមន្ត្រី៥រូប គឺនាយករដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីរាជវាំង រដ្ឋមន្ត្រីយុត្តិធម៌ រដ្ឋមន្ត្រីជើងទឹក និងរដ្ឋមន្ត្រីសឹក។ ក្រុមប្រឹក្សារដ្ឋមន្ត្រីនេះស្ថិតនៅក្រោមការបញ្ជារបស់ប្រេស៊ីដង់ស៊ុបប៉ែរីយើ។ ក្រោយមកបានមានការកែទម្រង់រដ្ឋបាលមួយដ៏សំខាន់នៅពេលដែលមានបញ្ញត្តិរាជវាំង ២១ សីហា ឆ្នាំ១៩០១ បានកំណត់ថា មេស្រុកត្រូវបានតែងតាំងតាមរយៈការបោះឆ្នោតចេញពីបញ្ជីឈ្មោះដែលរៀបចំដោយរេស៊ីដង់ ។ មេស្រុក មានសិទ្ធិជ្រើសរើសជំនួយការរបស់ខ្លួនហៅថា ជំទប់។ មេស្រុកព្រមទាំងជំទប់ និងសមាជិកជ្រើសតាំងពីររូបទៀតបានបង្កើតជាក្រុមប្រឹក្សាស្រុក(Conseil de Srok)។ អង្គការជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យដំបូងគេក្នុងប្រវត្តិសាស្ត្រនេះត្រូវបានរំពឹងថាអាចបំពេញ ភារកិច្ចប្រមូលពន្ធបានល្អ។ ប៉ុន្តែការរំពឹងទុកនេះ មិនបានឆ្លើយតបនិងរយៈពេលវែងឡើយ។ នៅឆ្នាំ១៩០៨ មានការកែទម្រង់រដ្ឋបាលមួយបន្ថែមទៀត។ ស្រុកត្រូវប្រែឈ្មោះជាឃុំ មេស្រុកទៅជាមេឃុំ ពីព្រោះប្រជាជនហាក់ដូចជាមិនចូលចិត្តមេស្រុក ដែលតែងតែប្រមូលពន្ធឱ្យបារាំងនាពេលកន្លងមក។[13]

ព្រឹត្តិការណ៍សំខាន់ៗនៃការកែប្រែរដ្ឋបាលថ្នាក់ក្រោមជាតិមានដូចតទៅ៖

- ឆ្នាំ១៩០១ បារាំងបញ្ចូលគោលការណ៍បោះឆ្នោតជ្រើសរើសមេស្រុក (មេឃុំ)

[12] Organisation de la Commune Cambodgienne, 1919

រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៧១៩៧0, ១៩៧៥, ១៩៨១, ១៩៨៩, ១៩៩៣ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ

[13] បណ្ឌិត សៅ ឡាយ សេចក្តីផ្តើមរដ្ឋបាលសាធារណៈ បោះពុម្ពលើកទី៦ ទំព័រទី៨,៩

- ឆ្នាំ១៩០២ បារាំងឱ្យប្រាក់កម្រៃដល់មេស្រុក និងក្រុមជំនុំ
- ឆ្នាំ១៩០៨ បានប្តូរឈ្មោះស្រុកទៅជាឃុំ ហើយមេស្រុកប្តូរឈ្មោះទៅជាមេឃុំ
- ឆ្នាំ១៩១៩ បារាំងបានប្រគល់ប្រភពធនធានហិរញ្ញវត្ថុឱ្យឃុំជាអ្នកគ្រប់គ្រង និងផ្តល់អំណាចឱ្យមេឃុំជាអ្នករៀបចំអភិវឌ្ឍមូលដ្ឋានឃុំរបស់ខ្លួនផ្ទាល់។
- ឆ្នាំ១៩២៥ រដ្ឋាភិបាលអាណានិគមបារាំងបានផ្តល់ឱ្យមេឃុំនូវអំណាចក្នុងការរៀបចំចាត់ចែងការងារយុត្តាធិការ ការងារគ្រប់គ្រងរដ្ឋបាលឃុំ ការងារហិរញ្ញវត្ថុ ដោយបានកម្រិតអត្រាពន្ធអាករឃុំ។
- ឆ្នាំ១៩៤៣ ប្រទេសមានសង្គ្រាមឈ្លានពានប្រព័ន្ធបោះឆ្នោតនៅឃុំ ត្រូវបានលុបចោលស្ទើរតែទាំងស្រុងដោយបានដាក់ជំនួសនូវការតែងតាំងមេឃុំ និងជំទប់ពីចៅហ្វាយខេត្តដោយមានការយល់ព្រមពី វ៉ែស៊ីដង់។

១.៣.៣ រដ្ឋបាលសាធារណៈ:ចំណេះបង្រៀយសម័យបារាំង

❖ សម័យសង្គមរាស្ត្រនិយម

បន្ទាប់ពីបានទទួលឯករាជ្យពីបារាំងឆ្នាំ១៩៥៣ រួចមកគេបានកត់សម្គាល់ឃើញថាមានការកែទម្រង់ខ្លះលើរដ្ឋបាលឃុំ។ ប៉ុន្តែការបែងចែកដែនដីរដ្ឋបាលទាំងមូលគឺយកតាមក្បើដំណែលរបស់បារាំង ដែនដីទាំងមូលត្រូវបានបែងចែកជាតំបន់រដ្ឋបាល(administration_region) ខេត្ត(province) ស្រុក(districts) ឃុំ សង្កាត់ (kums/Sangkats) និងភូមិ(lamlets) ហើយអំណាចគ្រប់គ្រងប្រទេសទាំងមូលចន្លោះ ឆ្នាំ(១៩៥៣ - ១៩៦៩) គឺតាមបែបរាជានិយមអព្យាក្រឹត្យមិនចូលបក្សសម្ព័ន្ធ។[14] ចាប់ពីឆ្នាំ១៩៥៣ ដល់ ឆ្នាំ១៩៧៤ រដ្ឋបាលឃុំដោយមានការកែទម្រង់ធំៗ ដូចជា៖

- ក្នុងឆ្នាំ១៩៥៩ រដ្ឋាភិបាលសម័យនោះបានបង្កើតឱ្យមានការបោះឆ្នោតជាសកល ដោយផ្ទាល់ និងសម្ងាត់ ជ្រើសរើសមេឃុំ និងក្រុមជំនុំ៖
  - រចនាសម្ព័ន្ធឃុំ គឺ មេឃុំ ជំទប់ និងស្មៀនដែលជាអង្គការប្រតិបត្តិ និងក្រុមជំនុំដែលជាអង្គការនីតិប្បញ្ញត្តិ។
  - ការត្រួតពិនិត្យនីត្យានុកូលភាពរបស់ចៅហ្វាយខេត្តទៅលើការសម្រេចខុសច្បាប់របស់មេឃុំ។
- ចាប់ពីឆ្នាំ១៩៥៣ ដល់ ១៩៧៤ រដ្ឋបាលឃុំ មានការកែទម្រង់ធំៗ ដូចជា៖
  - ឆ្នាំ១៩៦៥ តាមរយៈសមាជជាតិលើកទី២០របស់សង្គមរាស្ត្រនិយម រាជរដ្ឋាភិបាលបានសម្រេចប្តូរឈ្មោះ "ឃុំ" មក "សង្កាត់", "ចៅហ្វាយ" មកជា "អភិបាល"វិញចំពោះរដ្ឋបាលខេត្ត ក្រុង

[14] បណ្ឌិត សៅ ឡាយ សេចក្តីផ្តើមរដ្ឋបាលសាធារណៈ បោះពុម្ពលើកទី៦ ទំព័រ១០

- ឆ្នាំ១៩៦៩រាជរដ្ឋាភិបាលបានសម្រេចកែប្រែច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមជំនុំ ចៅសង្កាត់ជំទប់ ហើយប្រែមកជាការតែងតាំងផ្ទាល់ពីអំណាចកណ្តាលវិញ និងផ្អាកថវិកាឃុំ សង្កាត់ ដោយសារតែវិបត្តិនយោបាយជាបន្តបន្ទាប់។

❖ **សម័យសង្គ្រាម (លន់ នល់ និងប៉ុល ពត)**[15]

- ការធ្វើសមាជជាតិលើកទី២០ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៦៥ ពាក្យ "សង្កាត់" ត្រូវបានចាប់ផ្តើមប្រើប្រាស់សម្រាប់ឃុំនៅក្នុងទីក្រុង។
- នៅក្នុងរបបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ទោះបីបើរដ្ឋធម្មនុញ្ញនាសម័យនោះបានព្យាយាមធ្វើរឹមជ្ឈការនៅគ្រប់ថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិក៏ដោយ ប៉ុន្តែដោយសារតែសង្គ្រាមស៊ីវិលការបោះឆ្នោតគ្រប់ថ្នាក់នៅមូលដ្ឋានមិនអាចដំណើរការបានឡើយ ហើយមេឃុំនៅបន្តតែងតាំងដោយអភិបាលខេត្ត។
- ការរំលត់វិញនូវ របបរឹមជ្ឈការដោយសារតែប្រទេសជាតិជួបភាពវឹកវរក្នុងសម័យសង្គ្រាមគឺសម័យសាធារណរដ្ឋខ្មែរ (សម័យលន់នល់) និងសម័យកម្ពុជាប្រជាធិបតេយ្យ (សម័យប៉ុលពត)
- សម័យកម្ពុជាប្រជាធិបតេយ្យ (សម័យប៉ុលពត) មានការបែងចែកដែនដីជាថ្នាក់មជ្ឈឹម ភូមិភាគ ថ្នាក់តំបន់ និងសហករភូមិ ឃុំ ប៉ុន្តែគ្មានការកំណត់រចនាសម្ព័ន្ធ តួនាទី និងការគ្រប់គ្រងតាមបែបលទ្ធិប្រជាធិបតេយ្យនោះទេ។
- របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រដ្ឋធម្មនុញ្ញនៃរបបនេះមាន ២១មាត្រាប៉ុណ្ណោះ ដែលខ្លឹមសារភាគច្រើនផ្តោតទៅលើអំណាច "យោធា" និង"អង្គការ"។ មាត្រា៩ នៃរដ្ឋធម្មនុញ្ញនេះបានបញ្ញត្តិអំពីរបបដឹកនាំ និងធ្វើការងារជា "របបសមូហភាពដឹកនាំ និងធ្វើការងារ" ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែងរបបនេះមិនបានអនុវត្តទៅតាមរដ្ឋធម្មនុញ្ញ ឬ ច្បាប់អ្វីទាំងអស់។ នៅក្នុងរបបនេះរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល សេដ្ឋកិច្ច និងសង្គមត្រូវបានបំផ្លាញចោលទាំងស្រុង ហើយប្រជាពលរដ្ឋនៅទូទាំងប្រទេសត្រូវបានជម្លៀសទៅធ្វើស្រែចម្ការនៅតាមតំបន់ជនបទ និងរស់នៅប្រមូលផ្តុំរបៀប "សហករណ៍" ក្រោមការដឹកនាំ និងបញ្ជាផ្តាច់ការពី "អង្គការ"។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យប្រជាពលរដ្ឋនៅកម្ពុជាបាត់បង់អាយុជីវិតអស់រាប់លាននាក់ក្នុងរយៈពេលតែប្រមាណជាងបីឆ្នាំនេះប៉ុណ្ណោះ ។ ទន្ទឹមនេះរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងប្រទេសត្រូវបានបំផ្លាញចោលទាំងស្រុង។

[15] ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ក្រសួងមហាផ្ទៃ ខែមករា ឆ្នាំ២០១៩ ទំព័រ៨-៩

❖ **រដ្ឋបាលសាធារណៈ:ទំនើបក្នុងការកសាងប្រទេសឡើងវិញ(រដ្ឋបាលក្រោយ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩)**

ការគ្រប់គ្រងប្រទេសនៅចន្លោះ ឆ្នាំ១៩៨0-១៩៩៣ គឺតាមប្រព័ន្ធសង្គមនិយម (Socialism) អំណាចទាំងអស់គឺស្ថិតនៅលើរដ្ឋាភិបាលកណ្តាលពុំមានការធ្វើវិមជ្ឈការអំណាចទេ ដូច្នេះប្រជាពលរដ្ឋមិនមានសិទ្ធិចូលរួមក្នុងការធ្វើគោលនយោបាយសាធារណៈឡើយ។ ចំណែកឯប្រព័ន្ធរដ្ឋបាលដែនដីដែលជាកេរ្តិ៍ដំណែលពីបារាំងនោះក៏ពុំមានការកែប្រែនោះដែរ[16]។

ចាប់តាំងពី ឆ្នាំ១៩៩៣រហូតមកដល់បច្ចុប្បន្នការគ្រប់គ្រងប្រទេសគឺតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស ហើយគណបក្សដែលជាប់ឆ្នោតជាអ្នកមានសិទ្ធបង្កើតរាជរដ្ឋាភិបាល។ របបដឹកនាំមានលំនាំដូចជា រាជានិយមនៅប្រទេសអង់គ្លេស ព្រះមហាក្សត្រសោយរាជ្យតែមិនកាន់អំណាច ហើយការបែងចែងអំណាចតាមបែបសភានិយម។ ប្រភពដើមនៃលិទ្ធប្រជាធិបតេយ្យនេះ គឺចេញមកពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១។ ការអនុវត្តលទ្ធិប្រជាធិបតេយ្យចាប់ពី ឆ្នាំ១៩៩៣មានការរីកចម្រើនជាបន្តបន្ទាប់ទាំងនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន។

[16] បណ្ឌិត សៅ ឡាយ សេចក្តីផ្តើមរដ្ឋបាលសាធារណៈ បោះពុម្ពលើកទី៦ ទំព័រ១១

ជំពូកទី២
ដំណើរការគ្រប់គ្រងរដ្ឋបាលនៃ
សាលារាជធានីភ្នំពេញ

ជំពូកទី២

ដំណើរការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ

២.១ ទិដ្ឋភាពទូទៅនៃរាជធានីភ្នំពេញ

២.១.១ ប្រវត្តិរាជធានីភ្នំពេញ

រាជធានីភ្នំពេញត្រូវបានសាងសង់ជាលើកដំបូងនៅក្នុង **"សតវត្សរ៍ទី១៥"** ក្នុងអំឡុងរជ្ជកាលព្រះបាទស្រីសុរិយោព័រ (ពញាយ៉ាត) នៅពេលដែលព្រះអង្គបានបោះបង់ចោលរាជធានីអង្គរហើយទ្រង់បានមកសាងសង់រាជធានីថ្មីមួយទៀតនៅទួលបាសានក្នុងខេត្តស្រីសឈរ ដែលសព្វថ្ងៃត្រូវបានគេស្គាល់ថាជាស្រុកស្រីសន្ធរខេត្តកំពង់ចាម ។ ព្រះអង្គបានគង់នៅទីនោះបានតែមួយឆ្នាំគត់ដោយសារតែមានទឹកជំនន់រាល់រដូវវស្សាព្រះអង្គបានផ្លាស់ប្តូររាជធានីហើយបានមកសាងសង់រាជធានីថ្មីមួយទៀតតាមបណ្តោយមាត់ទន្លេចតុមុខ (ទន្លេមុខបួន) នៅក្នុងឆ្នាំ១៤៣៤ ដែលសព្វថ្ងៃជារាជធានីភ្នំពេញ ។

២.១.២ ទីតាំងភូមិសាស្ត្រ

រាជធានីភ្នំពេញ នៅតែក្បាបានអត្តសញ្ញាណទីក្រុងប្រវត្តិសាស្ត្រដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា និងជាមជ្ឈមណ្ឌលប្រមូលផ្តុំលើគ្រប់វិស័យរួមមាន៖ វិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច បេតិកភណ្ឌ វប្បធម៌ ទេសចរណ៍ និងការទូតជាមួយនឹងសន្ទុះនៃការអភិវឌ្ឍយ៉ាងឆាប់រហ័ស។

ជាមួយដំណាក់កាលវិវឌ្ឍប្រវត្តិសាស្ត្រ និងការសម្រិតសម្រាំងផ្នែកនគរូបនីយកម្មរាជធានីភ្នំពេញមានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជាត្រង់ចំណុចប្រសព្វទន្លេចតុមុខរួមមាន៖ ទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់ដែលមានព្រំប្រទល់ភូមិសាស្ត្រហ៊ុមព័ទ្ធដោយខេត្តកណ្តាលគឺ៖

- ខាងកើតទល់នឹងស្រុកខ្សាច់កណ្តាល និងស្រុកល្វាឯម
- ខាងលិចទល់នឹងស្រុកកណ្តាលស្ទឹង និងស្រុកអង្គស្នួល
- ខាងជើងទល់នឹងស្រុកពញាឮ និងស្រុកមុខកំពូល
- ខាងត្បូងទល់នឹងស្រុកកៀនស្វាយ និងក្រុងតាខ្មៅ ។

តារាងទី១៖ ស្ថានភាពគ្រប់គ្រងរដ្ឋបាលដែនដី

ល.រ	ការបរិយាយ	សរុប	ឯកតា
១	ផ្ទៃដីសរុប	៦៩២,៤៦	គីឡូម៉ែត្រការ៉ែ
២	ចំនួនខណ្ឌ	១៤	ខណ្ឌ
៣	ចំនួនសង្កាត់	១០៥	សង្កាត់

៤	ចំនួនភូមិ	៩៥៣	ភូមិ

២.១.៣ ស្ថានភាពប្រជាជន

- ស្ថិតិប្រជាពលរដ្ឋរាជធានីភ្នំពេញដែលបានចុះបញ្ជីស្នាក់នៅ (ជំរឿនប្រជាជនឆ្នាំ២០១៩) មានចំនួន ៤៩៩.២៩៩គ្រួសារប្រជាជនសរុបចំនួន២.២៨១.៩៥១នាក់ (ស្រី ១.១៧៦.២៧៨នាក់)។
- ដោយមានសៀវភៅស្នាក់នៅ (ក២) ចំនួន ៨.៥៧៦គ្រួសារ និងសុំកែតម្រូវបន្ថែមសមាជិកចំនួន ១៧.១៧៧ គ្រួសារសៀវភៅគ្រួសារ(ក៨) ចំនួន ៣.៦៧៨សហព័ទ្ធ និងសុំកែតម្រូវបន្ថែមសមាជិកចំនួន ២.៦២៣ សហព័ទ្ធ និងបានបំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋចំនួន ២៦.៧៧៩ សន្លឹក (ប្រុស ១៣.៦៥៩នាក់) និងចែកជូនប្រជាពលរដ្ឋប្រើប្រាស់បានចំនួន ១៩.៥០៦ សន្លឹក (ប្រុស ៩.៦៧៩នាក់)។
- ស្ថានភាពប្រជាជននៅតាមតំបន់ដែលស្មុគស្មាញក្នុងភូមិសង្កាត់ចំនួន ៤៦៤គោលដៅរកឃើញមនុស្សស្នាក់នៅបណ្តោះអាសន្នចំនួន ២៣.៨៦៦នាក់ (ស្រី ១១.៥៦៣នាក់) ណែនាំឱ្យបំពេញបែបបទស្នាក់នៅត្រឹមត្រូវ និងបានប្រមូលជនអនាថាចំនួន៤នាក់ និងស្ត្រីរកស៊ីផ្លូវភេទចំនួន ៤០នាក់ បញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទារាជធានីភ្នំពេញ។

តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ (ជំរឿនប្រជាជន ឆ្នាំ២០១៩)

ល.រ	ការបរិយាយ	ចំនួន
១	សរុបគ្រួសារ	៤៩៩.២៩៩
២	ប្រជាពលរដ្ឋសរុប	២.២៨១.៩៥១
៣	ប្រជាពលរដ្ឋជាស្ត្រី	១.១៧៦.២៧៨
៤	ទំហំគ្រួសារជាមធ្យម	៤,៤
៥	អត្រាកំណើនប្រចាំឆ្នាំ (២០១៨-២០១៩)	៤,៩%
៦	ដង់ស៊ីតេប្រជាជនក្នុង ១គ.ម^{២}	៣.២៩៥

២.២ ការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ

២.២.១ រចនាសម្ព័ន្ធរដ្ឋបាលសាលារាជធានីភ្នំពេញ

តារាងទី៣៖ រចនាសម្ព័ន្ធរដ្ឋបាលសាលារាជធានីភ្នំពេញ[17]



២.២.២ អំពីក្រុមប្រឹក្សាសាលារាជធានីភ្នំពេញ

ក្រុមប្រឹក្សារាជធានីត្រូវបានបង្កើតឡើងដោយការបោះឆ្នោតស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សា គឺជាតំណាងប្រជាពលរដ្ឋ និងជាអ្នកធ្វើសេចក្តីសម្រេចនានាក្នុងនាមប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានសំដៅបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រុមប្រឹក្សារាជធានីភ្នំពេញមានអាណត្តិ ៥(ប្រាំ)ឆ្នាំហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅ

[17] http://phnompenh.gov.kh/en/about-us/organization-chart/

ថ្ងៃបោះឆ្នោតបន្ទាប់។[18] សមាជិកក្រុមប្រឹក្សាត្រូវជ្រើសរើសដោយការបោះឆ្នោតអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។[19]

ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិក និងប្រធានក្រុមប្រឹក្សាសរុបចំនួន ២៧ (ម្ភៃប្រាំពីរ) រូប។[20]

២.២.២.១ សិទ្ធិអំណាចក្រុមប្រឹក្សារាជធានី

ក្រុមប្រឹក្សារាជធានីមានសិទ្ធិអំណាចពីរគឺ៖

- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ
- សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។[21]

ក្រុមប្រឹក្សារាជធានី ត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួននោះដោយផ្អែកទៅតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ។[22]

ប្រធានក្រុមប្រឹក្សារាជធានី ក្នុងនាមជាក្រុមប្រឹក្សារាជធានីរបស់ខ្លួនមានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលរាជធានីលើ៖

- ដីកា ឬ សេចក្តីសម្រេចដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារាជធានី
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សារាជធានីអនុម័តរួច
- សំណើដកហូតអភិបាល ឬ អភិបាលរងរាជធានីចេញពីមុខតំណែងតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារាជធានី
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សារាជធានី
- ប្រតិទិនប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីសម្រាប់រយៈពេល ១២ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារាជធានី

[18] មាត្រា២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ២០០៨

[19] មាត្រា៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ២០០៨

[20] មាត្រា១ អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣

[21] មាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

[22]មាត្រា៣២ និងមាត្រា៣៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

គណៈអភិបាលរាជធានីត្រូវរៀបចំឯកសារខាងលើនេះត្រូវតែជួយក្រុមប្រឹក្សារាជធានីរបស់ខ្លួន។[23] នៅក្នុងការរៀបចំលើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនឹងសំណើដកហូតអភិបាល ឬ អភិបាលរងរាជធានីចេញពីមុខតំណែង។

២.២.២.២ របៀបរបបការងាររបស់ក្រុមប្រឹក្សារាជធានី

នៅក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សារាជធានីត្រូវតែពិនិត្យពិចារណាទៅលើចំណុចដែលសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានី ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិតាមរយៈដីកា និងសេចក្តីសម្រេចខាងប្រតិបត្តិ ។ រាល់សេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិត្រូវធ្វើឡើងនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារាជធានីរបស់ខ្លួន ហើយត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ[24]
- ក្រុមប្រឹក្សារាជធានី អាចចាត់ឲ្យគណៈកម្មាធិការណាមួយ ឬ មួយចំនួនដែលតម្រូវឲ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត / ក្រុង / ស្រុក / ខណ្ឌ ឬ អាចបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា សេចក្តីសម្រេចតាមការចាំបាច់។ គណៈអភិបាលរាជធានី ត្រូវដឹកនាំនាយករដ្ឋបាលសាលារាជធានី និងទីចាត់ការដែលពាក់ព័ន្ធនៃសាលារាជធានីដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេសដទៃទៀតដល់គណៈកម្មាធិការ ឬ អនុគណៈ កម្មាធិការ ឬ ក្រុមការងារខាងលើព្រមទាំងធ្វើការសម្របសម្រួលណែនាំដល់ទីចាត់ការនានានៃសាលារាជធានី ក្នុងការរៀបចំសេចក្តីព្រាងដីកា សេចក្តីព្រាង សេចក្តីសម្រេចដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានីពិនិត្យ ពិភាក្សា និងអនុម័តលើសពីនេះអភិបាលរាជធានីត្រូវណែនាំនាយករដ្ឋបាលសាលារាជធានីឲ្យរៀបចំដីកា ឬ សេចក្តីសម្រេច ដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួចឱ្យស្របតាមទម្រង់ដែលបានកំណត់ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សារាជធានីចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារាជធានីរបស់ខ្លួន និងត្រូវប្រថាប់ និងការគាំទ្ររដ្ឋបាលរាជធានី[25]

[23] មាត្រា១៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត / ក្រុង / ស្រុក / ខណ្ឌ ឆ្នាំ២០០៨

[24] មាត្រា៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី / ខេត្ត / ក្រុង / ស្រុក / ខណ្ឌ ឆ្នាំ២០០៨

[25] មាត្រា១២នៃអនុក្រឹត្យលេខ២១៥ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

- ក្រុមប្រឹក្សារាជធានី ត្រូវចាត់ឲ្យអភិបាលរាជធានីចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬ សេចក្តីសម្រេច ក្រុមប្រឹក្សារាជធានីដែលបានអនុម័តរួចលើកលែងតែមានការកំណត់ផ្សេងពីនេះព្រមចាត់ចែងឲ្យមានប្រសិទ្ធភាព។[26]

២.២.២.៣ កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានីមានពីរប្រភេទ ៖

- កិច្ចប្រជុំសាមញ្ញ៖ ក្រុមប្រឹក្សារាជធានី ត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន១២ ដងក្នុងមួយឆ្នាំ
- ការប្រជុំវិសាមញ្ញ៖ ក្រុមប្រឹក្សារាជធានី អាចប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានទៅតាមចាំបាច់ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬ ពិសេស។[27] កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី អាចយកជាការបានលុះត្រាតែ កិច្ចប្រជុំទាំងនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី។ សេចក្តីសម្រេចធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ឬ រដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្ត សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

២.២.២.៤ គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី

គណៈកម្មាធិការចំនួនបីរបស់ក្រុមប្រឹក្សារាជធានីរួមមាន៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សារាជធានីអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ ក្រុមប្រឹក្សាអាចតែងតាំងសមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង បុគ្គលិកក្រុមប្រឹក្សាជាសមាជិកគណៈកម្មាធិការបាន។ គណៈកម្មាធិការដែលបង្កើតបន្ថែមមិនត្រូវមានតួនាទីភារកិច្ចត្រួតគ្នាជាមួយនឹង តួនាទី ភារកិច្ចរបស់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើឡើយ។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សារាជធានីអាចបង្កើតនូវអនុគណៈកម្មាធិការ រឺជាក្រុមការងារផ្សេងៗទៀតទៅតាមការស្នើសុំរបស់គណៈកម្មាធិការនានា ឬ គណៈអភិបាលរាជធានី។ អនុគណៈកម្មាធិការ ក្រុមការងារខាងលើនេះត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬ គណៈអភិបាលរាជធានី។

[26] មាត្រា១២នៃអនុក្រឹត្យលេខ២១៥ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[27] មាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យលេខ:២១៥អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

២.២.៣ គណៈអភិបាលរាជធានី

រាជធានី ត្រូវមានគណៈអភិបាលរាជធានីមួយដែលរួមមានអភិបាល និងអភិបាលរងមួយចំនួនដែលត្រូវបានតែងតាំងឡើងស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី/ ខេត្ត/ ក្រុង/ ស្រុក / ខណ្ឌ ។[28] អភិបាលរាជធានី អភិបាលរងមិនមែនជាសមាជិកក្រុមប្រឹក្សារាជធានីឡើយ។ គណៈអភិបាលរាជធានី មានសមាជិកប្រាំពីរ (០៧)រូប និងមានអាណត្តិការងារបួន (០៤)ឆ្នាំ។

អភិបាលរាជធានីភ្នំពេញ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើររបស់នាយករដ្ឋមន្ត្រី តាមសេចក្តីសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលរងរាជធានីភ្នំពេញ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

គណៈអភិបាល ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃដែលមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរស័ក្តិឧត្តមមន្ត្រី
- មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំ ឡើងគិតដល់ថ្ងៃតែងតាំង ព្រមទាំងមានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ និងមានបរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។[29]

២.២.៣.១ តួនាទីគណៈអភិបាលរាជធានី

- គណៈអភិបាលមានតួនាទី ភារកិច្ចច្បងៗ ដូចខាងក្រោម៖[30]

ធ្វើការសិក្សាស្រាវជ្រាវដើម្បីបានផ្តល់យោបល់ជូនទៅក្រុមប្រឹក្សាអំពីកិច្ចការនានាដែលពាក់ព័ន្ធ និងសិទ្ធិអំណាចខាងបញ្ញត្តិ និងសិទ្ធិអំណាចខាងប្រតិបត្តិដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

[28] មាត្រា២៥នៃអនុក្រឹត្យលេខ ២១៥អនក្រ ប.ក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលល្អនៃរាជធានីភ្នំពេញ

[29] មាត្រា១៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខ នស/រកម/០៥០៨/០១៧ ២២ ឧសភា ២០០៨

[30] ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ក្រសួងមហាផ្ទៃ ខែមករា ឆ្នាំ២០១៩ ទំព័រ៤០-៤១

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬ បានផ្ទេរមកឲ្យក្រុមប្រឹក្សា និងអំពីរបៀបរបបបែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានដើម្បីទទួលយកមុខងារភារកិច្ច និងធនធានដែលបានប្រគល់ ឬ បានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគ បីឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំគម្រោងថវិកាប្រចាំឆ្នាំ
- ការបង្កើតការកែសម្រួល ឬ ការរំសាយទីចាត់ការ ឬ ការិយាល័យនានា ការរៀបចំតួនាទីភារកិច្ច លក្ខខណ្ឌការងាររបស់បុគ្គលិក ការតែងតាំងការដំឡើងថ្នាក់ឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើសការតែងតាំង ការកំណត់ប្រាក់បៀវត្សកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សា ព្រមទាំងការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារតាមការចាំបាច់ដើម្បីរួមចំណែកជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សា
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណជនដូចជាការរៀបចំការព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយ ផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច និងកិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន
- សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅរាជធានីទៅរដ្ឋមន្ត្រី ប្រធានស្ថាប័នសាមី ត្រូវដាក់ជូនអភិបាលរាជធានីដើម្បីពិនិត្យ និងផ្តល់យោបល់ជាមុន។ ប្រសិនបើឯកភាព អភិបាលរាជធានីត្រូវចុះហត្ថលេខាលើរបាយការណ៍នេះជាមួយប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់មន្ទីរអង្គភាពនិងទីភ្នាក់ងារនានារបស់ ក្រសួងស្ថាប័នប្រចាំនៅរាជធានីត្រូវចម្លងជូនសាលារាជធានី។

២.២.៣.២ របៀបរបបការងារគណៈអភិបាលរាជធានី

ក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន គណៈអភិបាលរាជធានី អភិបាលរាជធានី អភិបាលរងរាជធានី ត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលរាជធានីត្រូវគោរពតាមនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានាស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់អភិបាលរាជធានីត្រូវតែយកការងារទាំងនោះ ពិគ្រោះពិភាក្សានៅក្នុងគណៈអភិបាលរាជធានីរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេច និងគោលការណ៍ណែនាំក្រុមប្រឹក្សារាជធានីរបស់ខ្លួន
- អភិបាលរាជធានីត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សារាជធានី អំពីសកម្មភាព ការងារទាំងអស់របស់គណៈអភិបាលរាជធានី អភិបាលរងរាជធានី ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលរាជធានីលើភារកិច្ចនានាដែលបានប្រគល់ហើយត្រូវរួមជាមួយអភិបាលរាជធានីក្នុងការទទួលខុសត្រូវអំពីការសម្រេច និង សកម្មភាពក្នុងគណៈអភិបាលរាជធានីរបស់ខ្លួន
- គណៈអភិបាលរាជធានី ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលរាជធានី និងអភិបាលរងរាជធានីហើយសុំការសម្រេចពីក្រុមប្រឹក្សារាជធានីរបស់ខ្លួន
- អភិបាលរាជធានី ត្រូវចុះហត្ថលេខាទៅលើលិខិតស្នាមរដ្ឋបាល សម្រាប់ចាត់ចែងការងារប្រចាំថ្ងៃដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារាជធានីរបស់ខ្លួនលើកលែង លិខិតបទដ្ឋានដែលតម្រូវឲ្យប្រធានក្រុមប្រឹក្សារាជធានីចុះហត្ថលេខានៅក្នុងនាមក្រុមប្រឹក្សារាជធានីរបស់ខ្លួន
- អភិបាលរាជធានី អាចប្រគល់សិទ្ធិដល់អភិបាលរង នៅក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួននៅក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងនីមួយៗ
- អភិបាលរាជធានី ត្រូវទទួលខុសត្រូវអំពីនីត្យានុកូលភាព នីតិវិធី ចំពោះឯកសារ លិខិតស្នាមឲ្យបានត្រឹមត្រូវតាមច្បាប់បែបបទប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងរាជធានីទាំងនោះ
- គណៈអភិបាលរាជធានី អភិបាលរាជធានី ឬ អភិបាលរងរាជធានីដែលបានសម្រេច ឬ ដែលបានអនុវត្តកិច្ចការណាមួយផ្ទុយទៅនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា កិច្ចការណាដែលស្ថិតក្នុង

សមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានីហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សារាជធានី ការសម្រេចសកម្មភាព នោះពុំមានសុពលភាពឡើយ គណៈអភិបាលរាជធានី អភិបាលរាជធានី ឬ អភិបាលរងរាជធានីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬ សកម្មភាពទាំងនេះ ។

២.២.៤ ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី

នៅក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីមានដូចខាងក្រោម៖

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សារាជធានីបានសម្រេចរួចហើយ គណៈអភិបាលរាជធានីត្រូវទទួលខុសត្រូវនៅក្នុងការចាត់ចែង អនុវត្តក្នុងនាមក្រុមប្រឹក្សារាជធានីរបស់ខ្លួន។[31]ដូច្នេះ គណៈអភិបាលរាជធានី គឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សារាជធានី
- ក្រុមប្រឹក្សារាជធានី ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលរាជធានី ដើម្បីធានាថាគណៈអភិបាលរាជធានី អនុវត្តកិច្ចការ ទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សារាជធានី[32]
- គណៈអភិបាលរាជធានី ត្រូវធ្វើសេចក្តីរាយការណ៍ ជូនក្រុមប្រឹក្សារាជធានីរបស់ខ្លួន រៀងរាល់កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារាជធានីរបស់ខ្លួនអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សារាជធានី និងចាំបាច់ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា[33]
- ក្រុមប្រឹក្សារាជធានីត្រូវធ្វើប្រតិភូកម្មទៅដល់ គណៈអភិបាលរាជធានីដើម្បីពិនិត្យនីត្យានុកូលភាពដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខណ្ឌ។[34]

---

[31] មាត្រា១០ មាត្រា២៧ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[32]មាត្រា១៧ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[33]មាត្រា២៧ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[34] មាត្រា១២ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

ក្រៅពីទំនាក់ទំនងនានាដូចដែលបានរៀបរាប់ខាងលើនេះទំនាក់ទំនងរវាង ក្រុមប្រឹក្សារាជធានី និង គណៈអភិបាលរាជធានីក៏បានកំណត់ក្នុងតួនាទីភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានីផងដែរ។

២.២.៥ នាយករដ្ឋបាលរាជធានីភ្នំពេញ

នាយករដ្ឋបាលមានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។ក្នុងតួនាទីខាងលើនេះនាយករដ្ឋបាលត្រូវធ្វើសេចក្តីរាយការណ៍ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។[35]
នាយករដ្ឋបាលមានតួនាទីភារកិច្ចដូចខាងក្រោម៖

- អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ធានាឱ្យអង្គភាពបុគ្គលិកក្រុមប្រឹក្សាអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន
- អនុវត្តដីការបស់ក្រុមប្រឹក្សា
- ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា អភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ
- ផ្តល់យោបល់ទៅដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងនៅក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពទៅដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ផ្តល់យោបល់ទៅគណៈអភិបាលដើម្បីគណៈអភិបាលបានអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។[36]

២.២.៦ ទីចាត់ការ និងការិយាល័យចំណុះ

សាលារាជធានី គឺជាកន្លែងធ្វើការរបស់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីដែលត្រូវបើកធ្វើការឲ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ។ ក្នុងអំឡុងពេលម៉ោងធ្វើការងារប្រជាពលរដ្ឋមានសិទ្ធិ៖

- ធ្វើទំនាក់ទំនង និងធ្វើការងារជាមួយក្រុមប្រឹក្សារាជធានី និងគណៈអភិបាលទទួលព័ត៌មានអំពីសំណើ និងការងារនានាពីរដ្ឋបាលរាជធានីចូលរួមយោបល់ ឬ សំណូមពរលើបញ្ហាណាមួយ។

[35]មាត្រា ១៨៤នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខ នស/រកម/០៥០៨/០១៧ ២២ ឧសភា ២០០៨
[36] មាត្រា ១៨៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខ នស/រកម/០៥០៨/០១៧ ២២ ឧសភា ២០០៨

- នៅចន្លោះម៉ោងធ្វើការ ឬ ថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីត្រូវធានាឱ្យមានមន្ត្រីបុគ្គលិកនៃរដ្ឋបាលរបស់ខ្លួនក្នុងចំនួនសមស្របប្រចាំការដើម្បីទទួល ឬ ដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា។[37]

រដ្ឋបាលរាជធានី ត្រូវតែជាម្ចាស់ក្នុងការទទួលខុសត្រូវ ចាត់ចែងទៅលើរាល់លិខិតស្នាមឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវឲ្យស្របតាមច្បាប់ជាធរមាន។

រដ្ឋបាលរាជធានីក៏ជាម្ចាស់ និងទទួលខុសត្រូវលើរាល់លិខិតស្នាមឯកសារនានាដែលបានរៀបចំឡើងដោយក្រុមប្រឹក្សារាជធានី ក្នុងនាមក្រុមប្រឹក្សារាជធានី និងដោយគណៈអភិបាលរាជធានីនៅក្នុងនាមរដ្ឋព្រមទាំងជាម្ចាស់លើឧបករណ៍ មធ្យោបាយ និងសម្ភារនានានៃរដ្ឋបាលរបស់ខ្លួន ដូច្នេះរដ្ឋបាលរាជធានីត្រូវទុកដាក់រាល់ឯកសារ លិខិតស្នាម ឧបករណ៍ មធ្យោបាយ និងសម្ភារនានានៃរដ្ឋបាលរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមការកំណត់មានសណ្តាប់ធ្នាប់ល្អ និងគង់វង្ស។[38]

ចំពោះត្រារដ្ឋបាលរាជធានី ត្រូវបានប្រគល់ឲ្យនាយករដ្ឋបាលដើម្បីទទួលខុសត្រូវ និងគ្រប់គ្រងសម្រាប់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានីប្រើប្រាស់។[39]

រដ្ឋបាលរាជធានី ត្រូវរៀបចំឲ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលារាជធានីដែលសាធារណៈជនអាចពិនិត្យមើលបានដោយងាយស្រួល។ ក្តារព័ត៌មានសាធារណៈនេះត្រូវសរសេរ ឬ បិទផ្សាយនេះត្រូវរក្សាទុកឲ្យបានយ៉ាងតិចដប់ថ្ងៃ។

ក្រៅពីក្តារព័ត៌មានសារធាណៈ នៅទីសាធារណៈសមស្របដើម្បីបិទផ្សាយព័ត៌មានជារួមគ្នារវាងរាជធានី ខណ្ឌ និងសង្កាត់ដែលពាក់ព័ន្ធ។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សារាជធានីត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ... ដើម្បីជូនដំណឹងអំពីកិច្ចការនានារដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ។[40]

[37]មាត្រា៥០ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[38]មាត្រា៥២ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[39]មាត្រា៥៣ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[40]មាត្រា៥៤ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

២.២.៦.១ ទីចាត់ការ

- សាលារាជធានី ត្រូវមានទីចាត់ការចំណុះចាំបាច់ដូចខាងក្រោម៖
  - ទីចាត់ការរដ្ឋបាល
  - ទីចាត់ការផែនការ និងវិនិយោគ
  - ទីចាត់ការហិរញ្ញវត្ថុ
  - ទីចាត់ការរៀបចំក្រុង
  - ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
  - ទីចាត់ការអន្តរវិស័យ
  - ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស
  - ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់។

ទីចាត់ការនីមួយៗត្រូវតែស្ថិតក្រោមការទទួលខុសត្រូវត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់នាយកទីចាត់ការមួយរូបដោយមាននាយករងទីចាត់ការយ៉ាងច្រើនរូបជាជំនួយការផ្ទាល់។ នាយក ទីចាត់ការនីមួយៗទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល។ ទីចាត់ការនីមួយៗត្រូវតែមានការិយាល័យចំណុះមួយចំនួន ។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយរូប និងមានអនុប្រធានការិយាល័យយ៉ាងច្រើនពីររូបជាជំនួយការ។

លក្ខខណ្ឌនៃការតែងតាំង /នាយកទីចាត់ការ/ នាយករងទីចាត់/ ប្រធានការិយាល័យ/ អនុប្រធានការិយាល័យ និងមន្ត្រីរាជការនិងបុគ្គលិកនៅក្នុងទីចាត់ការនីមួយៗ ត្រូវផ្អែកតាមលក្ខន្តិក:ដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

២.២.៦.២ របៀបរបបការងាររបស់ទីចាត់ការ និងការិយាល័យចំណុះ

ក្នុងការគ្រប់គ្រងចាត់ចែងការអនុវត្តតួនាទី និងភារកិច្ចរបស់ ទីចាត់ការ និងការិយាល័យនីមួយៗក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី នាយករដ្ឋបាលរាជធានី នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានការិយាល័យ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវពិចារណាលើរបៀបរបបធ្វើការងារដូចខាងក្រោម៖

- ទីចាត់ការនីមួយៗ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់នាយកទីចាត់ការ នាយកទីចាត់ការនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់

ចំពោះនាយករដ្ឋបាល នាយករដ្ឋបាលត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះគណៈអភិបាលរាជធានី អភិបាលរាជធានី និងក្រុមប្រឹក្សារាជធានីរបស់ខ្លួន[41]

- ការិយាល័យនីមួយៗត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានការិយាល័យ ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយកទីចាត់ការរបស់ខ្លួន និងនាយករដ្ឋបាលសាលារាជធានី
- នាយករដ្ឋបាលសាលារាជធានី ដោយមានទីចាត់ការគ្រប់គ្រងធនធានមនុស្សជាសេនាធិការត្រូវដឹកនាំ សម្របសម្រួលទីចាត់ការនានានៃសាលារាជធានី នៅក្នុងការរៀបចំកំណត់អំពីនីតិវិធីរដ្ឋបាលសម្រាប់ទីចាត់ការ និងការិយាល័យចំណុះទីចាត់ការនីមួយៗព្រមទាំងការរៀបចំកំណត់អំពីលក្ខខណ្ឌការងាររបស់នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិកទាំងអស់នៅតាម ការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីដើម្បីដាក់ជូន គណៈអភិបាលរាជធានី និងក្រុមប្រឹក្សារាជធានីពិនិត្យសម្រេច[42]
- នាយករដ្ឋបាលដោយមានទីចាត់ការហិរញ្ញវត្ថុ ដែលជាសេនាធិការត្រូវតែរៀបចំកំណត់អំពីនីតិវិធីហិរញ្ញវត្ថុ ការប្រើប្រាស់សម្ភារ ថវិកា សម្រាប់ទីចាត់ការ និងការិយាល័យនានានៃសាលារាជធានីដើម្បីដាក់ជូនគណៈអភិបាលរាជធានី និងក្រុមប្រឹក្សារាជធានីពិនិត្យ និងសម្រេច
- នីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងាររបស់មន្ត្រីបុគ្គលិកត្រូវចុះហត្ថលេខាពីអភិបាលរាជធានី
- គណៈអភិបាលរាជធានីត្រូវដឹកនាំនាយករដ្ឋបាលដើម្បីតាមដានត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំអំពីការអនុវត្តនូវនីតិវិធីរដ្ឋបាល នីតិវិធីហិញ្ញវត្ថុ និងលក្ខខណ្ឌការងារដែលបានកំណត់ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សារាជធានីរបស់ខ្លួន
- គ្រប់កិច្ចការនានា ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន គណៈអភិបាលរាជធានី ត្រូវដឹកនាំណែនាំដល់នាយករដ្ឋបាល ការប្រគល់កិច្ចការដល់ទីចាត់ការ និងការិយាល័យដែលទទួលខុសត្រូវការងារនីមួយៗដើម្បីសិក្សាស្រាវជ្រាវ លើកយោបល់ដោយតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានជាធរមាន នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ រួចបញ្ជូនមកនាយករដ្ឋបាលដើម្បីបញ្ជូនទៅអភិបាលរងទទួលបន្ទុក

[41]ប្រការ១៣នៃប្រកាសលេខ៤២៧៣.ប្រក ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

[42]ប្រការ១៥ នៃប្រកាសលេខ៤២៧៣.ប្រក ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

លើការងារវិស័យនីមួយៗពិនិត្យ និងផ្តល់យោបល់មុនដាក់ជូនអភិបាលរាជធានីពិនិត្យសម្រេចស្រប តាមបែបបទនីតិវិធី និងសមត្ថកិច្ចរបស់ខ្លួន[43]

- នាយកទីចាត់ការ និងប្រធានការិយាល័យនានាត្រូវធានាចាត់ចែងមន្ត្រី និងបុគ្គលិកក្នុងការិយាល័យ នីមួយៗដើម្បីអនុវត្តការងារដោយផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងផ្អែកតាមនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងារ
- នាយករដ្ឋបាល ត្រូវកំណត់ឲ្យមានរបបប្រជុំជាមួយនាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ និង ប្រធាន អនុប្រធានការិយាល័យចំណុះសាលារាជធានី។ នាយកទីចាត់ការនីមួយៗ ត្រូវកំណត់ឲ្យ មានរបបប្រជុំជាមួយប្រធាន អនុប្រធាន ការិយាល័យចំណុះ កិច្ចប្រជុំទាំងនេះ គឺជាការរួមគ្នាដើម្បី ពិនិត្យអំពីលទ្ធផលការងា រភាពរីកចម្រើន ឬ បញ្ហាប្រឈមនានាដើម្បីលើកទិសដៅ វិធានការ ឬ ស្នើ សុំយោបល់ថ្នាក់ដឹកនាំតាមឋានានុក្រមពិនិត្យ និងដោះស្រាយ
- គណៈអភិបាលត្រូវដឹកនាំណែនាំដល់នាយករដ្ឋបាលក្នុងការរៀបចំផែនការកម្មវិធីបណ្តុះបណ្តាល និង កសាងសមត្ថភាពដល់នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធាន ការិយាល័យ និងមន្ត្រី បុគ្គលិកទាំងអស់ពីជំនាញវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ព្រមទាំងតួនាទីភារកិច្ច នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខណ្ឌការងាររបស់មន្ត្រីបុគ្គលិកសំដៅលើកកម្ពស់ប្រសិទ្ធភាពការងារក្នុង សាលារាជធានី។[44]

២.២.៧ ទំនាក់ទំនងរវាងរាជធានីជាមួយខណ្ឌ សង្កាត់ និងស្ថាប័នឆានា

❖ ទំនាក់ទំនងរវាងរាជធានី ជាមួយខណ្ឌ

- រដ្ឋបាលរាជធានី រដ្ឋបាលខណ្ឌមានទំនាក់ទំនងមួយចំនួនទៀតដូចខាងក្រោម៖ ក្រុមប្រឹក្សាខណ្ឌត្រូវ ស្ថិតនៅក្រោមការពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី[45]

[43]ប្រការ១៦ នៃប្រកាសលេខ៤២៧៣.ប្រក ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យ នៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

[44]ប្រការ១៨ នៃប្រកាសលេខ៤២៧៣.ប្រក ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យ នៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

[45]មាត្រា១៥ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

- ក្រុមប្រឹក្សារាជធានីត្រូវធានាធ្វើប្រតិភូកម្មនូវមុខងារ និងភារកិច្ចសមស្របដល់ក្រុមប្រឹក្សាខណ្ឌ។[46] ដើម្បីឲ្យក្រុមប្រឹក្សាខណ្ឌនីមួយៗលើកកម្ពស់លើការចូលរួម និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋសំដៅបង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមខណ្ឌនីមួយៗ
- ក្រុមប្រឹក្សាខណ្ឌត្រូវអនុវត្តមុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានីបានធ្វើ ប្រតិភូកម្ម និងត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ និងចំពោះក្រុមប្រឹក្សាសង្កាត់នានាក្នុងខណ្ឌរបស់ខ្លួន និងត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារាជធានីអំពីភាពត្រឹមត្រូវតាមច្បាប់នៃការអនុវត្តមុខងារ និងភារកិច្ចដែលបានធ្វើប្រតិភូកម្មទាំងនេះ
- គណៈអភិបាលរាជធានី ត្រូវធានាឱ្យទៅដល់គណៈអភិបាលខណ្ឌនីមួយៗនៃរាជធានីធ្វើកិច្ចសហ-ប្រតិបត្តិការជាមួយគ្នា ដើម្បីរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ គោរពសិទ្ធិមនុស្ស និងការគោរពច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់រាជធានី[47]
- ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធានាផ្តល់មធ្យបាយ សម្ភារៈ ធនធាននានា រួមទាំងធនធានហិរញ្ញវត្ថុ ធនធាន មនុស្ស និងការបណ្តុះបណ្តាល ការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ ក្រុមប្រឹក្សាទាំងនេះ ដើម្បីអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សារាជធានីទៅក្រុមប្រឹក្សាខណ្ឌ និងសង្កាត់ក្នុងរាជធានី ។ ក្រុមប្រឹក្សារាជធានីត្រូវធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃការអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មឱ្យខណ្ឌ ដើម្បីធានាថាខណ្ឌអនុវត្តមុខងារ ភារកិច្ចទាំងនោះ ក្នុងក្របខ័ណ្ឌនៃការងារដែលបានធ្វើប្រតិភូកម្មឱ្យលើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងធានាថាខណ្ឌឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យនីត្យានុកូលភាពខាងលើនេះ។ ក្រុមប្រឹក្សាខណ្ឌ ត្រូវធ្វើការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីធានាថាក្រុមប្រឹក្សាសង្កាត់អនុវត្តមុខងារ ភារកិច្ច ក្នុងក្របខ័ណ្ឌនៃអំណាចដែលបានធ្វើប្រតិភូកម្មឱ្យលើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថាក្រុមប្រឹក្សាសង្កាត់បានអនុវត្តមុខងារ ភារកិច្ចនេះក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

[46]មាត្រា១១៨ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[47]មាត្រា១២១ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

❖ **ទំនាក់ទំនងរវាងរាជធានីជាមួយសង្កាត់**

រដ្ឋបាលរាជធានី និងរដ្ឋបាលសង្កាត់មានទំនាក់ទំនងគ្នាដូចខាងក្រោម៖ ក្រុមប្រឹក្សាសង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី[48]

- ក្រុមប្រឹក្សារាជធានីត្រូវតែធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃការអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មឲ្យសង្កាត់ដើម្បីធានាថាសង្កាត់អនុវត្តមុខងារ និងភារកិច្ចទាំងនោះក្នុងក្របខណ្ឌនៃការងារដែលបានធ្វើប្រតិភូកម្មឲ្យលើមូលដ្ឋានក្នុងការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងធានាបានថាសង្កាត់ឆ្លើយតបបានយ៉ាងល្អប្រសើរនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញគោលការណ៍ណែនាំស្តីអំពីការត្រួតពិនិត្យនីត្យានុកូលភាពខាងលើនេះ
- ក្រុមប្រឹក្សាបានលើកកម្ពស់នៅក្នុងការបង្កើតការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាសង្កាត់ត្រូវទទួលខុសត្រូវ៖
  - ផ្តល់យោបល់ និងពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារាជធានីដើម្បីធានាថាក្រុមប្រឹក្សា នៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋ
  - ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សារាជធានីអំពីតម្រូវការនានា របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមាន
  - អនុវត្តមុខងារ និងភារកិច្ចដែលក្រុមប្រឹក្សារាជធានីបានធ្វើប្រតិភូកម្មឲ្យធ្វើសហប្រតិបត្តិការ ឱ្យបានពេញលេញជាមួយ និងក្រុមប្រឹក្សារាជធានីនៅក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ។[49]
- ក្រុមប្រឹក្សាត្រូវធានាធ្វើប្រតិភូកម្មឲ្យបានសមស្របនូវមុខងារ និងកិច្ចការដល់ក្រុមប្រឹក្សាសង្កាត់ដែលស្ថិតក្នុងរាជធានីរបស់ខ្លួន ដើម្បីធានាឲ្យក្រុមប្រឹក្សាសង្កាត់មានលទ្ធភាពកាន់តែច្រើនថែមទៀតនៅក្នុងការបង្កើត ការជំរុញ និងការធ្វើឲ្យមានចីរភាពទៅដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យទៅដល់ប្រជាពលរដ្ឋនៅតាមសង្កាត់នីមួយៗ

[48]មាត្រា១១៥ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[49]មាត្រា១១៦ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

- មុខងារ និងភារកិច្ចដែលក្រុមប្រឹក្សាត្រូវធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់គឺជា មុខងារ ភារកិច្ចដែលមានការពាក់ព័ន្ធដោយផ្ទាល់ទៅដល់ការផ្តល់សេវាកម្ម និងសេចក្តីត្រូវការនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតាមសង្កាត់នីមួយៗ

❖ **ទំនាក់ទំនងរវាងរាជធានី ជាមួយស្ថាប័ននានា**

ទំនាក់ទំនងរវាងរដ្ឋបាលរាជធានីជាមួយក្រសួងស្ថាប័នរួមមាន ៖

- ក្រុមប្រឹក្សារាជធានីត្រូវស្ថិតក្នុងក្របខណ្ឌអំណាចប្រតិបត្តិរបស់ជាតិ[50]
- ក្នុងក្របខណ្ឌនៃអំណាចនីតិប្រតិបត្តិរបស់ជាតិ រាជរដ្ឋាភិបាលមានសិទ្ធិណែនាំនិងត្រួតពិនិត្យនីត្យានុកូលភាពនៃការសម្រេច និងការធ្វើសកម្មភាពរបស់ក្រុមប្រឹក្សារាជធានីដើម្បីធានាឲ្យបានថាក្រុមប្រឹក្សាគោរពយ៉ាងត្រឹមត្រូវនូវ រដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយជាតិ[51]
- ក្រសួងស្ថាប័ននានាដែលអាចធ្វើទំនាក់ទំនង និងកិច្ចសហការដោយផ្ទាល់ជាមួយ និងរដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់ តាមការចាំបាច់ក៏ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលរាជធានី[52]
- ក្រសួងស្ថាប័នត្រូវធ្វើការប្រគល់ និងធ្វើប្រតិភូកម្មមុខងារភារកិច្ចសមស្របដោយភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ បុគ្គលិក និងសមត្ថកិច្ចឲ្យក្រុមប្រឹក្សារាជធានីស្របតាមច្បាប់ និងបទបញ្ជាគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍទៅតាមបែបប្រជាធិបតេយ្យនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងការរៀបចំនូវគោលការណ៍ណែនាំគាំទ្រដល់ក្រុមប្រឹក្សារាជធានីនៅក្នុងការរៀបចំនូវប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា។

[50]មាត្រា១៣២ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[51]មាត្រា១៣៤ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

[52]មាត្រា១៣៨ នៃអនុក្រឹត្យលេខ២១៥អនក្រ .បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

ជំពូកទី៣
សមិទ្ធផលការងារសម្រេចបាន
របស់រដ្ឋបាលសាលារាជធានី
ភ្នំពេញ ឆ្នាំ២០២០

ជំពូកទី៣

សមិទ្ធផលការងារសម្រេចបានរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ ឆ្នាំ២០២០

៣.១ ការគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ

បរិយាយអំពីលទ្ធផលនៃការអនុវត្តការងាររដ្ឋបាល ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ផែនការ និងការគាំទ្រមូលដ្ឋាន ការគ្រប់គ្រងធនធានមនុស្ស ការងារអន្តរវិស័យ ការងារហិរញ្ញវត្ថុ ការងារលទ្ធកម្ម ការងារអង្គភាពច្រកចេញចូលតែមួយ ការងាររដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុង និងការងារការិយាល័យប្រជាពលរដ្ឋ។

៣.១.១ ការងាររដ្ឋបាល

- ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

  បានទទួលលិខិត និងឯកសារផ្សេងៗពីក្រសួង មន្ទីរ និងអង្គភាពនានា សរុបចំនួន ២៣.៩០៨ច្បាប់។

តារាងទី៤៖ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

ល.រ	ការបរិយាយ	ចំនួន
១	ដីកាដែលបានដាក់ចេញ	១៥១
២	សេចក្តីសម្រេចដែលបានដាក់ចេញ	៤០៥
៣	លិខិតរដ្ឋបាលដែលបានដាក់ចេញ	២៣.៩៩០
៤	លិខិតចូល	២៣.៩០៨
៥	សៀវភៅគ្រួសារ	៣.៦៧៨
៦	អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ	២៦.៧៧៩

- **ការគ្រប់គ្រងប្រជាពលរដ្ឋ**[53]
  - ស្ថិតិប្រជាពលរដ្ឋរាជធានីភ្នំពេញ ដែលបានចុះបញ្ជីស្នាក់នៅ (ជំរឿនប្រជាជនឆ្នាំ២០១៩)មានចំនួន ៤៩៩.២៩៩គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ២.២៨១.៩៥១នាក់ (ស្រី ១.១៧៦.២៧៨នាក់)។
  - បានផ្តល់សៀវភៅស្នាក់នៅ (ក២) ចំនួន ៨.៥៧៦គ្រួសារ និងសុំកែតម្រូវបន្ថែមសមាជិកចំនួន១៧.១៧៧ គ្រួសារសៀវភៅគ្រួសារ(ក៨) ចំនួន ៣.៦៧៨សហព័ទ្ធ និងសុំកែតម្រូវបន្ថែមសមាជិកចំនួន ២.៦២៣ សហព័ទ្ធ និងបានបំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋចំនួន ២៦.៧៧៩

[53] របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០២០

សន្លឹក (ប្រុស ១៣.៦៥៩នាក់) និងចែកជូនប្រជាពលរដ្ឋប្រើប្រាស់ បានចំនួន ១៩.៥០៦សន្លឹក (ប្រុស ៩.៦៧៩នាក់)។

- បានដឹកនាំត្រួតពិនិត្យរដ្ឋបាលនៅតំបន់ស្មុគស្មាញនៅក្នុងភូមិ សង្កាត់ចំនួន ៤៦៤គោលដៅ រកឃើញមនុស្សស្នាក់នៅបណ្តោះអាសន្នចំនួន ២៣.៨៦៦នាក់ (ស្រី ១១.៥៦៣នាក់) ណែនាំឱ្យបំពេញបែបបទស្នាក់នៅត្រឹមត្រូវ និងបានប្រមូលជនអនាថាចំនួន៤នាក់ និងស្ត្រីរកស៊ីផ្លូវភេទចំនួន ៤០នាក់ បញ្ជូនទៅមន្ទីរសង្គមកិច្ចអតីតយុវជន និងយុវនីតិសម្បទារាជធានីភ្នំពេញ។

- **ការងារអត្រានុកូលដ្ឋាន**

- ប្រជាពលរដ្ឋដែលបានមកចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំឆ្នាំ២០២០ បានចំនួន ៦៦.១១១ នាក់ (ស្រី ៣២.១៤៧នាក់) ក្នុងនោះ សំបុត្រកំណើត ចំនួន ២១.៥១១នាក់ (ស្រី ១០.៣៤១នាក់) បញ្ជាក់កំណើត ចំនួន១៥.៩៤៥នាក់ (ស្រី ៧.៧១៤នាក់) មរណភាព ចំនួន៤.៧៤១នាក់ (ស្រី ២.១៦២នាក់) អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងខ្មែរចំនួន ១១.៧២០គូ រវាងខ្មែរ និងបរទេសចំនួន ១៨០គូ ព្រមទាំងបានចុះបញ្ជីកំណើតជនបរទេសចំនួន ៣៧នាក់ បញ្ជីអាពាហ៍ពិពាហ៍បរទេស និងបរទេសចំនួន ២៤គូ និងបញ្ជីមរណភាពជនបរទេសចំនួន ២៩នាក់។

- **ការផ្សព្វផ្សាយព័ត៌មាន**

តារាងទី៥៖ ការផ្សព្វផ្សាយព័ត៌មាន

ល.រ	ការបរិយាយ	ចំនួន
១	វិទ្យុ	១១.០៤៦ អត្ថបទ
២	ទូរទស្សន៍	១០.០៣៩ អត្ថបទ
៣	បិទផ្សាយលើក្តារព័ត៌មានសាធារណៈ	១.០៨០ សន្លឹក
៤	ផ្សេងៗ (ការផ្សព្វផ្សាយព័ត៌មាន និងប្រតិកម្មរហ័សដែលមានផេកអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ផេករដ្ឋបាលរាជធានីភ្នំពេញ និងគេហទំព័ររដ្ឋបាលរាជធានីភ្នំពេញ)	១១៧ អត្ថបទ

៣.១.២ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ

បានទទួលលិខិតពីបណ្តាក្រសួង ស្ថាប័ន មន្ទីរពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិចំនួន ៤៣០លិខិត បានរៀបចំទំនាក់ទំនងសម្របសម្រួលរៀបចំកម្មវិធីជូនថ្នាក់ដឹកនាំសាលារាជធានីភ្នំពេញ រួមមាន៖

ការជួបសម្តែងការគួរសម និងជួបប្រជុំពិភាក្សាការងាររបស់គណៈប្រតិភូជាតិ និងគណៈប្រតិភូអន្តរជាតិ បានចំនួន ១.៧២២លើក ព្រមទាំងបានសហការ និងសម្របសម្រួលក្នុងការអនុវត្តគម្រោងសហប្រតិបត្តិការអន្តរជាតិនានា។[54]

តារាងទី៦៖ ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ

ល.រ	ការបរិយាយ	ចំនួន
១	លិខិតចូល	៤៣០លិខិត
២	សម្តែងការគួរសម/បដិសណ្ឋារកិច្ច/ការប្រជុំ/រៀបចំលិខិត	១.៧២២លិខិត
៣	ឯកសារបានចុះហត្ថលេខា	០១លើក

៣.១.៣.ការងារផែនការ និងការគាំទ្រមូលដ្ឋាន

គម្រោងសកម្មភាពនៃកម្មវិធីវិនិយោគ ឆ្នាំ២០២០

តារាងទី៧៖ គម្រោងសកម្មភាពរបស់រដ្ឋបាលរាជធានីភ្នំពេញ

ល.រ	ផ្នែក	ចំនួនគម្រោង
១	សេដ្ឋកិច្ច	៧១
២	សង្គមកិច្ច	២៦
៣	ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ	១៤
៤	រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ	៣១
សរុប		**១៤២**

តារាងទី៨៖ គម្រោងសកម្មភាពរបស់រដ្ឋបាលខណ្ឌ សង្កាត់

ល.រ	ផ្នែក	ចំនួនគម្រោង
១	សេដ្ឋកិច្ច	១៩៩
២	សង្គមកិច្ច	២៧
៣	ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ	១៩៦
៤	រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ	០១
សរុប		**៤២៣**

[54] របាយការណ៍បូកសរុបការងារទីចាត់ការទំនាក់ទំនងអន្តរជាតិប្រចាំឆ្នាំ ២០២០

៣.១.៤. ការគ្រប់គ្រងធនធានមនុស្ស

- **ការងារគ្រប់គ្រងបុគ្គលិក**[55]

- បានពិនិត្យសំណុំលិខិតតែងតាំងមុខតំណែងមន្ត្រីរាជការ ចំនួន ៤០រូប (ជានារី ចំនួន ១៤រូប) បំពេញក្នុងរចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ មានដូចខាងក្រោម៖
  - មន្ត្រីនៃរដ្ឋបាលខណ្ឌចំនួន ២៦រូប (ជានារីចំនួន ៨រូប)
  - មន្ត្រីនៃមន្ទីរជំនាញចំនួន ១៤រូប (ជានារីចំនួន ៦រូប)។
- បានចេញនូវដីកាតែងតាំងពីមុខតំណែងមន្ត្រីរាជការបំពេញរចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ សរុបចំនួន ១០០រូប (ជានារីចំនួន ២៧រូប) រួមមាន៖
  - មន្ត្រីនៃសាលារាជធានីភ្នំពេញ ចំនួន ០៣រូប (ជានារីចំនួន ០១រូប)
  - មន្ត្រីនៃរដ្ឋបាលខណ្ឌចំនួន ៣១រូប (ជានារីចំនួន ១០រូប)
  - មន្ត្រីនៃមន្ទីរជំនាញចំនួន ៦៦រូប (ជានារីចំនួន ១៦រូប)។
- បានបញ្ជូនសំណើសុំផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាខណ្ឌ និងសង្កាត់ចំនួន ២២រូប (ជានារីចំនួន ០១រូប) រួមមាន៖
  - ក្រុមប្រឹក្សាខណ្ឌដែលស្នើសុំផ្លាស់ប្តូរ និងទទួលស្គាល់ចំនួន ១០រូប
  - ក្រុមប្រឹក្សាសង្កាត់ដែលស្នើសុំផ្លាស់ប្តូរ និងទទួលស្គាល់ចំនួន ១២រូប (ជានារីចំនួន ០១រូប)។

តារាងទី៩៖ ស្ថិតិក្រុមប្រឹក្សា គណៈអភិបាលមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា

ការបរិយាយ	សរុប	ស្រី
ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ	០១រូប	០០រូប
សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ	២៦រូប	០៦រូប
សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ដែលផ្លាស់ប្តូរ	០រូប	០រូប
អភិបាលរាជធានីភ្នំពេញ	០១រូប	០រូប
អភិបាលរងរាជធានីភ្នំពេញ	០៦រូប	០១រូប
នាយករដ្ឋបាលសាលារាជធានីភ្នំពេញ	០១រូប	០រូប
នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ	០៧រូប	០២រូប
នាយកទីចាត់ការ	០៩រូប	០៣រូប

[55] របាយការណ៍បូកសរុបការងារទីចាត់ការធនធានមនុស្សប្រចាំឆ្នាំ២០២០

នាយករងទីចាត់ការ	១៨រូប	០១រូប
ប្រធានអង្គភាព	០២រូប	០១រូប
អនុប្រធានអង្គភាព	០៤រូប	០១រូប
ប្រធានការិយាល័យ	២៣រូប	០៥រូប
អនុប្រធានការិយាល័យ	៤៦រូប	១៧រូប
ប្រធានការិយាល័យប្រជាពលរដ្ឋ	០១រូប	០០រូប
អនុប្រធានការិយាល័យប្រជាពលរដ្ឋ	០១រូប	០១រូប
ប្រធានផ្នែក នៃការិយាល័យប្រជាពលរដ្ឋ	០២រូប	០០រូប
អនុប្រធានផ្នែក នៃការិយាល័យប្រជាពលរដ្ឋ	០៤រូប	០១រូប
មន្ត្រីរាជការ នៃការិយាល័យនានា	១៥៩រូប	៦៦រូប
មន្ត្រីជាប់កិច្ចសន្យាសាលារាជធានីភ្នំពេញ	១.០២៩រូប	២២៧រូប

៣.១.៥ការងារអភិវឌ្ឍន៍ទីក្រុង និងអន្តរវិស័យ

- **ការងារៀបចំ និងការអភិវឌ្ឍទីក្រុង[56]**

ពិនិត្យ និងផ្តល់យោបល់លើលិខិតរដ្ឋបាលទូទៅ និងការងារ LMAP និងសំណង់ខុសលិខិតអនុញ្ញាត សាងសង់សំណង់គ្មានលិខិតអនុញ្ញាត និងការងារពាក់ព័ន្ធ និងការជួសជុលសំណង់គ្រប់ប្រភេទចំនួន ២.៥៥០ច្បាប់លិខិតពាក់ព័ន្ធនឹងការស្នើសុំកាប់ រំកិល លះមែកដើមឈើក្នុងរាជធានីភ្នំពេញ បូករួមនឹងការចុះពិនិត្យ និងលើកជាយោបល់ចំនួន ៦២ករណី។ បានពិនិត្យ និងបានផ្តល់យោបល់លើការងារពាក់ព័ន្ធនឹងការស្នើសុំលិខិតអនុញ្ញាតសាងសង់ទៅ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន១៦៥ច្បាប់។ បានមកចុះពិនិត្យទីតាំងជាក់ស្តែងតាមចំណារឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញចំនួន ១៣០ករណី។

- **ការងារអន្តរវិស័យ[57]**

ពិនិត្យ និងផ្តល់យោបល់លើសំណុំលិខិតអនុញ្ញាតលើកស្លាកយីហោជូនអាជីវករថ្មីបាន ៣.១៨៣ច្បាប់ បានដំឡើងផ្ទាំងផ្សាយថ្មីចំនួន ៧៥ទីតាំង(ក្នុងនោះមានប៉ាណូ-របារកាត់ទទឹងផ្លូវ-ប្រអប់ភ្លើង-ទូរទស្សន៍ LED)។ បានបន្តសុពលភាពផ្ទាំងផ្សាយពាណិជ្ជកម្ម ចំនួន ១៣៦ទីតាំង (ក្នុងនោះរួមមាន ប៉ាណូ-របារកាត់ទទឹងផ្លូវ ប្រអប់ភ្លើង-ទូរទស្សន៍ LED និងស្លាកសញ្ញាចង្អុលបង្ហាញទិសផ្លូវ) បានចេញលិខិត អនុញ្ញាតឱ្យក្រុមហ៊ុនកែ

[56] របាយការណ៍បូកសរុបការងារទីចាត់ការរៀបចំក្រុងប្រចាំឆ្នាំ២០២០

[57] របាយការណ៍បូកសរុបការងារការិយាល័យផ្សព្វផ្សាយពាណិជ្ជកម្មប្រចាំឆ្នាំ២០២០

លម្អរបារកាត់ទទឹងផ្លូវទៅជា LED ចំនួន ១ទីតាំង បានចេញលិខិតអនុញ្ញាតឱ្យមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដាក់ស្លាកសញ្ញាសម្គាល់ ទីតាំងមជ្ឈមណ្ឌលចំនួន ២ទីតាំង និងបានចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនបន្តសុពលភាពដាក់បង់អង្គុយនៅតាមបណ្តោយសួនច្បារមាត់ទន្លេ និងសួនច្បារផ្សារចាស់។

តារាងទី១០៖ ទីតាំងអាជីវកម្មដែលបានអនុញ្ញាត ច្បាប់ពីរដ្ឋបាលរាជធានី

ប្រភេទអាជីវកម្ម	ចំនួន		សរុបចំនួន
	ទីតាំងថ្មី	ទីតាំងបន្ត	
ទីតាំងជួលផ្ទះ	១៣ទីតាំង	១០ទីតាំង	២៣ទីតាំង
ទីតាំងបញ្ចុលហ្គាស	០៥ទីតាំង	០៥ទីតាំង	១០ទីតាំង
ទីតាំងបើកព្រះវិហារ	០៨ទីតាំង	០០ទីតាំង	០៨ទីតាំង
ទីតាំងក្រុមហ៊ុន	២៤ទីតាំង	៣៥ទីតាំង	៥៩ទីតាំង
ទីតាំងបើកផ្សារ	០៤ទីតាំង	០៥ទីតាំង	០៩ទីតាំង
ទីតាំងទូអេធីអឹម	១០ទីតាំង	១០ទីតាំង	២០ទីតាំង
ទីតាំងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ	៥២ទីតាំង	៤៥ទីតាំង	៩៧ទីតាំង
ទីតាំងអាជីវកម្មដេប៉ូស្តុក-លក់ ខ្សាច់សំណង់	៣០ទីតាំង	១៤ទីតាំង	៤៤ទីតាំង
ទីតាំងទិញ-លក់បញ្ចាំទ្រព្យសម្បត្តិ	២០ទីតាំង	៣៩ទីតាំង	៥៩ទីតាំង
ទីតាំងអាជីវកម្មឆ្នោត	០២ទីតាំង	០៤ទីតាំង	០៦ទីតាំង
ទីតាំងអាជីវកម្មហ្គេមកម្សាន្តតុក្កតា	០២ទីតាំង	០០ទីតាំង	០២ទីតាំង
ទីតាំងអាជីវកម្មទេសចរណ៍	១០ទីតាំង	០០ទីតាំង	១០ទីតាំង
ទីតាំងអាជីវកម្មសាលាបង្រៀនបើកបរ	០២ទីតាំង	០០ទីតាំង	០២ទីតាំង
សរុបរួម	**១៨២ទីតាំង**	**១៦៧ទីតាំង**	**៣៤៩ទីតាំង**

៣.១.៦ ការងារហិរញ្ញវត្ថុ

- **ការអនុវត្តចំណូល និងចំណាយ**[58]
  - រដ្ឋបាលរាជធានីភ្នំពេញបានអនុវត្តនីតិវិធីហិរញ្ញវត្ថុតាមការណែនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយអនុវត្តតាមប្រកាសលេខ ១៦៤៦សហវ.អហក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការប្រគល់

[58] របាយការណ៍បូកសរុបការងារទីចាត់ការហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០

កាតព្វកិច្ចប្រមូលចំណូល និងការបែងចែកឥណទានចំណាយថវិកា រាជធានីភ្នំពេញ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៩។

- អនុវត្តតាមសេចក្តីណែនាំលេខ០១០សហវចុះថ្ងៃទី១៥ខែមេសា ឆ្នាំ២០២០ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងសមត្ថភាពចំណាយសម្រាប់ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត។

➢ **ការគ្រប់គ្រងទ្រព្យសម្បត្តិ**

- រដ្ឋបាលរាជធានីភ្នំពេញ បានរៀបចំបញ្ជីសារពើភ័ណ្ឌដោយធ្វើជាតារាងប្រៀបធៀប កើន ថយ សម្រាប់ ឆ្នាំ២០១៩ ក្នុងនោះមានទ្រព្យសម្បត្តិមួយចំនួនមានសភាពចាស់ទ្រុឌទ្រោមប្រើលែងបានការិយាល័យទ្រព្យសម្បត្តិក៏បាន និងកំពុងរៀបចំនីតិវិធីនៅក្នុងការជម្រះ ដើម្បីធ្វើការកាត់ចេញពីបញ្ជីសារពើភ័ណ្ឌជាបន្តបន្ទាប់រៀងរាល់ឆ្នាំ។

តារាងទី១១៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ

ល.រ	ការបរិយាយ	ចំនួន
១	ទ្រព្យសម្បត្តិ ដែលបានទិញ ឬ ទទួល (ថ្មី)	១២៥៤គ្រឿង
២	ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ	

៣.១.៧ ការងារអន្តរាគមន៍ច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

ការងារអង្គភាពច្រកចេញចូលតែមួយ[59]

- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងកិច្ចប្រជុំផ្សេងៗទៀតសរុបចំនួន ១៦លើក។

តារាងទី១២៖ ការផ្តល់សេវាសាធារណៈតាមច្រកចេញចូលតែមួយ

ល.រ	ឈ្មោះសេវា	ចំនួនសេវា
១	នីត្យានុកូលកម្ម	៩.២៤៤
២	ការងាររដ្ឋបាល	០៩
៣	វិស័យសុខាភិបាល	៨០៥
៤	វិស័យទេសចរណ៍	៦៦៥
៥	វិស័យសាធារណការ និងដឹកជញ្ជូន	៣៨៣

[59] របាយការណ៍បូកសរុបការងារអង្គភាពច្រកចេញចូលតែមួយប្រចាំឆ្នាំ២០២០

៦	វិស័យពត៌មាន	៣៨៤
៧	វិស័យបរិស្ថាន	១៨
៨	វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	២៧៨
៩	វិស័យពាណិជ្ជកម្ម	១៣៨
១០	វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	១២.៥៨១
១១	វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	៤.៥៩៥
១២	វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	៣០.៩៦៤
	(ក) សំណង់	៤១៧
	(ខ) សុរិយោដី	៣០.៥៤៧
១៣	វិស័យវប្បធម៌ និងវិចិត្រសិល្បៈ	០១
១៤	វិស័យរ៉ែ និងថាមពល	០០
សរុប		**៦០.០៥៧**

➢ ការិយាល័យប្រជាពលរដ្ឋ[60]

- បានចូលរួមក្នុងកិច្ចប្រជុំដែលដឹកនាំដោយគណៈអភិបាលរាជធានីភ្នំពេញ ចំនួន ៤៤លើក បានចូលរួមនៅក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ ចំនួន ១០លើក និងកិច្ចប្រជុំវិសាមញ្ញមានចំនួន ២លើកបានចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ប្រឹក្សារាជធានីអាណត្តិទី៣ចំនួន ១១លើក និងបានចូលរួមកម្មវិធី និងប្រជុំដឹកនាំដោយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ចំនួន ៣លើក។
- បានប្រចាំការនៅតុពិសេសការិយាល័យប្រជាពលរដ្ឋ ក្នុងអង្គភាពច្រកចេញចូលតែមួយ ក្នុងការជួយសម្របសម្រួលដល់ប្រជាពលរដ្ឋដែលមកស្នើសុំប្រើសេវានៅអង្គភាពច្រកចេញចូលតែមួយ។
- បានប្រជុំពង្រឹងការងាររដ្ឋបាលផ្ទៃក្នុង ការិយាល័យជាទៀងទាត់ ក្នុង១ខែម្តង ទាំងថ្នាក់ការិយាល័យ និងថ្នាក់ផ្នែកនីមួយៗ សរុបបាន ១២លើក និងបានចុះចាប់ប្រអប់សំបុត្រទទួលពាក្យបណ្តឹងចំនួន ៥៧ ទីតាំង និងចុះបើកប្រអប់សំបុត្រទទួលពាក្យបណ្តឹងចំនួន ១២៦/ដង/លើក។

[60] របាយការណ៍បូកសរុបការងារការិយាល័យប្រជាពលរដ្ឋប្រចាំឆ្នាំ២០២០

៣.២ ការងាររដ្ឋបាលខណ្ឌ និងសង្កាត់

៣.២.១ ការងាររដ្ឋបាលខណ្ឌ

ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	ដីកាដែលបានដាក់ចេញ	00	៤៩	៤៩
២	សេចក្តីសម្រេចដែលបានដាក់ចេញ	00	៤៩៧	៤៩៧
៣	លិខិតរដ្ឋបាលដែលបានដាក់ចេញ	00	៣២.៤៦៥	៣២.៤៦៥
៤	លិខិតដែលបានទទួល	00	៣៦.៥១០	៣៦.៥១០
៥	សៀវភៅស្នាក់នៅ	00	១៨.៧៥២	១៨.៧៥២

ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	សេចក្តីចម្លងសំបុត្រកំណើត	00	២៤.២៥៥	២៤.២៥៥
២	សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត	00	១០៦.៥៣៧	១០៦.៥៣៧
៣	សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍	00	១១.៧១៣	១១.៧១៣
៤	សេចក្តីចម្លងសំបុត្រមរណភាព	00	២.១៤៤	២.១៤៤

ការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
ក). ការផ្សព្វផ្សាយព័ត៌មាន				
១	វិទ្យុ	00អត្ថបទ	៦៦៧អត្ថបទ	៦៦៧អត្ថបទ
២	ទូរទស្សន៍	00អត្ថបទ	១.១២៧អត្ថបទ	១.១២៧អត្ថបទ

៣	បិទផ្សាយលើក្តារព័ត៌មានសាធារណៈ	០០សន្លឹក	៨៤៨សន្លឹក	៨៤៨សន្លឹក
៤	ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន	០០ ច្បាប់	៦០២ច្បាប់	៦០២ច្បាប់
៥	ផ្សេងៗ	០០ច្បាប់	១.៧៨៨ច្បាប់	១.៧៨៨ ច្បាប់
ខ). ទំនាក់ទំនងសាធារណៈ				
១	សាធារណជនមកទំនាក់ទំនងសាលាខណ្ឌ	០០លើក	២២១.២៣៥ លើក	២២១.២៣៥ លើក
២	គណៈប្រតិភូភៀវជាតិអន្តរជាតិ	០០លើក	១.៩១៤លើក	១.៩១៤លើក

កិច្ចប្រជុំគណៈអភិបាល

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល	០០	១៥៦	១៥៦
២	កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល	០០	១៥៣	១៥៣

កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការ និងការរៀបចំវេទិកាសាធារណៈ

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា	០០	១៤៥	១៤៥
២	កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា	០០	១២	១២
៣	កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា	០០	០	០
៤	កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស	០០	២៥	២៥
៥	កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ	០០	១៣៥	១៣៥
៦	ការរៀបចំវេទិកាសាធារណៈ	០០	៣៩	៣៩

គម្រោងវិនិយោគបីឆ្នាំរំកិលខណ្ឌ

ល.រ	ផ្នែក	ចំនួនគម្រោង
១	សេដ្ឋកិច្ច	១៦៦
២	សង្គមកិច្ច	២៨៦
៣	គ្រប់គ្រងដីធ្លី បរិស្ថាន ការប្រែប្រួលអាកាសធាតុគ្រោះមហន្តរាយ	១១៣
៤	រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ	១៤១
សរុប		៧០៦

ការអនុវត្តគម្រោងវិនិយោគខណ្ឌ

ល.រ	ផ្នែក	សរុប	ស្ថានភាពនៃការអនុវត្ត		
			មិនទាន់	កំពុង	បញ្ចប់
១	សេដ្ឋកិច្ច	**២៤១**	៥០	៥	៨២
២	សង្គមកិច្ច	**២៨៣**	២៦	១២	៥៨៧
៣	គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ	**១១៣**	១៣	៤	៩៩
៤	រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ	**១៤១**	៦	១	១១១
សរុប		**៧៧៨**	**៩៥**	**២២**	**៨៧៩**

ស្ថិតិក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក (ខណ្ឌទាំង ១៤ ទូទាំងរាជធានី)

ល.រ	ការបរិយាយ	សរុប	ស្រី
១	សមាជិកក្រុមប្រឹក្សា	២៥៦	៥១
២	ប្រធានក្រុមប្រឹក្សា	១៤	០១
៣	សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ	០០	០០
៤	អភិបាល	១៤	០០
៥	អភិបាលរង	៥៦	១១

៦	នាយករដ្ឋបាល	១៤	០០
៧	នាយករងរដ្ឋបាល	២៤	០៣
៨	ប្រធានការិយាល័យ និងអង្គភាព	៨២	០៩
៩	អនុប្រធានការិយាល័យ និងអង្គភាព	៦៦	១៨
១០	មន្ត្រីការិយាល័យ	២២៩	៨៨
១១	បុគ្គលិកកិច្ចសន្យា	១.០៤៥	២៣៧

កិច្ចការច្រកចេញចូលតែមួយ

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	សេវាសរុបដែលបានផ្តល់ចប់សព្វគ្រប់	០០	២៣០.៣១៣	២៣០.៣១៣
២	ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា	០០	២១១.៧៨២	២១១.៧៨២
៣	ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា	០០	៥៧.១៧២	៥៧.១៧២
៤	ចំណូលដែលទទួលបានពីការផ្តល់សេវា	០០	៤.០២៧.០០៤.១២៥រ	៤.០២៧.០០៤.១២៥រ
៥	ករណីបណ្តឹងដែលទទួលបានសរុប	០០	៤៣៨.៧៩២.០១៩	៤៣៨.៧៩២.០១៩
៦	ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ	០០	១៧	១៧

៣.២.២ ការងាររដ្ឋបាលសង្កាត់

ស្ថិតិក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិក

ល.រ	ការបរិយាយ	សរុប	ស្រី
១	សមាជិកក្រុមប្រឹក្សាសង្កាត់	៨៩៩	៣២២
២	សមាជិកក្រុមប្រឹក្សាសង្កាត់ដែលបានផ្លាស់ប្តូរ	១៩	០៥
៣	ចៅសង្កាត់	១០៥	១៥
៤	ចៅសង្កាត់រងទី១	១០៥	៣៤
៥	ចៅសង្កាត់រងទី២	១០៥	២១

៦	ស្មៀនសង្កាត់	១០៥	១៦
៧	បុគ្គលិកកិច្ចសន្យា	២៣០	៦៦
៨	មេភូមិ	៩៥៣	១៤១
៩	អនុប្រធានភូមិ	៩០៩	២៤១
១០	សមាជិកភូមិ	៩០៩	៥៤៩
១១	អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាសង្កាត់	១៣៦	៨២
	ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃសង្កាត់	១៤៩	៥៥

ដីកា សេចក្តីសម្រេច និងលិខិត

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	ដីកាដែលបានដាក់ចេញ	00	៩៨	៩៨
២	សេចក្តីសម្រេចដែលបានដាក់ចេញ	00	៧៦០	៧៦០
៣	លិខិតរដ្ឋបាលដែលបានដាក់ចេញ	00	២៨.៩២៣	២៨.៩២៣
៤	លិខិតដែលបានទទួល	00	២៤.១៩៥	២៤.១៩៥

កិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា	00	១.០៣០	១.០៣០
២	កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា	00	៣២៨	៣២៨
៣	កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា	00	៥	៥
៤	កិច្ចប្រជុំ គ.ក.ន.ក	00	៩៦៩	៩៦៩

គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ

ល.រ	ផ្នែក	ចំនួនគម្រោង
១	សេដ្ឋកិច្ច	១៥៣
២	សង្គមកិច្ច	៥៣០
៣	ធនធានធម្មជាតិ និងបរិស្ថាន	១៦៨
៤	សេវាកម្មរដ្ឋបាល និងសន្តិសុខ	៣០៦
៥	យេនឌ័រ	៦២
សរុប		**១.២១៩**

ការអនុវត្តគម្រោងសង្កាត់

ល.រ	ផ្នែក	សរុប	ស្ថានភាពនៃការអនុវត្ត		
			មិនទាន់	កំពុង	បញ្ចប់
១	សេដ្ឋកិច្ច	២៤២	៩	៥៩	១៧២
២	សង្គមកិច្ច	១.៣៣៩	១០៩	១៦០	៨៣៦
៣	ធនធានធម្មជាតិ និងបរិស្ថាន	៣១៨	២៨	៨២	២១២
៤	សេវាកម្មរដ្ឋបាល និងសន្តិសុខ	៩៩៣	៥៦	១៣៧	៧៧៧
៥	យេនឌ័រ	៥៦	៥	១៣	៦៤
សរុប		**២.៩៤៨**	**២០៧**	**៤៥១**	**២.០៦**

ការគ្រប់គ្រងទ្រព្យសម្បត្តិសង្កាត់

ល.រ	**ការបរិយាយ**	**ចំនួន**		
		ដើមគ្រា	**ក្នុងគ្រា**	**បូកយោង**
១	ទ្រព្យសម្បត្តិសង្កាត់ ដែលបានទិញ ឬ ទទួល (ថ្មី)	០០	២.៣៣០	២.៣៣០
២	ទ្រព្យសម្បត្តិសង្កាត់ដែលបានកាត់ចេញ	០០	១.៦៤៤	១.៦៤៤

ការអភិវឌ្ឍសមត្ថភាព

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	វគ្គសិក្សា	00	៤៥៩	៤៥៩
២	សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា	00	២.៥៤៣	២.៥៤៣
៣	សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា	00	១.០៩០	១.០៩០

សេវាសង្គម

ល.រ	ការបរិយាយ	ចំនួន
១	មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីសង្កាត់	១២
២	គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ)	៤១០
៣	គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់	0
៤	គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់	0
៥	គ្រួសារងាយរងគ្រោះដែលសង្កាត់ចុះកំណត់អត្តសញ្ញាណ	៦.៤៥១
៦	ស្ត្រីរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីសង្កាត់	១.៦២៨

ការសម្រុះសម្រួលទំនាស់

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយសង្កាត់	00	២.៤៨៨	២.៤៨៨
២	ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ	00	១៩២	១៩២

ការងារអត្រានុកូលដ្ឋាន

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
១	សំបុត្រកំណើត	00	១៤.១៧២	១៤.១៧២

ល.រ	ការបរិយាយ	ចំនួន		
		ដើមគ្រា	ក្នុងគ្រា	បូកយោង
២	សំបុត្របញ្ជាក់កំណើត	00	១០.៤៩៦	១០.៤៩៦
៣	សេចក្តីចម្លងសំបុត្រកំណើត	00	២០.៩៧៧	២០.៩៧៧
៤	សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត	00	១៤.៩៧៧	១៤.៩៧៧
៥	សំបុត្រអាពាហ៍ពិពាហ៍	00	៦.៧៧៧	៦.៧៧៧
៦	សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍	00	១១.៨៦២	១១.៨៦២
៧	សំបុត្រមរណភាព	00	៣.០៤៨	៣.០៤៨
៨	សេចក្តីចម្លងសំបុត្រមរណភាព	00	៦.៩២៥	៦.៩២៥

ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត

ល.រ	ការបរិយាយ	ចំនួន
១	ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី	២.៣៣០
២	ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត	១.៦៤៤
៣	ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី)	៧៨.២៦៥

ជំពូកទី៤
បញ្ហាប្រឈម និងដំណោះស្រាយ

ជំពូកទី៤
បញ្ហាប្រឈម និងដំណោះស្រាយ

៤.១ បញ្ហាប្រឈម

- **ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ**
  - កម្មវិធីការងាររបស់ថ្នាក់ដឹកនាំរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ ដែលទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ទទួលភារកិច្ចការរៀបចំរួមមានជំនួបសម្តែងការគួរសមជាមួយប្រមុខបេសកកម្មការទូតអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានាត្រូវបានលើកពេល និងលុបចោលកម្មវិធី ដោយសារការកើតមានការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងអំឡុងខែវិច្ឆិកា ។
- **ការគ្រប់គ្រងធនធានមនុស្ស**
  - ខ្វះមន្ត្រីស្មៀនចំនួន ២រូបរួមមានស្មៀន សង្កាត់បឹងព្រលឹត និងសង្កាត់បឹងកក់ទី១ ដែលបានចូលនិវត្តន៍ និងទទួលមរណភាព
  - ដំណើរការនៃការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌ ឆ្នាំ២០២០ ពុំបានអនុវត្តទៅតាមការគ្រោងទុកដោយសារចូលរួមអនុវត្តវិធានការបង្ការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- **ការងារអភិវឌ្ឍន៍ទីក្រុង**
  - ដោយរាជធានីភ្នំពេញបានអភិវឌ្ឍន៍មុនប្លង់គោលរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ដែលត្រូវអនុម័តធ្វើឱ្យការអភិវឌ្ឍមិនទាន់គោរពបានពេញលេញតាមប្លង់គោលរាជធានីភ្នំពេញឆ្នាំ២០៣៥
  - បញ្ហាចាក់ដីលុបសម្រាប់ធ្វើការអភិវឌ្ឍធ្វើឱ្យបិទផ្លូវទឹកហូរ
- **ការងារអន្តរវិស័យ**
  - ការបិទខិតប័ណ្ណផ្សព្វផ្សាយនៅតាមដើមឈើបង្គោលភ្លើង និងការចងបដាអនាធិបតេយ្យនៅតែកើតមានជាពិសេសនៅពេលយប់មានការបិតស្ទឹកយ៉ែរកម្ទីតណាទានបង្កឱ្យប៉ះពាល់ដល់សោភ័ណភាព និងសណ្តាប់ធ្នាប់
  - ការសរសេរស្លាកយីហោដែលបានប្រើប្រាស់អក្សរបរទេសសុទ្ធ ឬ អក្សរបរទេសនៅលើអក្សរខ្មែរហើយនៅពេលយប់ស្លាកអក្សរខ្មែរគ្មានភ្លើងបំភ្លឺ (បើកភ្លើងតែអក្សរបរទេសសុទ្ធ) នៅតាមហាងលក់ដូរ និងភោជនីយដ្ឋាននានា ការសរសេរអក្សរខុសខ្លឹមសារខុសអក្ខរាវិរុទ្ធ

- **ការងារហិរញ្ញវត្ថុ**
  - ការរៀបចំបិទបញ្ជីចំណូលចំណាយថវិកាឆ្នាំ២០១៩ និងការកែតម្រូវគម្រោងថវិកាឆ្នាំ២០២០ និងរៀបចំគម្រោងផែនការថវិកា ឆ្នាំ២០២១របស់រដ្ឋបាលសង្កាត់មួយចំនួនដើម្បីផ្ញើរមករដ្ឋបាលរាជធានីភ្នំពេញធ្វើការបញ្ជាក់ទទួលស្គាល់ និងផ្តល់អនុលោមភាពនៅមានការយឺតយ៉ាវ
- **ការងារលទ្ធកម្ម**
  - នៅពេលចុះអនុវត្តការងារជាក់ស្តែងដែលបានជួបបញ្ហាប្រឈមដូចជា៖ផលប៉ះពាល់សំយ៉ាប និងរបងផ្ទះរបស់ប្រជាពលរដ្ឋដែលធ្វើរំលោភបំពានលើចិញ្ចើមផ្លូវនិងបណ្តាញផ្សេងៗដូចជាបណ្តាញទឹកស្អាត បង្គោលភ្លើង អគ្គិសនីបណ្តាញក្រោមដី បណ្តាញខ្សែកាប្លិ៍អុបទិច និងបណ្តាញគមនាគមន៍ផ្សេងៗ
- **ការងារអង្គភាពច្រកចេញចូលតែមួយ និងការងារការិយាល័យប្រជាពលរដ្ឋ**
  - សេវាវិស័យសាធារណការ និងដឹកជញ្ជូនផ្នែកចុះបញ្ជីយានយន្តមិនទាន់បានដំណើរការនៅអង្គភាពច្រកចេញ-ចូលតែមួយនៅឡើយ
  - មន្ត្រីរាជការមួយចំនួនរួមនឹងប្រជាពលរដ្ឋខ្លះពុំទាន់យល់ច្បាស់ទូលំទូលាយអំពីតួនាទី សិទ្ធិអំណាចរបស់ការិយាល័យប្រជាពលរដ្ឋនៅឡើយ

៤.២ ដំណោះស្រាយ

- **ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ**
  - គួរត្រួតពិនិត្យលទ្ធភាពរៀបចំបំពាក់ឧបករណ៍បរិក្ខារនៅបន្ទប់ប្រជុំក្នុងសាលារាជធានីភ្នំពេញ ដើម្បីបង្កើតជម្រើសបន្ទប់ប្រជុំដែលអាចប្រើប្រាស់សម្រាប់កិច្ចប្រជុំតាមរយៈប្រព័ន្ធអនឡាញ (online) បានព្រមទាំងបង្កើនល្បឿនអ៊ីនធឺណិតឲ្យលឿនជាងមុន និងមានស្ថេរភាព។
  - បន្តទំនាក់ទំនងល្អជាមួយបណ្តាទីក្រុងសម្ព័ន្ធមេត្រី បណ្តាទីក្រុងស្តាប័នដៃគូរង់ចាំរហូតដល់ស្ថានភាពការរីករាលដាលវីរុសកូវីដ-១៩ធូរស្បើយ និងអាចគ្រប់គ្រងបានល្អប្រសើរជាងស្ថានភាពពេលបច្ចុប្បន្ន
- **ការគ្រប់គ្រងធនធានមនុស្ស**
  - បានធ្វើការផ្សព្វផ្សាយទៅខណ្ឌរដ្ឋបាលខណ្ឌទាំង១៤ ដើម្បីឱ្យមានការស្ម័គ្រចិត្តបំពេញការងារជាស្មៀន និងបានរៀបចំសំណើទៅក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងសម្រេច
  - បានចាត់មន្ត្រី ចំនួន២រូបទៅបំពេញការងារជាស្មៀនបណ្តោះអាសន្នសិនដើម្បីធានាបន្តនិរន្តរភាពការងារនៅរដ្ឋបាលសង្កាត់ទាំងពីរ
  - រង់ចាំការណែនាំពីក្រសួងមហាផ្ទៃបន្ទាប់ពីសភាពនៃជំងឺ កូវីដ-១៩ បានធូរស្រាលឡើងវិញសិន

- **ការងារអភិវឌ្ឍន៍ទីក្រុង**
  - គួរតែបានធ្វើការកែសម្រួលលិខិតគតិយុត្តមួយចំនួនដើម្បីរៀបចំការអភិវឌ្ឍទៅលើវិស័យសំណង់ ឱ្យមានប្រសិទ្ធភាពសមស្របទៅតាមប្លង់គោល ឆ្នាំ២០៣៥
  - គួរបានគណៈកម្មការសិក្សាធ្វើបច្ចុប្បន្នភាពប្លង់គោល ឆ្នាំ២០៣៥
  - គួរធ្វើការស្តារប្រឡាយចំនួន ១២ខ្សែបន្ថែមទៀត
- **ការងារអន្តរវិស័យ**
  - សំណូមពររដ្ឋបាលខណ្ឌ ទាំង១៤សហការអនុវត្តខ្លឹមសារលិខិតលេខ ០៨៧/១៩លស.អចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៩ស្តីពីការចុះបកស្នែកយ៉ែរ និងរុះរើបដាផ្សព្វផ្សាយពាណិជ្ជកម្មអនាធិបតេយ្យ
  - ភាគីពាក់ព័ន្ធសហការអនុវត្តតាមសេចក្តីជូនដំណឹងចុះ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩របស់រដ្ឋបាលរាជធានីភ្នំពេញ ទៅក្រុមហ៊ុនអាជីវកម្មបកចេញឱ្យអស់នូវស្នែកយ៉ែរ ប័ណ្ណព័ត៌មានសៅកម្ម និងបដាផ្សព្វផ្សាយពាណិជ្ជកម្មអនាធិបតេយ្យ
  - សំណូមពរអាជ្ញាធរខណ្ឌនីមួយៗជួយណែនាំរុះរើ និងទប់ស្កាត់ការដាក់តាំងស្លាកយីហោ ដែលមិនអនុវត្តតាមសេចក្តីណែនាំលេខ០១៥.១៨សណន/អ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ របស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពីការដាក់តាំងស្លាកយីហោផ្ទាំងផ្សាយពាណិជ្ជកម្ម និងនិមិត្តសញ្ញាផ្សេងៗក្នុងរាជធានីភ្នំពេញ មិនផ្តល់អាជ្ញាប័ណ្ណជូននៅច្រកចេញ-ចូលតែមួយរបស់ខណ្ឌណែនាំឱ្យកែតម្រូវរុះរើ និងបកចោល
- **ការងារហិរញ្ញវត្ថុ**
  - រដ្ឋបាល សង្កាត់នីមួយៗ គួរបានរកមន្ត្រីដែលមានជំនាញហិរញ្ញវត្ថុដើម្បីមកទំនាក់ទំនងការងារជាមួយ ទីចាត់ការហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ ដើម្បីមានភាពងាយស្រួលក្នុងការពន្យល់ណែនាំនៅពេលមានកំហុសឆ្គងក្នុងការរៀបចំ និងឱ្យបានទាន់ពេលវេលា
  - គួរតែបានរដ្ឋបាលខណ្ឌធ្វើរបាយការណ៏ ចំណូល-ចំណាយប្រចាំខែ និងសំណើសុំឧបត្ថម្ភតុល្យភាពថវិកាសម្រាប់ត្រីមាសបន្ទាប់ ដោយមានការភ្ជាប់របាយការណ៏ ចំណូល-ចំណាយសម្រាប់ត្រីមាសមុន និងត្រីមាសបន្ទាប់ដើម្បីផ្ញើមករដ្ឋបាលរាជធានីភ្នំពេញឱ្យបានត្រឹមត្រូវ និងទៀងទាត់
- **ការងារលទ្ធកម្ម**
  - ស្នើឱ្យអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធចូលរួមសហការគ្នា
- **ការងារអង្គភាពច្រកចេញចូលតែមួយ និងការងារការិយាល័យប្រជាពលរដ្ឋ**
  - រដ្ឋបាលរាជធានីភ្នំពេញបានធ្វើលិខិតទៅកាន់ ក្រសួងសាធារណៈការ និងដឹកជញ្ជូនដើម្បីឱ្យដំឡើងប្រព័ន្ធSERVER ចុះបញ្ជីយានយន្តនៅសាលារាជធានីភ្នំពេញ និងបង់កម្រៃសេវានៅអង្គភាពច្រក

ចេញចូលតែមួយប៉ុន្តែមិនទាន់ទទួលការឆ្លើយតបនៅឡើយ

- ស្នើសុំបើកវគ្គផ្សព្វផ្សាយបន្ត និងស្នើសុំផ្សាយតាមប្រព័ន្ធ ព័ត៌មាន ទូរទស្សន៍ និងកាសែត

៤.៣ ទិសដៅការងារឆ្នាំបន្ទាប់

៤.៣.១ រដ្ឋបាលរាជធានី[61]

- **ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**
  - ត្រៀមរៀបចំកិច្ចប្រជុំសាមញ្ញចំនួន ១២លើករបស់ក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី៣
  - ត្រៀមរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី៣
  - ត្រៀមរៀបចំកិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញអាណត្តិទី៣
  - ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ
  - ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្មរាជធានីភ្នំពេញ
- **ការងារគណៈអភិបាល**
  - ត្រៀមជួបសម្តែងការគួរសមជាមួយភ្ញៀវជាតិ អន្តរជាតិ
  - ត្រៀមចូលរួមជាអធិបតីក្នុងពិធីបើកការដ្ឋានស្ថាបនាផ្លូវ សួន សាលារៀន
  - ត្រៀមប្រជុំអឌ្ឍមាសរបស់គណៈអភិបាល
  - ត្រៀមប្រជុំប្រចាំខែរបស់គណៈអភិបាល
    - បន្តអនុវត្តទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលស្តីពីវិធាននៃការទប់ស្កាត់ការរាតត្បាតនៃមេរោគកូវីដ-១៩
    - បន្តការផ្សព្វផ្សាយដើម្បី បញ្ជ្រាបការយល់ដឹងកាន់តែខ្ពស់ស្តីពីអនាម័យនៅក្នុងការរស់នៅជូនដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានក្នុងរាជធានីភ្នំពេញ
    - បន្តការចូលរួមសហការជាមួយក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅរាជធានីភ្នំពេញក្នុងការចុះយុទ្ធនាការផ្សព្វផ្សាយពីវិធានការទប់ស្កាត់ការរីករាលនៃមេរោគកូវីដ-១៩ និងកំណត់អត្តសញ្ញាណប្រជាពលរដ្ឋទីទ័លក្រខ្លាំងដើម្បីពិនិត្យលទ្ធភាពក្នុងការជួយឧបត្ថម្ភតាមជាក់ស្តែង
- **ការងាររដ្ឋបាល**
  - ត្រៀមរៀបចំកម្មវិធីប្រចាំសប្តាហ៍ និងធ្វើលិខិតអញ្ជើញប្រជុំជូនគណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សារាជធានីភ្នំពេញ

[61] របាយការណ៍ស្តីពីទិសដៅការងារឆ្នាំបន្ទាប់សាលារាជធានីភ្នំពេញប្រចាំឆ្នាំ២០២០

- រៀបចំបូកសរុបរបាយការណ៍ប្រចាំខែត្រីមាសឆមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានីភ្នំពេញ

➢ **ការងារគ្រប់គ្រងធនធានមនុស្ស**

- ត្រៀមរៀបចំរបាយការណ៍ ស្តីពីការលទ្ធផលបញ្ចប់នៃការប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមរបប ០២ឆ្នាំសម្រាប់ ឆ្នាំ២០២១
- ត្រៀមរៀបចំផែនការក្របខណ្ឌមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់ ឆ្នាំ២០២២
- ត្រៀមរៀបចំការងារស្នើសុំតម្លើងឡើងថ្នាក់ឋានន្តរស័ក្តិទៅតាមវេន និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការបម្រើការងាររក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញ សម្រាប់ឆ្នាំ ២០២១
- ត្រៀមរៀបចំការងារស្នើសុំដាក់មន្ត្រីរាជការ ដែលដល់អាយុត្រូវចូលនិវត្តន៍សម្រាប់ ឆ្នាំ២០២២ និងមន្ត្រីរាជការដែលស្នើសុំចូលនិវត្តន៍មុនអាយុ
- ត្រៀមរៀបចំបញ្ជីបច្ចុប្បន្នភាពមន្ត្រីរាជការបម្រើក្រោមឱវាទរដ្ឋបាលរាជធានីភ្នំពេញប្រចាំឆ្នាំ ២០២១
- ត្រៀមរៀបចំបញ្ជីបច្ចុប្បន្នភាព ក្រុមប្រឹក្សារាជធានី ខណ្ឌ និងសង្កាត់សម្រាប់ឆ្នាំ ២០២១
- ត្រៀមរៀបចំស្នើសុំផ្តល់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា និងប័ណ្ណសរសើរជូនទៅកាន់មន្ត្រីរាជការ-មន្ត្រីជាប់កិច្ចសន្យាសម្រាប់ ឆ្នាំ២០២១
- ត្រៀមរៀបចំបើកវគ្គបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការតាមផែនការ ដែលគ្រោងទុកសម្រាប់ឆ្នាំ ២០២១

➢ **ការងាររៀបចំ និងការអភិវឌ្ឍទីក្រុង**

- បញ្ចប់ទៅលើគម្រោងសិក្សាគម្រោងផ្លូវថ្មើរជើងមាត់ទន្លេបាសាក់ ចាប់ពីស្ពានឥន្ទនូកោះពេជ្រហូតដល់ស្ពានព្រះមុនីវង្ស
- បន្តសិក្សាគម្រោងផ្លូវថ្មើរជើងមាត់ទន្លេសាបចាប់ពីផ្សារពោធិ៍ដល់គល់ស្ពានជ្រោយចង្វារ និងចាប់ពីស្ពានជ្រោយចង្វាររហូតដល់ស្ពានដែក
- ចូលរួមសហការសិក្សាជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ អង្គភាព JICA និងអង្គភាពពាក់ព័ន្ធលើគម្រោងរៀបចំប្រព័ន្ធបង្ហូរ
- ចូលរួមសហការសិក្សាជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ អង្គភាព JICA និងអង្គភាពពាក់ព័ន្ធលើគម្រោងរៀបចំប្រព័ន្ធបង្ហូរទឹកតំបន់អាងស្តុកទឹក ស្ថានីយ៍បូមទឹក និងស្ថានីយ៍ចម្រោះទឹកកខ្វក់នៅក្នុងរាជធានីភ្នំពេញចូលរួមសហការសិក្សាប្លង់មេ ដឹកជញ្ជូនប្លង់មេ និងប្រព័ន្ធបង្ហូរទឹកនៅក្នុងរាជធានីភ្នំពេញ

- **ការងារហិរញ្ញវត្ថុ**
  - រៀបចំការងារបិទបញ្ជីចំណូល-ចំណាយថវិកា និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិកា ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់
  - រៀបចំអាណត្តិបើកប្រាក់ និងរៀបចំឯកសារសំណើគម្រោងអភិវឌ្ឍរាជធានីភ្នំពេញ ឆ្នាំ២០២១ ដើម្បីស្នើសុំអនុលោមភាពពីក្រសួងមហាផ្ទៃ
  - រៀបចំសំណើសុំបង្វែតណាទានក្នុង ឆ្នាំ២០២១ និងរៀបចំទទួលស្គាល់លើការកែតម្រូវគម្រោងថវិកាឆ្នាំ ២០២១របស់រដ្ឋបាលសង្កាត់ទាំង១០៥
  - រៀបធ្វើគម្រោងផែនការថវិកាសម្រាប់ឆ្នាំ២០២២ និងរៀបចំកសាងផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ ឆ្នាំ២០២២-២០២៤
  - រៀបចំបើកប្រាក់បៀវត្សមន្ត្រីរាជការសាលារាជធានីភ្នំពេញ ឆ្នាំ២០២១

សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាន

យោងទៅតាមរយៈការស្រាវជ្រាវប្រធានបទខាងលើនេះបានបង្ហាញឲ្យឃើញពីសមិទ្ធផលដែលរដ្ឋបាលរាជធានីភ្នំពេញទទួលបានក្នុងឆ្នាំ ២០២០ នៅក្នុងនោះរួមមានទាំងស្ថានភាពគ្រប់គ្រងរដ្ឋបាល និងសកម្មភាពនានាដែលបានកើតមានឡើងនៅក្នុងរដ្ឋបាលរាជធានីភ្នំពេញ។ ដែលនៅក្នុងឆ្នាំ២០២០ កន្លងទៅនេះ រដ្ឋបាលរាជធានីភ្នំពេញ ក៏ដូចជាបណ្តាខេត្តទូទាំងប្រទេសកម្ពុជា បានទទួលរងសម្ពាធ នៃការរីករាលដាលជាសកលដ៏ធំដ៏កាចសាហាវកូវីដ-១៩ និងសម្ពាធនៃការប្រែប្រួលអាកាសធាតុពោលគឺទឹកជំនន់រហ័ស ឬ ជំនន់ទឹកភ្លៀងដែលបានទម្លាក់វាមកជាបន្ទុកមកលើរាជរដ្ឋាភិបាលកម្ពុជាទៅ និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីចាត់ចែងគ្រប់គ្រងសភាពការណ៍នេះ ឲ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈការអនុវត្តវិធានការនានារបស់ក្រសួងសុខាភិបាល និងការបំពេញតួនាទី-ភារកិច្ចរបស់រដ្ឋបាលគ្រប់ថ្នាក់ស្របតាម **"សភាពធម្មតាបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩ (New Normal Life)"** ។

ការកសាងរដ្ឋបាលមូលដ្ឋានមួយប្រកបដោយសក្តានុពល និងមានចីរភាពទាមទារឲ្យមានការតាំងចិត្តខាងនយោបាយរយៈពេលវែង។ បទពិសោធន៍នៅប្រទេសនានាជាច្រើនដែលមានប្រព័ន្ធរដ្ឋបាលតាមបែបប្រជាធិបតេយ្យវិមជ្ឈការរឹងមាំបានបង្ហាញឲ្យឃើញ កំណែទម្រង់នេះជាដំណើរការដ៏សាំញ៉ាំ ស្មុគស្មាញ និងរសើប មិនគ្រាន់តែមានផលប៉ះពាល់មកលើរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរដ្ឋបាលមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែកំណែទម្រង់នេះក៏មានផលប៉ះពាល់ដល់ស្ថាប័ននានានៅថ្នាក់ជាតិផងដែរ។ ហេតុនេះកំណែទម្រង់នេះត្រូវការរយៈពេលវែងត្រូវឆ្លងកាត់ដំណាក់កាលបត់បែនជាច្រើន ទន្ទឹមនេះនៅតាមដំណាក់កាលនីមួយៗនៃការកែទម្រង់ទាមទារឲ្យមានការពិគ្រោះយោបល់ ការចូលរួម និងការស្រុះស្រួលគ្នាខាងនយោបាយក្នុងសង្គមទាំងមូល ហើយត្រូវតម្កល់ការប្តេជ្ញាចិត្តខាងនយោបាយ ដែលបានស្រុះស្រួលឯកភាពគ្នានោះក្នុងរយៈពេលវែងសម្រាប់គាំទ្រដំណើរការកែទម្រង់នេះអាចវិវត្តទៅមុខជាប់ជានិច្ច។

ជាលទ្ធផលដែលទទួលបានទោះបីស្ថិតនៅក្នុងស្ថានភាពដ៏លំបាកក្តីក្នុងពេលពេញមួយឆ្នាំ ២០២០នេះ ក្រោមចំណាត់ការដ៏ម៉ឺងម៉ាត់របស់ប្រមុខរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង-ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលរាជធានីភ្នំពេញ បានបន្តខិតខំបំពេញតួនាទី-ភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាពសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ តាមរយៈការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ សង្កាត់មានសុវត្ថិភាព និងបានចូលរួមទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពលើការងារប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅរាជធានីភ្នំពេញ ជាពិសេសការបិទបញ្ចប់ដោយជោគជ័យនូវ " **ព្រឹត្តិការណ៍ ៣ វិច្ឆិកា** " និង" **ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា**" ជាមួយគ្នានេះដែរ រដ្ឋបាលរាជធានីភ្នំពេញក៏បានបន្តការយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្មនូវតួនាទី និងភារកិច្ចស្នូលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី -ខេត្ត ក្រុង-ស្រុក-ខណ្ឌ គោលការណ៍ណែនាំ និង

លិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួង-ស្ថាប័នថ្នាក់ជាតិ ជាពិសេសគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលជារបៀបវារៈដ៏សំខាន់សម្រាប់ការអភិវឌ្ឍទៅតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងន័យបង្កើនជំនឿជឿជាក់របស់ប្រជាពលរដ្ឋមកលើការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល។

ទន្ទឹមទៅនឹងសមិទ្ធផល និងស្នាដៃការងារសំខាន់ៗ ដូចបានជម្រាបជូនក្នុងរបាយការណ៍នេះរដ្ឋបាលរាជធានីភ្នំពេញ ក៏បានកត់សម្គាល់ជូននូវការងារដែលនៅសេសសល់ និងបញ្ហាប្រឈមមួយចំនួនទៀតដែលស្ថិតក្នុងតួនាទី-ភារកិច្ច និងការទទួលខុសត្រូវសម្រាប់បន្តយកចិត្តទុកដាក់ដោះស្រាយជាអាទិភាពរួមមាន៖

បញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់ បញ្ហាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការប្រែប្រួលអាកាសធាតុ បញ្ហានានាក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់រាជធានីភ្នំពេញ និងការរួមគ្នាលើកកម្ពស់លើវិស័យសុខភាពសាធារណៈ ដើម្បីបង្កើនភាពធន់របស់ទីក្រុងឲ្យកាន់តែប្រសើរឡើង។

អនុសាសន៍

អនុសាសន៍

ផ្អែកលើសេចក្តីសន្និដ្ឋានខាងលើកត្តាមួយចំនួនដែលអាចជួយបង្កើនដល់ ការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ និងបុគ្គលិកក្រោមឱវាទដើម្បីអនុវត្តឲ្យបានការផ្តល់នូវសេវាសាធារណៈប្រកបដោយប្រសិទ្ធិភាពនោះ ៖

- ត្រូវរៀប ឲ្យមានយន្តការសម្របសម្រួលកម្រិតជាតិជាមួយការរៀបចំឲ្យមានក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ កម្មវិធី ផែនការអនុវត្តច្បាស់លាស់ ក្នុងការកសាងសមត្ថភាព ធនធានមនុស្ស ការផ្តល់ធនធានហិរញ្ញវត្ថុ ការផ្ទេរមុខងារ ធនធាន សិទ្ធិអំណាចជាក់លាក់ ប្រកបដោយចីរភាពដល់រដ្ឋបាលមូលដ្ឋាន។ រដ្ឋបាលមូលដ្ឋានដែលមិនមានធនធានមនុស្សប្រកបដោយសមត្ថភាព មិនមានធនធានហិរញ្ញវត្ថុសមស្រប មិនមានមុខងារ និងសិទ្ធិអំណាចជាក់លាក់ប្រៀបប្រដូច "**មនុស្សដែលមានបាតដៃទទេស្អាត**"។ ក្នុងស្ថានភាពនេះយើងមិនអាចកសាងរដ្ឋបាលមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពបានឡើយ។
- ការផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឲ្យមានការយល់ដឹង ដើម្បីលើកកម្ពស់ការចូលរួមដ៏ត្រឹមត្រូវក្នុងភាពជាម្ចាស់ពីប្រជាពលរដ្ឋក្នុងដំណើរការកំណែទម្រង់ ក៏ដូចកិច្ចការនានារបស់រដ្ឋបាលមូលដ្ឋាន គឺជាផ្នែកដ៏សំខាន់មួយក្នុងការផ្លាស់ប្តូរទម្លាប់ និងឥរិយាបទរបស់សហគមន៍នានានៅមូលដ្ឋាន។ ការលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់នៅមូលដ្ឋាន គឺជាកត្តាជំរុញឲ្យមានការរីក លូតលាស់ និងចីរភាពដល់ប្រព័ន្ធរដ្ឋបាលមូលដ្ឋានសម្រាប់រយៈពេលវែង។
- សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក៏ចាំបាច់ត្រូវមានការបកស្រាយអោយបានច្បាស់លាស់ និងពង្រឹងបន្ថែមទៀតទាំងក្នុងក្របខណ្ឌ លិខិតបទដ្ឋានគតិយុត្ត ក៏ដូចជាការអនុវត្តជាក់ស្តែង។ ការប្រាស្រ័យទាក់ទងគ្នា រវាងរដ្ឋបាលថ្នាក់រាជធានីភ្នំពេញ និងរដ្ឋបាលថ្នាក់ខណ្ឌ និងអង្គភាពពាក់ព័ន្ធ ជាកត្តាមួយសំខាន់ ជួយជំរុញអោយមានការអភិវឌ្ឍបានល្អប្រសើរ និងស្របតាមគោលដៅដែលរាជរដ្ឋាភិបាលចង់សម្រេចអោយបាន។
- ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់រដ្ឋបាលរាជធានី គឺមានសារៈសំខាន់ណាស់ដែលតាមរយៈនេះ រាជរដ្ឋាភិបាលអាចបង្កើតអោយមានមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សនៅតាមរាជធានីខេត្ត ដែលប្រមូលនូវអ្នកដែលមានសមត្ថភាពក្នុងការចូលរួមអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងចំណេះដឹងជំនាញ ការប្រើប្រាស់ព័ត៌មានវិទ្យា និងឥរិយាបថក្នុងនាមជាមន្ត្រីរាជការ រួមទាំងសមត្ថភាពជាអ្នកដឹកនាំ ដើម្បីអោយពួកគាត់មានសមត្ថភាពពេញលេញក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព ។

ផ្អែកលើការសិក្សាស្រាវជ្រាវ និងបទពិសោធន៍ខាងលើនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ប្រកបដោយភាពប្រយ័ត្នប្រយែងតាមរយៈការធ្វើបណ្តើរៀនសូត្រដកស្រង់បទពិសោធន៍បណ្តើរពីមួយជំហានទៅមួយជំហានទៀតដោយផ្អែកទៅលើ ស្ថានភាពនយោបាយ សង្គម និងសេដ្ឋកិច្ចនៅកម្ពុជា។

ឯកសារយោង

ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅ ថ្ងៃ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រកាសអោយប្រើនៅថ្ងៃ ២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លេខ នស/រកម/០៥០៨/០១៧ ២២ ឧសភា ២០០៨
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/ ០១៨ , ២៤ ឧសភា ២០០៨
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលរដ្ឋសភាអនុម័ត ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៨
- អនុក្រឹត្យលេខ: ២១៥ អនក្រ.បក ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនង ការងាររបស់ក្រុមប្រឹក្សា គណៈ អភិបាលរាជធានី និង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានី ភ្នំពេញ
- អនុក្រឹត្យលេខ ២២ អនក្រ.បក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុម ប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់ អាណត្តិទី៣
- ប្រកាសលេខ ៤២៧៣.ប្រកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃ សាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌនិងការកំណត់តួនាទី ភារកិច្ច របៀបរបប ការងារនៃការិយាល័យទាំងនោះ

ខ. សៀវភៅ និងរបាយការណ៍

- សម្តេចព្រះសង្ឃរាជ ជួន ណាត , វចនានុក្រមខ្មែរ
- ហៀង សាង ,នីតិរដ្ឋបាលទូទៅ,បោះពុម្ពលើកទី៣ ឆ្នាំ២០០១
- សាស្ត្រាចារ្យ ហៀង សាង និងអនុបណ្ឌិត ប៉ែង ឆុង ការគ្រប់គ្រងរដ្ឋបាលដែនដីឆ្នាំ (២០១២)
- សៅ ឡាយ, សេចក្តីផ្តើមរដ្ឋបាលសាធារណៈ ឆ្នាំ ២០១៤
- គ្រូឧត្តមសិក្សាជាន់ខ្ពស់ ង៉ឹយ ធឿន នីតិរដ្ឋបាល (២០១៧)
- សាស្ត្រាចារ្យ ហៀង សាង សហត្ថិភាព រដ្ឋបាលដែនដីនៃកម្ពុជា (២០១៨)

- បណ្ឌិត ឈុន ណារ៉ែត និង ខៀវ វិជ្ជានន្ទ, គោលនយោបាយសាធារណៈ និងដំណើរការធ្វើច្បាប់, ២០១៩
- ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ក្រសួងមហាផ្ទៃ ខែមករា ឆ្នាំ២០១៩
- បណ្ឌិត សៅ ឡាយ សេចក្តីផ្តើមរដ្ឋបាលសាធារណៈ បោះពុម្ពលើកទី៦
- របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ ២០២០

គ. គេហទំព័រ

- http://phnompenh.gov.kh/en/about-us/organization-chart/
- http://phnompenh.gov.kh/phnom-penh-city/
- http://phnompenh.gov.kh/public-services/

ឧបសម្ព័ន្ធ

មាតិកាឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធគតិយុត្តិ

ឧបសម្ព័ន្ធទី១ ៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/ ០៥០៨/ ០១៧, ២២ ឧសភា ២០០៨

ឧបសម្ព័ន្ធទី២ ៖ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៨ , ២៤ ឧសភា ២០០៨

ឧបសម្ព័ន្ធទី៣ ៖ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ឧបសម្ព័ន្ធទី៤ ៖ អនុក្រឹត្យលេខ: ២១៥ អនក្រ.បក ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី៥ ៖ អនុក្រឹត្យលេខ ២២ អនក្រ.បក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌសម្រាប់អាណត្តិទី៣

ឧបសម្ព័ន្ធទី៦ ៖ ប្រកាសលេខ ៤២៧៣.ប្រក ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

២. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១ ៖ ផែនទីរាជធានីភ្នំពេញ និងរដ្ឋបាលសាលារាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី២ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី៣ ៖ រូបភាពសកម្មភាពការងារ និងសមិទ្ធផលរបស់សាលារាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី៤ ៖ កម្រងរូបភាពចុះស្រាវជ្រាវឯកសារ

ឧបសម្ព័ន្ធគតិយុត្តិ

``

ឧបសម្ព័ន្ធទី១

``

ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិន្ទាតិសាសនា រក្ខគខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានអនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ច្បាប់

ស្តីពី

ការគ្រប់គ្រងរដ្ឋបាល

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ជំពូកទី ១

អំពីបទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ២.-

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពផល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយរឹមជ្ឈការ និងវិសហមជ្ឈការ ។

មាត្រា ៣.-

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

មាត្រា ៤.-

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

មាត្រា ៥.-

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

មាត្រា ៦.-

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE
MINISTERE DU PALAIS

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៧.-

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៨.-

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

មាត្រា ៩.-

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

មាត្រា ១០.-

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

មាត្រា ១១.-

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

មាត្រា ១២.-

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

ROYAUME du CAMBODGE
MINISTERE du PALAIS ROYAL

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬ បទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

មាត្រា ២៣.-

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសក្នុងរយៈពេលយ៉ាងយូរដប់ប្លន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២៤.-

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ២៥.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម :

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីរយសែសិប (២៤០) ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំសាយតាមលំដាប់ណាដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០) ថ្ងៃ ។

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

មាត្រា ២៦.-

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

មាត្រា ២៧.-

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

មាត្រា ២៨.-

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ផ្នែកទី ២

តួនាទី តារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

មាត្រា ២៩.-

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ ។

មាត្រា ៣០.-

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងរដ្ឋបាល ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ៣១.-

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។

មាត្រា ៣២.-

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើជីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

មាត្រា ៣៣.-

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

មាត្រា ៣៤.-

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

មាត្រា ៣៥.-

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

មាត្រា ៣៦.-

ស្របតាមរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬ ជីកាតាមការចាំបាច់ ដែលមិនផ្ទុយនឹង :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ជាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងផែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

មាត្រា ៣៧.-

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

មាត្រា ៣៨.-

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

ROYAUME DU CAMBODGE LE MINISTRE DE PALAIS ROYAL

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

មាត្រា ៣៩.-

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ(១២)ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣)ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ស្ថិតនាការបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យ ដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

មាត្រា ៤០.-

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

មាត្រា ៤១.-

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

មាត្រា ៤២.-

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

មាត្រា ១៣៩.-

គណៈអភិបាលរួមមាន ប្រធានមួយរូប ដែលហៅថា អភិបាល និងអភិបាលរងមួយចំនួន ។

មាត្រា ១៤០.-

គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប ។

គណៈអភិបាលខេត្តមានចំនួនពីបី(០៣)រូប ទៅប្រាំពីរ(០៧)រូប ។

គណៈអភិបាលក្រុង ស្រុក ខណ្ឌមានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប ។

ចំនួនជាក់ស្តែងនៃគណៈអភិបាល សម្រាប់ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៤១.-

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៤២.-

អភិបាលរាជធានី អភិបាលខេត្ត ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ដែលមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានឋានន្តរសក្តិឧត្តមមន្ត្រី

-មានអាយុចាប់ពីសាមសិបប្រាំ(៣៥)ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង

-មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចចំនួនប្រាំពីរ(០៧)ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

ផ្នែកទី ២

នាយករដ្ឋបាល

មាត្រា ១៨៣.-

ក្រុមប្រឹក្សានីមួយៗ ត្រូវមាននាយករដ្ឋបាលមួយរូបដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៨៤.-

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

ក្នុងតួនាទីខាងលើនេះ នាយករដ្ឋបាលត្រូវធ្វើសេចក្តីរាយការណ៍ និងមានគណនេយ្យភាព ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន ។

មាត្រា ១៨៥.-

នាយករដ្ឋបាល មានតួនាទី ភារកិច្ចដូចខាងក្រោម :

-អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល

-ធានាឱ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន

-អនុវត្តជីការបស់ក្រុមប្រឹក្សា

-ចូលរួម និងមានយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ

-ផ្តល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

-ផ្តល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

មាត្រា ២៧៣.-

បែបបទ និងនីតិវិធីនៃការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

ជំពូកទី ៦
អំពីទោសប្បញ្ញត្តិ

មាត្រា ២៧៤.-

សមាជិកក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលវិន័យដោយមិនទាន់គិតផល់ទោស ព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

មាត្រា ២៧៥.-

វិន័យដែលត្រូវអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាដែលបានប្រព្រឹត្តនូវកំហុស ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៤ ចំណុចទី ៥ មាត្រា ២២ នៃច្បាប់នេះ ។

មាត្រា ២៧៦.-

វិន័យដែលត្រូវអនុវត្ត ចំពោះគណៈអភិបាល នាយករដ្ឋបាល បុគ្គលិកក្រុមប្រឹក្សា ត្រូវផ្អែកតាមគោលការណ៍នៃបទប្បញ្ញត្តិដូចមានចែងក្នុងចំណុចទី ៣ និងចំណុចទី ៦ មាត្រា ១៥១ នៃច្បាប់នេះ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលក្ខន្តិកៈដោយឡែករបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

ជំពូកទី ៧

អំពីអន្តរប្បញ្ញត្តិ

ផ្នែកទី ១

ការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវ

មាត្រា ២៧៧.-

រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌដែលត្រូវបានបង្កើតឡើងដោយច្បាប់នេះនឹងជំនួសរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលបច្ចុប្បន្ននេះ ។

មាត្រា ២៧៨.-

អភិបាលរាជធានី អភិបាលខេត្ត អភិបាលក្រុង អភិបាលខណ្ឌ អភិបាលស្រុកដែលបានតែងតាំងឡើងនៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តស្ថិតក្នុងមុខតំណែងនិងបំពេញការងាររហូតដល់មានក្រុមប្រឹក្សា និងគណៈអភិបាលដែលបានរៀបចំឡើងស្របតាមច្បាប់នេះមកជំនួស ។

មាត្រា ២៧៩.-

ការតែងតាំងគណៈអភិបាលសម្រាប់ក្រុមប្រឹក្សាអាណត្តិទី ១ នេះ ត្រូវធ្វើឡើងយ៉ាងយូរដប់ប្លន(១៤)ថ្ងៃ បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត “គ.ជ.ប.” ប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗនោះ ។

មាត្រា ២៨០.-

ជីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ទាំងអស់ដែលអនុវត្ត ឬដែលបានកាន់កាប់ដោយ ឬក្នុងនាមរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ជីកា លិខិតបទដ្ឋាន កិច្ចសន្យា កិច្ចព្រមព្រៀង ការងារ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ទាំងអស់នោះត្រូវអនុវត្ត និងចាត់ចែងបន្តដោយរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

មាត្រា ២៨១.-

អង្គភាព និងមន្ត្រីបុគ្គលិកដែលបំពេញការងារក្នុងអង្គភាពរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តជាអង្គភាព និងជាមន្ត្រីបុគ្គលិកនៃអង្គភាពទាំងនោះរបស់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រហូតដល់មានការរៀបចំជាថ្មី ។

មាត្រា ២៨២.-

ក្រសួងមហាផ្ទៃ ត្រូវធ្វើការកំណត់ និងកត់ត្រានូវការផ្ទេរ និងការទទួលយកនូវសិទ្ធិ កាតព្វកិច្ចទាំងអស់ កម្មសិទ្ធិ ទ្រព្យសម្បត្តិ ចំណូល និងប្រាក់ ព្រមទាំងអង្គភាព បុគ្គលិក ពីរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នជូនទៅរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ឱ្យបានសមស្រប និងមានតម្លាភាព ។

ផ្នែកទី ២
ក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា ២៨៣.-

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបន្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា លើកលែងតែគោលការណ៍ដូចមានចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍នៃជំពូកទី ៥ នៃច្បាប់នេះ ។

មាត្រា ២៨៤.-

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវរៀបចំលិខិតបទដ្ឋានសម្រាប់គាំទ្រឃុំ សង្កាត់ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨៨ គោលការណ៍នៃផ្នែកទី ៦ ផ្នែកទី ៧ ផ្នែកទី ៨ ផ្នែកទី ៩ នៃជំពូកទី ២ និងគោលការណ៍នៃជំពូកទី ៥ នៃច្បាប់នេះ ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ២៨៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៨៦.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨

ព្រះហស្តលេខា និងព្រះរាជលញ្ឆកររ

នរោត្តម សីហមុនី

៣រ.ល.០៧០៥.៥៩៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ៥៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃួង ជិនកេន

ឧបសម្ព័ន្ធទី២

ច្បាប់

ស្តីពី

ការបោះឆ្នោតជ្រើសរើស

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខគខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាថនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុភមង្គលា សិរីតិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹស្សលេខ នស/រកត/០៣០៤/១២៤ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បានអនុម័តកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE D. PALAIS ROYAL

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំ ការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការ ចោះឆ្នោតអសកល ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយដែលក្នុងច្បាប់នេះហៅកាត់ថា "ក្រុមប្រឹក្សា" ។

មាត្រា ២.-

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មី ចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុត កំណត់នៅថ្ងៃចោះឆ្នោតបន្ទាប់ ។

មាត្រា ៣.-

បទប្បញ្ញត្តិទូចមានចែងនៅក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជ-ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកមកអនុវត្តសម្រាប់កំណត់ចំនួនសមាជិកក្រុមប្រឹក្សា នីមួយៗ ។

មាត្រា ៤.-

សមាជិកក្រុមប្រឹក្សាត្រូវជ្រើសរើសឡើង ដោយការចោះឆ្នោតអសកល មិនចំចោះ ដោយសើរ ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

មាត្រា ៥.-

ការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើតែមួយថ្ងៃ នៅថ្ងៃអាទិត្យណាមួយ ។

កាលបរិច្ឆេទជាក់ស្តែងនៃការចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវកំណត់ដោយនាយក-រដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងកាលៈដែលសមាជិកទាំងអស់របស់ក្រុមប្រឹក្សាណាមួយលាលែងពីមុខតំណែង ឬ ត្រូវបានបាត់បង់ក្នុងកំឡុងពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា គណៈកម្មាធិការជាតិរៀបចំការ

មាត្រា ១១.-

ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបង្កើតគណៈកម្មការរៀបចំការបោះឆ្នោតសម្រាប់រាជធានី ឬ ខេត្ត ឬ ក្រុង ឬ ស្រុក ឬ ខណ្ឌ ។

មាត្រា ១២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំតាក់តែងបទបញ្ជានិងនីតិវិធីដែលទាក់ទងទៅនឹងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដោយអនុលោមទៅតាមគោលការណ៍នៃច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ផ្នែកទី ២
ប្រព័ន្ធបោះឆ្នោត និងរូបមន្ត

មាត្រា ១៣.-

ក. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយត្រូវបែងចែកអាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដែលផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌល តាមជំហានទាំងឡាយដូចខាងក្រោម :

ជំហានទី ១ : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈមួយដោយយកចំនួនសន្លឹកឆ្នោតបានការសរុបមកចែកនឹងចំនួនអាសនៈសរុបរបស់ក្រុមប្រឹក្សា តាមរូបមន្តដូចខាងក្រោម :

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ :

-$\text{ក}_{\text{ត}}$: តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់ ២ ខ្ទង់ក្រោយក្បៀស ។

-$\text{ស}_{\text{ស}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជនផ្នែកនីតិបុគ្គលនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

ថ្នាក់ សម្រាប់រយៈពេលដប់(១០)ឆ្នាំ ចាប់ពីសម័យចោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

មាត្រា ៨៧.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត និង/ឬ ត្រូវលុបឈ្មោះចេញពីបញ្ជីចោះឆ្នោត ចំពោះជនណា ឬ គណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤៥ នៃច្បាប់នេះ ឬ មាត្រា ៧៦ នៃច្បាប់ស្តីពីការចោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ៨៨.-

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៧ និងបទប្បញ្ញត្តិនៃមាត្រា ៧៨ នៃច្បាប់ស្តីពីការចោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីដែលនៅតែពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះពីបញ្ជីចោះឆ្នោតសម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋចាលចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់បណ្តេញចេញពីមុខតំណែងនិង/ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀលដល់ពីរលាន(២.០០០.០០០) រៀល ។

ជំពូកទី ៥
អំពីអន្តរប្បញ្ញត្តិ

មាត្រា ៨៩.-

កាលបរិច្ឆេទនៃការចោះឆ្នោតលើកទី ១ដើម្បីជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើឡើងក្នុងរយៈពេលដប់ពីរ(១២)ខែយ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

មាត្រា ៩០.-

ដើម្បីចោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាលើកទី ១ ចំនួនសមាជិកក្រុមប្រឹក្សា ត្រូវ

កំណត់ក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០)ថ្ងៃមុនថ្ងៃបោះឆ្នោត ដោយអនុលោមតាម
មាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ជំពូកទី ៦

អវសានប្បញ្ញត្តិ

មាត្រា ៥១.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥២.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅវិមានព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ នវម្ភៈ ឆ្នាំ ២០០៨

ព្រះហស្តលេខា និងព្រះរាជលញ្ជកា

នរោត្តម សីហមុនី

៣៨.០៧០៥.៦០០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ៥៥១ ច.ល
ដែលបានចុះចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៨
ប្រធានរដ្ឋសភាព្រះរាជាណាចក្រកម្ពុជា

ហេង សំរិន

ឧបសម្ព័ន្ធទី៣

``

ក្រុមប្រឹក្សាស្តេចច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ: 184
ថ្ងៃ: អង្គារ៍ ទី 3 ខែ កក្កដា ឆ្នាំ 2018
ម៉ោង: 15:40 ល្ងាច

នស/រកម/០៦១៨/ ០ ៧ ២

ព្រះរាជក្រម

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហនភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិឡ្ហាធរាមហាក្សត្រ
ខេមរាជនា សម្ភូហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៥០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៩៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៥/សម.រ.ធ/២០១៨ កបធ.ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ហើយដែលមានសេចក្តីទាំងស្រុងជូចដូច្នេះ

ច្បាប់

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅ

នៃគណៈរដ្ឋមន្ត្រី

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ច្បាប់នេះមានគោលបំណងជានាប្រសិទ្ធភាពការងាររបស់គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអង្គការនីតិប្រតិបត្តិដូចបានបញ្ញត្តនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២ .-

ច្បាប់នេះមានគោលដៅកំណត់អំពីសមាសភាព សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៣ .-

ច្បាប់នេះមានវិសាលភាពអនុវត្តទៅលើអង្គការនីតិប្រតិបត្តិ ។

ជំពូកទី ២
សមត្ថកិច្ច និងសមាសភាពគណៈរដ្ឋមន្ត្រី

មាត្រា៤ .-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការនីតិប្រតិបត្តិ មានសមត្ថកិច្ចកំណត់និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ ។ រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិនិងអង្គការតុលាការ ។

មាត្រា៥ .-

រាជរដ្ឋាភិបាលដឹកនាំកិច្ចការទូទៅរបស់រដ្ឋស្របតាមកម្មវិធីនយោបាយរបស់ខ្លួន ។

មាត្រា៦ .-

រាជរដ្ឋាភិបាលត្រូវការពារនីតានុកូលភាព ជានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

មាត្រា៧ .-

រាជរដ្ឋាភិបាលគ្រប់គ្រង ដឹកនាំ បញ្ជា ប្រើប្រាស់រដ្ឋបាលសាធារណៈគ្រប់ថ្នាក់ រួមទាំងកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងកម្លាំងប្រដាប់អាវុធផ្សេងៗទៀត ក្នុងការធ្វើសកម្មភាពរបស់ខ្លួន ។

មាត្រា៨ .-

សមាសភាពនៃរាជរដ្ឋាភិបាលមាន ៖

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី
- រដ្ឋមន្ត្រី
- រដ្ឋ... ។

ROYAUME DU CAMBODGE ROYAL PALACE MINISTRE DU PALAIS

មាត្រា៩ ._

នាយករដ្ឋមន្ត្រីជាសមាជិករដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលឯទៀតអាចជ្រើសរើសយកក្នុងចំណោមសមាជិករដ្ឋសភា ឬក្រៅសមាជិករដ្ឋសភា ប៉ុន្តែត្រូវជាសមាជិកគណបក្សមានតំណាងនៅក្នុងរដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្ត ។

មាត្រា១០ ._

មុខងារនៃសមាជិករាជរដ្ឋាភិបាលមានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ការធ្វើអាជីវកម្មគ្រប់ប្រភេទ ឬការកាន់មុខតំណែងជាថ្នាក់ដឹកនាំ ឬគណៈគ្រប់គ្រង ឬសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនសហគ្រាស ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

មាត្រា១១ ._

នៅពេលផុតនីតិកាលរបស់រដ្ឋសភាឬពេលផ្លាស់ប្តូររាជរដ្ឋាភិបាល រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានការកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង ។

មាត្រា១២ ._

នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលនៅក្នុងមុខតំណែង ត្រូវទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញការកិច្ចដែលកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៣

គណៈរដ្ឋមន្ត្រី សមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល

មាត្រា១៣ ._

គណៈរដ្ឋមន្ត្រីទទួលខុសត្រូវរួមចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល ។

នាយករដ្ឋមន្ត្រី ជាប្រមុខរាជរដ្ឋាភិបាល ដឹកនាំ បញ្ជារាល់សកម្មភាពការងាររបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ។

មាត្រា១៤ ._

នាយករដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ។

អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រីមានអង្គប្រជុំធំ និងអង្គប្រជុំពិនិត្យស្រាវជ្រាវ ។

រាល់អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ត្រូវមានកំណត់ហេតុ ។

មាត្រា១៥ ._

អង្គប្រជុំធំ គឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។

នាយករដ្ឋមន្ត្រីអាចអញ្ជើញអ្នកពាក់ព័ន្ធនានាចូលរួមក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី តាមការចាំបាច់ ។

នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

មាត្រា១៦ ._

នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់កោះប្រជុំនិងធ្វើជាអធិបតីនៃអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសម្រេចកិច្ចការគាងនាមរាជរដ្ឋាភិបាលឡើយ ។

មាត្រា១៧ ._

នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ សន្តិសុខជាតិ និងវិស័យផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនណាម្នាក់ជាអ្នកចរចា និងចុះហត្ថលេខា ។

បែបបទ និងនីតិវិធីនៃការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា១៨ ._

នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និងសារាចរបស់រាជរដ្ឋាភិបាល ។ លិខិតបទដ្ឋានគតិយុត្តនានាដែលមានអានុភាពទូទៅរបស់រាជរដ្ឋាភិបាល ត្រូវចុះក្នុងរាជកិច្ច ។

មាត្រា១៩ ._

នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំរដ្ឋសភា ដើម្បីកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

នាយករដ្ឋមន្ត្រីលើកសំណើជូនរដ្ឋសភា ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់ ។

មាត្រា២០ ._

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ ដើម្បីបញ្ចប់មុខតំណែងសមាជិករាជរដ្ឋាភិបាលដោយព្រះរាជក្រឹត្យ ។

មាត្រា២១ ._

នាយករដ្ឋមន្ត្រីលើកសំណើផ្លាស់ប្តូរ និងជំនួសសមាជិករាជរដ្ឋាភិបាលជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្ត ។ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយ សមាជិករាជរដ្ឋាភិបាលនោះត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

មាត្រា២២ ._

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងនៅតាមក្រសួង ស្ថាប័ននានា ដោយព្រះរាជក្រឹត្យ ។

មាត្រា២៣ ._

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមុខតំណែងមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដូចខាងក្រោម ៖

- ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល

ROYAUME DU CAMBODGE • MINISTERE DU PALAIS ROYAL •

- ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
- អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការនគរបាលជាតិ

មុខតំណែង និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិចាប់ពីថ្នាក់ឧត្តមសេនីយ៍ឡើង ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ការកិច្ចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ស្របតាមបទប្បញ្ញត្តិជាធរមាន ។

មាត្រា២៤ .-

នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ការកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ ដែលមិនមានចែងក្នុងមាត្រា២៣ លើកលែងតែមន្ត្រីដែលមានចែងក្នុងកថាខណ្ឌទី២ មាត្រា៤៦ នៃច្បាប់នេះ ។

មាត្រា២៥ .-

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់គោរមងារដល់ឥស្សរជន វរជន ឬសប្បុរសជនណាមួយ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

មាត្រា២៦ .-

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់ ឬអាចផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិ ឥស្សរជន វរជន ឬសប្បុរសជន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

មាត្រា២៧ .-

នាយករដ្ឋមន្ត្រី អាចលើកសំណើផ្តល់ងារកិត្តិយសជាប្រតិភូរាជរដ្ឋាភិបាលដល់ឥស្សរជនណាមួយដោយព្រះរាជក្រឹត្យ ។

មាត្រា២៨ .-

ក្នុងករណីពិសេស ឬប្រធានសក្តិ នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់និងបន្ទាន់ រួចហើយត្រូវរាយការណ៍សុំការអនុម័តពីអង្គការនីតិប្បញ្ញត្តិ ស្របតាមបទប្បញ្ញត្តិជាធរមាន ។

មាត្រា២៩ .-

ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រី១(មួយ)រូប ទទួលការងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។

មាត្រា៣០ .-

ឧបនាយករដ្ឋមន្ត្រីជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនានុក្រមលើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ។

ឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រី តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី ។ កិច្ចការដែលទាក់ទងនឹងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីមិនអាចសម្រេចឡើយ ។

មាត្រា៣១ ._

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំ គ្រប់គ្រងក្រសួង ហៅថា រដ្ឋមន្ត្រី ។

សមាជិករាជរដ្ឋាភិបាលដែលមិនដឹកនាំក្រសួង ត្រូវទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី ។

មាត្រា៣២ ._

នាយករដ្ឋមន្ត្រី និងសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មានឧទ្ធកាល័យរបស់ខ្លួនមួយនិងមានទីប្រឹក្សា ជំនួយការ លេខាធិការដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

មាត្រា៣៣ ._

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីអំពើដែលខ្លួនបានប្រព្រឹត្ត ។

នាយករដ្ឋមន្ត្រីត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្ត និងការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ហើយមានសិទ្ធិដក និងដាក់ជំនួសសមាជិករាជរដ្ឋាភិបាលតាមបែបបទនិងនីតិវិធីជាធរមាន ។

ជំពូកទី ៤
ទីស្តីការគណៈរដ្ឋមន្ត្រី

មាត្រា៣៤ ._

ត្រូវបានបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និងចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា៣៥ ._

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញការកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា៣៦ ._

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

តួនាទី ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

មាត្រា៣៧ ._

ទីស្តីការគណៈរដ្ឋមន្ត្រីអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

មាត្រា៣៨ ._

រៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រីត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៥
ការបង្កើតក្រសួង

មាត្រា៣៩ ._

ការបង្កើតក្រសួងត្រូវកំណត់ដោយច្បាប់ ។

ក្រសួងនីមួយៗត្រូវអនុវត្តសមត្ថកិច្ចស្របតាមច្បាប់ដែលបង្កើតក្រសួងនោះ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់នាយកដ្ឋានឡើង ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស ។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងក្រសួងពីរ ឬច្រើន គណៈរដ្ឋមន្ត្រីត្រូវពិនិត្យ និងសម្រេច ។

មាត្រា៤០ ._

រដ្ឋមន្ត្រីដឹកនាំការងារក្នុងក្រសួង និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន ។

មាត្រា៤១ ._

រដ្ឋមន្ត្រីមានការកិច្ចដឹកនាំ គ្រប់គ្រងក្រសួង និងអង្គភាពចំណុះក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់ ។

មាត្រា៤២ ._

នៅពេលដែលរដ្ឋមន្ត្រីណាម្នាក់អវត្តមាន ឬមានការកិច្ចមិនអាចដឹកនាំ គ្រប់គ្រងក្រសួងបានជាបណ្តោះអាសន្ន រដ្ឋលេខាធិការប្រចាំការដូចមានចែងក្នុងមាត្រា៤៨ នៃច្បាប់នេះ ត្រូវទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ក្រសួង ក្នុងហានៈជារដ្ឋមន្ត្រីស្តីទី រហូតដល់មានវត្តមានរដ្ឋមន្ត្រីនៃក្រសួងសាមី ។ ក្នុងករណីដែលរដ្ឋលេខាធិការប្រចាំការ មិនអាចបំពេញតួនាទីជារដ្ឋមន្ត្រីស្តីទីបាន រដ្ឋមន្ត្រីអាចចាត់តាំងរដ្ឋលេខាធិការផ្សេងទៀតជារដ្ឋមន្ត្រីស្តីទី ។

រដ្ឋមន្ត្រីស្តីទីមិនមែនជាសមាជិករាជរដ្ឋាភិបាលហើយត្រូវអនុវត្តសិទ្ធិអំណាចតាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី ។

ក្នុងករណីដែលមានកិច្ចការចាំបាច់តាមរដ្ឋធម្មនុញ្ញ និងច្បាប់តម្រូវឱ្យរដ្ឋមន្ត្រីជាអ្នកបំពេញតួនាទីនោះ នាយករដ្ឋមន្ត្រីចាត់តាំងសមាជិករាជរដ្ឋាភិបាលណាម្នាក់ ដើម្បីបំពេញកិច្ចការនោះជំនួសឱ្យរដ្ឋមន្ត្រីដែលអវត្តមាន ។

តួនាទី ការកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទីត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៤៣ ._

ក្រសួងនីមួយៗមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញការកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីនៃក្រសួងសាមី ។

មាត្រា៤៤ ._

ក្រសួងនីមួយៗមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងសាមី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ក្រសួង ។

តួនាទី ការកិច្ចរបស់រដ្ឋលេខាធិការប្រចាំការត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

មាត្រា៤៥ ._

ក្រសួងនីមួយៗអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

មាត្រា៤៦ ._

រដ្ឋមន្ត្រីមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមាន ចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រដ្ឋមន្ត្រីមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រាជរដ្ឋាភិបាល អាចចេញអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួងដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា៤៧ ._

រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំ ។

ប្រកាស សេចក្តីសម្រេច សារាចរ ឬសេចក្តីណែនាំរបស់ក្រសួង មិនអាចចែងអំពីកិច្ចការដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ: ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលឡើយ ។

ជំពូកទី ៦

ការបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា

មាត្រា៤៨ ._

រាជរដ្ឋាភិបាលអាចលើកសំណើបង្កើត ឬអាចបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា តាមការចាំបាច់ ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

មាត្រា៤៩ ._

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ: មិនមានក្របខ័ណ្ឌមន្ត្រីរាជការដោយឡែករបស់ខ្លួនឡើយ ។ មន្ត្រីរាជការដែលបំពេញការងារនៅក្នុងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ត្រូវជ្រើសយកពីក្របខ័ណ្ឌមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី និង/ឬក្រសួងពាក់ព័ន្ធ លើកលែងតែមានកំណត់ក្នុងច្បាប់ដោយឡែក ។

ប្រធានស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា មានសិទ្ធិលើកសំណើតែងតាំង ឬមានសិទ្ធិតែងតាំង ផ្លាស់ប្តូរមន្ត្រីរាជការរបស់ខ្លួន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ: មានសមត្ថកិច្ចដូចមានកំណត់នៅក្នុងច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៥0 ._

នាយករដ្ឋមន្ត្រីអាចចាត់តាំងសមាជិករាជរដ្ឋាភិបាល១(មួយ)រូប ឱ្យទទួលដឹកនាំ គ្រប់គ្រងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើងស្របតាមមាត្រា៤៨ នៃច្បាប់នេះ ។

ជំពូកទី ៧
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា និងជំនួយការ

មាត្រា៥១ ._

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើអគ្គនាយកឡើងទៅ ។

មាត្រា៥២ ._

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សា និងជំនួយការនាយករដ្ឋមន្ត្រី បំពេញការកិច្ចតាមការប្រគល់ពីនាយករដ្ឋមន្ត្រី ។

មាត្រា៥៣ ._

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ហើយក៏មិនមែនជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ដែរ ។

នៅពេលណាដែលរាជរដ្ឋាភិបាលចប់អាណត្តិ ឬលាលែង ឬត្រូវបានទម្លាក់ដោយរដ្ឋសភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ដូចមានចែងក្នុងមាត្រា៣២ មាត្រា៣៧ មាត្រា៤៥ និងមាត្រា៥២ នៃច្បាប់នេះ ក៏ត្រូវអស់តំណែងដែរ ។

មាត្រា៥៤ ._

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ នៅក្នុងមុខតំណែង ទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញការកិច្ច ។

ប្រាក់បំណាច់មុខងារនៃរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

ជំពូកទី ៨
អន្តរប្បញ្ញត្តិ

មាត្រា៥៥ ._

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ៣ក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/0613/012 ចុះថ្ងៃទី ២0 ខែ មិថុនា ឆ្នាំ2013

ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ជំពូកទី៩
អវសានប្បញ្ញត្តិ

មាត្រា៥៦ .-

ច្បាប់នេះត្រូវយកទៅអនុវត្តចាប់ពីនីតិកាលទី៦ នៃរដ្ឋសភាតទៅ ។

មាត្រា៥៧ .-

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ និងច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

មាត្រា៥៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៥៩ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេដ្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨

ត្រាសាស. ១៨០៦.៦៨១

ព្រះហស្តលេខា និងព្រះរាជលញ្ជការ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមទ្បាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា
សម្តេចក្រឡាហោម ស ខេង

ឧបនាយករដ្ឋមន្ត្រីប្រចាំការ
និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា
កិត្តិនីតិកោសលបណ្ឌិត ចិន ឈិន
លេខ:៦៩១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃសុក្រ ២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ឧបសម្ព័ន្ធទី៤

``

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៤.អន.ប្រ

អនុក្រឹត្យ

ស្តីពី

តួនាទី តារាងចំនួន និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

មាត្រា ១០.-

ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកានិងសេចក្តីសម្រេចនានា ក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្ត ដោយមានការតាមដាននិងវាយតម្លៃជាប្រចាំ។

មាត្រា ១១.-

កិច្ចប្រជុំក្រុមប្រឹក្សារាជធានីភ្នំពេញអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

សេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ។

មាត្រា ១២.-

ក្រុមប្រឹក្សារាជធានីភ្នំពេញអាចចាត់ឱ្យគណៈកម្មាធិការណាមួយឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកាឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះគណៈអភិបាលរាជធានីត្រូវដឹកនាំនាយករដ្ឋបាលសាលារាជធានីនិងទីចាត់ការពាក់ព័ន្ធនៃសាលារាជធានី ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

គណៈអភិបាលរាជធានីភ្នំពេញ ដោយមាននាយករដ្ឋបាលសាលារាជធានីជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ទីចាត់ការនានានៃសាលារាជធានី រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានីពិនិត្យ ពិភាក្សា និងអនុម័ត។

អភិបាលរាជធានីភ្នំពេញត្រូវណែនាំនាយករដ្ឋបាលសាលារាជធានី ឱ្យរៀបចំដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួច ឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សារាជធានីចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលរាជធានីភ្នំពេញ។

ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវចាត់ឱ្យអភិបាលរាជធានីចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកាឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

មាត្រា ១៣.-

ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលរាជធានីភ្នំពេញ លើ :

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សារាជធានីបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារាជធានី
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សារាជធានី
- សំណើដកហូតអភិបាលរាជធានីឬអភិបាលរងរាជធានីចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សារាជធានី តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សារាជធានី
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារាជធានីរយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សារាជធានី
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលរាជធានីភ្នំពេញត្រូវជួយក្រុមប្រឹក្សារបស់ខ្លួន ក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

មាត្រា ១៤.-

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលរាជធានី និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សារាជធានី
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការ ដែលស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំនិងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលរាជធានី
- បញ្ជាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សារាជធានី
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សារាជធានី

- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សារាជធានី ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សារាជធានី
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានី
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

មាត្រា ១៥.-

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សារាជធានីភ្នំពេញអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន :

- ការកោះអញ្ជើញអភិបាលរាជធានី ឬអភិបាលរងរាជធានី ឬគណៈអភិបាលរាជធានី ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជធានី ឬហេតុការណ៍ណាមួយដែលកើតមានក្នុងរាជធានីភ្នំពេញ ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលរាជធានីភ្នំពេញ
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សារាជធានីយល់ថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលរាជធានីអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យស្រាវជ្រាវនិងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សារាជធានី ឬសមាជិកក្រុមប្រឹក្សារាជធានី ឬគណៈអភិបាលរាជធានី ឬអភិបាលរាជធានី ឬអភិបាលរងរាជធានី ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សារាជធានីតាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- ការពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលរាជធានី
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សារាជធានីនិងគណៈអភិបាលរាជធានីយល់ឃើញថាចាំបាច់។

មាត្រា ១៦.-

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សារាជធានីត្រូវចាត់ឱ្យអភិបាលរាជធានីធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សារាជធានីពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនេះ។

ក្នុងករណីកិច្ចការណាមួយដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទនិងនីតិវិធីដែរ ប៉ុន្តែបែបបទនិងនីតិវិធីនោះ ចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សារាជធានីមិនអាចអនុវត្តបាន ក្រុមប្រឹក្សារាជធានីត្រូវចាត់ឱ្យគណៈអភិបាលរាជធានីធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។

មាត្រា ១៧.-

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សារាជធានីភ្នំពេញបានសម្រេចរួចហើយ គណៈអភិបាលរាជធានីភ្នំពេញត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាលរាជធានីត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី ដូចមានចែងក្នុងមាត្រា១៤និងមាត្រា១៥នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សារាជធានីត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលរាជធានី ដើម្បីធានាថាគណៈអភិបាលរាជធានីអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សារាជធានី។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សារាជធានីក្នុងការរៀបចំនូវប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សារាជធានី។

ក្រុមប្រឹក្សារាជធានីអាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង តាមការចាំបាច់ឬតាមសំណើរបស់គណៈកម្មាធិការឬគណៈអភិបាលរាជធានី។

មាត្រា ២១.-

គណៈអភិបាលរាជធានីភ្នំពេញអាចស្នើសុំក្រុមប្រឹក្សារាជធានី ដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សារាជធានីបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលរាជធានី។

មាត្រា ២២.-

ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

មាត្រា ២៣.-

ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវណែនាំឱ្យគណៈអភិបាលរាជធានីផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សារាជធានីបានបង្កើតឡើង។

មាត្រា ២៤.-

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលរាជធានី ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនក្រុមប្រឹក្សារាជធានី។

ក្រុមប្រឹក្សារាជធានីអាចតម្រូវឱ្យគណៈកម្មាធិការណាមួយ រាយការណ៍ដោយផ្តាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

ផ្នែកទី៣

គណៈអភិបាលរាជធានីភ្នំពេញ

មាត្រា ២៥.-

រាជធានីភ្នំពេញត្រូវមានគណៈអភិបាលរាជធានីមួយ ដែលរួមមានអភិបាលរាជធានី អភិបាលរងរាជធានី ដែលត្រូវបានតែងតាំងឡើង ស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា ២៦.-

អភិបាលរាជធានីភ្នំពេញ អភិបាលរងរាជធានីភ្នំពេញ មិនមែនជាសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញឡើយ។

មាត្រា ២៧.-

គណៈអភិបាលរាជធានីភ្នំពេញត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

មាត្រា ២៨.-

គណៈអភិបាលរាជធានីភ្នំពេញមានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សារាជធានីភ្នំពេញ និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ទាំងសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ។

មាត្រា ២៩.-

គណៈអភិបាលរាជធានីភ្នំពេញត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សារាជធានីអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សារាជធានី ដើម្បីក្រុមប្រឹក្សារាជធានីធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សារាជធានី និងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រនិងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឬបានផ្ទេរ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការឬការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរសក្តិ និងការបញ្ឈប់បុគ្គលិក
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សារាជធានី
- ការកំណត់នីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សារាជធានី
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី និងបុគ្គលិករបស់ក្រុមប្រឹក្សារាជធានី

មាត្រា ៤៦.-

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ មានសិទ្ធិចូលរួមនិងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សារាជធានី កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សារាជធានី និងកិច្ចប្រជុំគណៈអភិបាលរាជធានី ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលារាជធានីជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សារាជធានី ។

មាត្រា ៤៧.-

ក្នុងការចូលរួមក្នុងកិច្ចប្រជុំដូចមានចែងក្នុងមាត្រា៤៦នៃអនុក្រឹត្យនេះនិងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលារាជធានីភ្នំពេញអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សារាជធានី គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរបស់ខ្លួន អំពីបញ្ហាច្បាប់ និងបច្ចេកទេស ដើម្បីថានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី និងអភិបាលរាជធានី មានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលារាជធានី ។

មាត្រា ៤៨.-

ដោយមានការដឹកនាំ ណែនាំពីគណៈអភិបាលរាជធានី និងអភិបាលរាជធានី នាយករដ្ឋបាលសាលារាជធានីត្រូវធានាឱ្យនាយកទីចាត់ការ មន្ត្រី បុគ្គលិកទាំងអស់ អនុវត្តការងារឱ្យបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានានិងការសម្រេចរបស់ក្រុមប្រឹក្សានិងគណៈអភិបាលរបស់ខ្លួន ។

មាត្រា ៤៩.-

គណៈអភិបាលរាជធានីឬអភិបាលរាជធានី អាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលសាលារាជធានី ឱ្យលើកយោបល់លើកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាលរាជធានី ឬអភិបាលរាជធានីពិនិត្យ សម្រេចតាមការចាំបាច់ ។

ផ្នែកទី៥

សាលារាជធានីភ្នំពេញនិងទីចាត់ការចំណុះនានា

មាត្រា ៥០.-

សាលារាជធានីភ្នំពេញ គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី ។

សាលារាជធានីភ្នំពេញ ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ ។

ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ :

- ធ្វើទំនាក់ទំនងនិងធ្វើការងារជាមួយក្រុមប្រឹក្សារាជធានី និងគណៈអភិបាលរាជធានី
- ទទួលព័ត៌មានអំពីសំណើនិងការងារនានាពីរដ្ឋបាលរាជធានីភ្នំពេញ
- ចូលរួមយោបល់ឬសំណូមពរលើបញ្ហាណាមួយ ។

រវាងសង្កាត់នានាក្នុងខណ្ឌ

- ការងារហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខណ្ឌ
- ការងារដីធ្លីនិងសំណង់
- ការងារសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ សិទ្ធិមនុស្ស និងយេនឌ័រ
- ការអនុវត្តមុខងារ ភារកិច្ចនានាដែលបានធ្វើប្រតិភូកម្ម
- កិច្ចការដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

ផ្អែកលើតួនាទីខាងលើនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមការសម្រេចរបស់ គ.ជ.អ.ប.ត្រូវចេញប្រកាសស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យនានាចំណុះសាលាខណ្ឌ រួមទាំងល័ក្ខខ័ណ្ឌនៃការរៀបចំមន្ត្រី បុគ្គលិកនៃការិយាល័យទាំងនោះ។

ជំពូកទី៤

ការគាំទ្រនិងទំនាក់ទំនងរវាងរដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ និងទំនាក់ទំនងរវាងរដ្ឋបាលទាំងនេះជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល

ផ្នែកទី១

ទំនាក់ទំនងរវាងរដ្ឋបាលរាជធានី ខណ្ឌ សង្កាត់

មាត្រា ១១៥.-

ក្រុមប្រឹក្សាសង្កាត់និងក្រុមប្រឹក្សាខណ្ឌត្រូវស្ថិតក្រោមការត្រួតពិនិត្យនិងការគ្រប់គ្រងរបស់ក្រុមប្រឹក្សារាជធានី។

មាត្រា ១១៦.-

ដើម្បីធានាឱ្យក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌលើកកម្ពស់ក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាសង្កាត់ត្រូវទទួលខុសត្រូវ :

- ក្នុងការផ្តល់យោបល់និងការពិគ្រោះយោបល់ ជាមួយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌ ដើម្បីធានាថាក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាខណ្ឌ នៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សារាជធានីនិងក្រុមប្រឹក្សាខណ្ឌ អំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាពនិងធនធានដែលខ្លួនមាន
- អនុវត្តមុខងារ ភារកិច្ចទាំងឡាយដែលបានធ្វើប្រតិភូកម្មដោយក្រុមប្រឹក្សារាជធានី
- ធ្វើសហប្រតិបត្តិការឱ្យបានពេញលេញជាមួយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌ ក្នុងការលើកកម្ពស់ការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន។

មាត្រា ១១៧.-

ក្រុមប្រឹក្សាខណ្ឌត្រូវរៀបចំឱ្យមានការពិគ្រោះយោបល់សមស្របជាមួយក្រុមប្រឹក្សាសង្កាត់ ដើម្បី :

- ធ្វើការសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមសង្កាត់នានាក្នុងខណ្ឌ ដើម្បីលើកកម្ពស់ការឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ
- ប្រមូលផ្តុំសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋដែលលើកឡើងដោយក្រុមប្រឹក្សាសង្កាត់ ហើយដែលក្រុមប្រឹក្សាសង្កាត់មិនអាចឆ្លើយតបបាន ដើម្បីពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ខិតខំឆ្លើយតបតម្រូវការទាំងនោះ
- គាំទ្រសមត្ថភាពចាំបាច់ដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីឱ្យក្រុមប្រឹក្សាសង្កាត់ក្នុងខណ្ឌមានសមត្ថភាពទទួលបាននូវមុខងារ ភារកិច្ចដែលត្រូវធ្វើប្រតិភូកម្មកាន់តែច្រើនថែមទៀតពីក្រុមប្រឹក្សារាជធានី សំដៅឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។

មាត្រា ១១៨.-

ក្រុមប្រឹក្សាខណ្ឌត្រូវអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មឱ្យដោយក្រុមប្រឹក្សារាជធានី។ ក្រុមប្រឹក្សារាជធានីត្រូវធានាធ្វើប្រតិភូកម្មនូវមុខងារ ភារកិច្ចសមស្របដល់ក្រុមប្រឹក្សាខណ្ឌនានា។

ដើម្បីធ្វើប្រតិភូកម្មមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សារាជធានីត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខណ្ឌនិងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ដើម្បីរួមគ្នាពិចារណាអំពីភាពសមហេតុផល ក្នុងការធ្វើប្រតិភូកម្មមុខងារ ភារកិច្ចសមស្របទៅឱ្យក្រុមប្រឹក្សាខណ្ឌ ឬទៅឱ្យក្រុមប្រឹក្សាសង្កាត់ និងល័ក្ខខ័ណ្ឌចាំបាច់នានាក្នុងការធ្វើសហប្រតិបត្តិការរវាងក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ក្នុងការអនុវត្តមុខងារ ភារកិច្ចទាំងនោះ។

មាត្រា ១១៩.-

ដើម្បីលើកកម្ពស់ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់រាជធានី ខណ្ឌ និងសង្កាត់ ក្រុមប្រឹក្សានីមួយៗត្រូវសម្របសម្រួលនិងបង្កលក្ខណៈឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធនានា។

មាត្រា ១២០.-

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធានាធ្វើប្រតិភូកម្មឱ្យបានសមស្របនូវមុខងារ ភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ក្នុងរាជធានីរបស់ខ្លួន ដើម្បីធានាឱ្យក្រុមប្រឹក្សាសង្កាត់មានលទ្ធភាពកាន់តែច្រើនថែមទៀតក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយផ្ទាល់ដល់ប្រជាពលរដ្ឋនៅតាមសង្កាត់នីមួយៗ។

មុខងារ ភារកិច្ចដែលត្រូវធ្វើប្រតិភូកម្មដល់ក្រុមប្រឹក្សាសង្កាត់ គឺជាមុខងារ ភារកិច្ចដែលមានការពាក់ព័ន្ធដោយផ្ទាល់ដល់ការផ្តល់សេវាកម្ម ការអភិវឌ្ឍ និងសេចក្តីត្រូវការនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតាមសង្កាត់នីមួយៗ។

ដើម្បីធានាការធ្វើប្រតិភូកម្មតាមគោលការណ៍ខាងលើនេះ ក្រុមប្រឹក្សារាជធានីត្រូវធ្វើការពិគ្រោះយោបល់ ដូចបានចែងក្នុងវាក្យខណ្ឌទី២ មាត្រា១១៨នៃអនុក្រឹត្យនេះ។

មាត្រា ១២១.-

ក្នុងមុខងារជាតំណាងរាជរដ្ឋាភិបាល គណៈអភិបាលរាជធានីភ្នំពេញត្រូវធ្វើការដឹកនាំ ណែនាំ សម្របសម្រួលដល់គណៈអភិបាលខណ្ឌ ដើម្បីធានារក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ ការគោរពសិទ្ធិមនុស្ស ការគោរពច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខណ្ឌនីមួយៗ។

គណៈអភិបាលរាជធានីត្រូវធានាឱ្យគណៈអភិបាលខណ្ឌនីមួយៗនៃរាជធានី ធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា ដើម្បីរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ ការគោរពសិទ្ធិមនុស្ស និងការគោរពច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់រាជធានី។

អភិបាលខណ្ឌត្រូវទំនាក់ទំនងជាមួយគណៈអភិបាលរាជធានី ដើម្បីស្នើសុំការដឹកនាំ ណែនាំ និងសម្របសម្រួលពាក់ព័ន្ធនឹងកិច្ចការខាងលើនេះ។

មាត្រា ១២២.

ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវធានាផ្តល់មធ្យោបាយ សម្ភារៈ ធនធាននានា រួមទាំងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងការបណ្តុះបណ្តាល ការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាទាំងនេះ ដើម្បីអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មពីក្រុមប្រឹក្សារាជធានីទៅក្រុមប្រឹក្សាខណ្ឌ និងសង្កាត់ក្នុងរាជធានី។

ក្រុមប្រឹក្សារាជធានីត្រូវធ្វើការត្រួតពិនិត្យនីត្យានុកូលភាពនៃការអនុវត្តមុខងារ ភារកិច្ចដែលបានធ្វើប្រតិភូកម្មឱ្យខណ្ឌ និងសង្កាត់ ដើម្បីធានាថាខណ្ឌ និងសង្កាត់អនុវត្តមុខងារ ភារកិច្ចទាំងនោះ ក្នុងក្របខ័ណ្ឌនៃការងារដែលបានធ្វើប្រតិភូកម្មឱ្យ លើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងធានាថាខណ្ឌ និងសង្កាត់ឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញគោលការណ៍ណែនាំស្តីពីការត្រួតពិនិត្យនីត្យានុកូលភាពខាងលើនេះ។

មាត្រា ១២៣.

ក្រុមប្រឹក្សាខណ្ឌ ត្រូវធ្វើការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ ដើម្បីធានាថាក្រុមប្រឹក្សាសង្កាត់អនុវត្តមុខងារ ភារកិច្ច ក្នុងក្របខ័ណ្ឌនៃអំណាចដែលបានធ្វើប្រតិភូកម្មឱ្យ លើមូលដ្ឋាននៃការគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ហើយត្រូវធានាថាក្រុមប្រឹក្សាសង្កាត់បានអនុវត្តមុខងារ ភារកិច្ចនេះ ក្នុងការឆ្លើយតបបានយ៉ាងប្រសើរបំផុតនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

មាត្រា ១២៤.

ដើម្បីធានាដល់ការអភិវឌ្ឍរាជធានីប្រកបដោយចីរភាព ក្រុមប្រឹក្សារាជធានីត្រូវសហការសិក្សារៀបចំប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីក្នុងរាជធានី លើមូលដ្ឋាននៃការពិគ្រោះយោបល់ ការសម្របសម្រួល ការចូលរួមពីក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាសង្កាត់ទាំងអស់ក្នុងរាជធានី ព្រមទាំងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។

ប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីនេះ ត្រូវរៀបចំតាមគោលការណ៍និងនីតិវិធីដែលកំណត់។

ក្រុមប្រឹក្សារាជធានីត្រូវធានាថាប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដី ដែលបានសម្រេចជាផ្លូវការត្រូវគោរពនិងអនុវត្តយ៉ាងត្រឹមត្រូវ។

ក្រុមប្រឹក្សារាជធានីត្រូវរៀបចំផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងត្រូវខិតខំសម្របសម្រួល តម្រង់ទិសសកម្មភាពនានាក្នុងការអភិវឌ្ឍរាជធានី ដោយផ្អែកលើមូលដ្ឋាននៃប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីនេះ។

មាត្រា ១៣១.-

ក្រសួង ស្ថាប័ននានាត្រូវសហការសម្របសម្រួលជាមួយ គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ ដើម្បីអនុវត្តបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១២៦ មាត្រា១២៧ មាត្រា១២៨ មាត្រា១២៩ និងមាត្រា១៣០នៃអនុក្រឹត្យនេះ និងការងារដទៃៗទៀតដែលពាក់ព័ន្ធដល់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់។

មាត្រា ១៣២.-

ក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ។

ក្នុងក្របខ័ណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ រាជរដ្ឋាភិបាលមានសិទ្ធិណែនាំនិងត្រួតពិនិត្យនីត្យានុកូលភាពនៃការសម្រេចនិងការធ្វើសកម្មភាពរបស់ក្រុមប្រឹក្សា ដើម្បីធានាឱ្យបានថាក្រុមប្រឹក្សាគោរពយ៉ាងត្រឹមត្រូវនូវរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងគោលនយោបាយរបស់ជាតិ។

មាត្រា ១៣៣.-

ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សារាជធានីភ្នំពេញត្រូវបានទទួលប្រតិភូកម្មដោយអនុក្រឹត្យនេះពីរាជរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ ដើម្បីរួមគ្នាសម្រេចឱ្យបាននូវគោលនយោបាយរបស់ជាតិ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប.ត្រូវចេញប្រកាសដើម្បីកំណត់អំពីគោលការណ៍ និងនីតិវិធីនានាពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មខាងលើនេះ។

មាត្រា ១៣៤.-

ក្រសួង ស្ថាប័ននានា អាចធ្វើទំនាក់ទំនងនិងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលខណ្ឌឬរដ្ឋបាលសង្កាត់តាមការចាំបាច់ ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលរាជធានីភ្នំពេញ។

មាត្រា ១៣៥.-

ក្នុងករណីមានភាពមិនចុះសម្រុងគ្នារវាងរដ្ឋបាលរាជធានីជាមួយរដ្ឋបាលខណ្ឌឬរដ្ឋបាលសង្កាត់ ឬរវាងរដ្ឋបាលណាមួយក្នុងចំណោមរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់ ក្រសួងមហាផ្ទៃត្រូវធ្វើការសម្របសម្រួល ដោះស្រាយតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

មាត្រា ១៣៦.-

ក្នុងការអនុវត្តការងាររបស់ខ្លួន ក្រុមប្រឹក្សារាជធានីត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយក្រសួង ស្ថាប័ននានា ដើម្បីពិគ្រោះយោបល់អំពីការគាំទ្រនិងការចូលរួមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយអំពីសេចក្តីត្រូវការទាំងឡាយរបស់ប្រជាពលរដ្ឋ ហើយដែលក្រុមប្រឹក្សាមិនអាចដោះស្រាយបានដោយផ្អែកលើសមត្ថភាពនិងធនធានដែលក្រុមប្រឹក្សាមាន។

ខណ្ឌ បុគ្គលិករបស់ក្រុមប្រឹក្សារាជធានីនិងបុគ្គលិករបស់ក្រុមប្រឹក្សាខណ្ឌ បែបបទនិងនីតិវិធីនៃការសុំច្បាប់ឈប់សម្រាកត្រូវអនុវត្តតាមសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

មាត្រា ១៤៧.-

គ.ជ.អ.ប. ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីធ្វើសមាហរណកម្មរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍រាជធានី មកក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលរាជធានី ស្របតាមស្មារតីនៃអនុក្រឹត្យនេះ។

ក្នុងការសិក្សាខាងលើនេះ គ.ជ.អ.ប. ត្រូវធ្វើការពិគ្រោះយោបល់និងធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំយុទ្ធសាស្ត្រ និងដំណាក់កាលសមស្របក្នុងដំណើរការធ្វើសមាហរណកម្មនេះ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា ១៤៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ១៤៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ក្ត ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១៤៩*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ឧបសម្ព័ន្ធទី៥

``

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.២៤២.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុងកោះរ៉ុង នៃខេត្តព្រះសីហនុ

- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌចឹងកេងកង នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកតាំងគោក នៃខេត្តកំពង់ធំ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកបុរីអូរស្វាយសែនជ័យ នៃខេត្តស្ទឹងត្រែង
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកតាលោសែនជ័យ នៃខេត្តពោធិ៍សាត់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី និងសមាជិកក្រុមប្រឹក្សាខេត្តនីមួយៗសម្រាប់អាណត្តិទី៣ ដោយអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម៖

១- រាជធានីភ្នំពេញ	មានចំនួនសមាជិកក្រុមប្រឹក្សា	២៧ នាក់
២- ខេត្ត កណ្តាល	មានចំនួនសមាជិកក្រុមប្រឹក្សា	២៧ នាក់
៣- ខេត្ត កំពង់ចាម	មានចំនួនសមាជិកក្រុមប្រឹក្សា	២៧ នាក់
៤- ខេត្ត បាត់ដំបង	មានចំនួនសមាជិកក្រុមប្រឹក្សា	២៧ នាក់
៥- ខេត្ត ព្រៃវែង	មានចំនួនសមាជិកក្រុមប្រឹក្សា	២៧ នាក់
៦- ខេត្ត សៀមរាប	មានចំនួនសមាជិកក្រុមប្រឹក្សា	២៧ នាក់
៧- ខេត្ត តាកែវ	មានចំនួនសមាជិកក្រុមប្រឹក្សា	២៧ នាក់
៨- ខេត្ត ត្បូងឃ្មុំ	មានចំនួនសមាជិកក្រុមប្រឹក្សា	២៥ នាក់
៩- ខេត្ត បន្ទាយមានជ័យ	មានចំនួនសមាជិកក្រុមប្រឹក្សា	២៥ នាក់
១០-ខេត្ត កំពង់ស្ពឺ	មានចំនួនសមាជិកក្រុមប្រឹក្សា	២៥ នាក់
១១-ខេត្ត កំពង់ធំ	មានចំនួនសមាជិកក្រុមប្រឹក្សា	២៥ នាក់
១២-ខេត្ត កំពត	មានចំនួនសមាជិកក្រុមប្រឹក្សា	២៥ នាក់
១៣-ខេត្ត កំពង់ឆ្នាំង	មានចំនួនសមាជិកក្រុមប្រឹក្សា	២៣ នាក់
១៤-ខេត្ត ស្វាយរៀង	មានចំនួនសមាជិកក្រុមប្រឹក្សា	២៣ នាក់
១៥-ខេត្ត ពោធិ៍សាត់	មានចំនួនសមាជិកក្រុមប្រឹក្សា	២១ នាក់
១៦-ខេត្ត ក្រចេះ	មានចំនួនសមាជិកក្រុមប្រឹក្សា	២១ នាក់

១៧-ខេត្ត ព្រះសីហនុ	មានចំនួនសមាជិកក្រុមប្រឹក្សា	១៩ នាក់
១៨-ខេត្ត កោះកុង	មានចំនួនសមាជិកក្រុមប្រឹក្សា	១៩ នាក់
១៩-ខេត្ត ព្រះវិហារ	មានចំនួនសមាជិកក្រុមប្រឹក្សា	១៩ នាក់
២០-ខេត្ត រតនគិរី	មានចំនួនសមាជិកក្រុមប្រឹក្សា	១៩ នាក់
២១-ខេត្ត ឧត្តរមានជ័យ	មានចំនួនសមាជិកក្រុមប្រឹក្សា	១៩ នាក់
២២-ខេត្ត ស្ទឹងត្រែង	មានចំនួនសមាជិកក្រុមប្រឹក្សា	១៧ នាក់
២៣-ខេត្ត មណ្ឌលគិរី	មានចំនួនសមាជិកក្រុមប្រឹក្សា	១៥ នាក់
២៤-ខេត្ត ប៉ៃលិន	មានចំនួនសមាជិកក្រុមប្រឹក្សា	១៥ នាក់
២៥-ខេត្ត កែប	មានចំនួនសមាជិកក្រុមប្រឹក្សា	១៥ នាក់។

មាត្រា ២.-

ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នីមួយៗសម្រាប់អាណត្តិទី៣ ដោយអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម៖

១.រាជធានីភ្នំពេញ

១- ខណ្ឌ មានជ័យ	មានចំនួនសមាជិកក្រុមប្រឹក្សា	២១ នាក់
២- ខណ្ឌ ច្បារអំពៅ	-ដ-	២១ នាក់
៣- ខណ្ឌ ទួលគោក	-ដ-	២១ នាក់
៤- ខណ្ឌ ឫស្សីកែវ	-ដ-	២១ នាក់
៥- ខណ្ឌ សែនសុខ	-ដ-	២១ នាក់
៦- ខណ្ឌ ពោធិ៍សែនជ័យ	-ដ-	២១ នាក់
៧- ខណ្ឌ ចំការមន	-ដ-	១៩ នាក់
៨- ខណ្ឌ ដង្កោ	-ដ-	១៩ នាក់
៩- ខណ្ឌ ដូនពេញ	-ដ-	១៩ នាក់
១០-ខណ្ឌ ៧មករា	-ដ-	១៩ នាក់
១១-ខណ្ឌ បឹងកេងកង	-ដ-	១៧ នាក់
១២-ខណ្ឌ កំបូល	-ដ-	១៧ នាក់
១៣-ខណ្ឌ ជ្រោយចង្វារ	-ដ-	១៧ នាក់
១៤-ខណ្ឌ ព្រែកព្នៅ	-ដ-	១៧ នាក់

២.ខេត្ត កណ្តាល

១៥-ក្រុង តាខ្មៅ	មានចំនួនសមាជិកក្រុមប្រឹក្សា	២១ នាក់
១៦-ស្រុក កៀនស្វាយ	-ដ-	២១ នាក់
១៧-ស្រុក ស្អាង	-ដ-	២១ នាក់

២២.ខេត្ត ឧត្តរមានជ័យ

១៩០-ក្រុង សំរោង	មានចំនួនសមាជិកក្រុមប្រឹក្សា	១៧ នាក់
១៩១-ស្រុក ត្រពាំងប្រាសាទ	-ដ-	១៧ នាក់
១៩២-ស្រុក បន្ទាយអំពិល	-ដ-	១៥ នាក់
១៩៣-ស្រុក អន្លង់វែង	-ដ-	១៥ នាក់
១៩៤-ស្រុក ចុងកាល់	-ដ-	១៣ នាក់

២៣.ខេត្ត មណ្ឌលគិរី

១៩៥-ស្រុក កែវសីមា	មានចំនួនសមាជិកក្រុមប្រឹក្សា	១៣ នាក់
១៩៦-ស្រុក កោះញែក	-ដ-	១៣ នាក់
១៩៧-ស្រុក អូរាំង	-ដ-	១១ នាក់
១៩៨-ស្រុក ពេជ្រាដា	-ដ-	១១ នាក់
១៩៩-ក្រុង សែនមនោរម្យ	-ដ-	១១ នាក់

២៤.ខេត្ត ប៉ៃលិន

២០០-ក្រុង ប៉ៃលិន	មានចំនួនសមាជិកក្រុមប្រឹក្សា	១៥ នាក់
២០១-ស្រុក សាលាក្រៅ	-ដ-	១៥ នាក់

២៥.ខេត្ត កែប

២០២-ក្រុង កែប	មានចំនួនសមាជិកក្រុមប្រឹក្សា	១៣ នាក់
២០៣-ស្រុក ដំណាក់ចង្អើរ	-ដ-	១៣ នាក់។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៥ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ៤៤២៧ ប្រ

ប្រកាស

ស្តីពី

ការបង្កើតការិយាល័យចំណុះនីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងតាមការសម្រេចនៃអង្គប្រជុំ គ.ជ.អ.ប លើកទី៣ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

សម្រួច

ជំពូកទី១

អំពីទីចាត់ការ និងការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ

ផ្នែកទី១

អំពីការបង្កើតការិយាល័យ និងតួនាទី ភារកិច្ច

របស់ការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ

ប្រការ ១.-

សាលារាជធានីភ្នំពេញ គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីភ្នំពេញ។

សាលារាជធានីភ្នំពេញ ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ។

ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ :

- ធ្វើចំនាក់ចំនង និងធ្វើការងារជាមួយក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីភ្នំពេញ
- ទទួលព័ត៌មានអំពីសំណើ និងការងារនានាពីរដ្ឋបាលរាជធានីភ្នំពេញ
- ចូលរួមយោបល់ ឬសំណូមពរលើបញ្ហាណាមួយ។

នៅចន្លោះម៉ោងធ្វើការ ឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីភ្នំពេញត្រូវធានាឱ្យមានមន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួន ក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួល ឬដោះស្រាយសំណូមពរបន្ទាន់ ពិសេសនានា។

ប្រការ ២.-

ផ្អែកតាមមាត្រា៥៥ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ សាលារាជធានីភ្នំពេញត្រូវមានទីចាត់ការចំណុះចាំបាច់ ដូចខាងក្រោម :

- ទីចាត់ការរដ្ឋបាល
- ទីចាត់ការផែនការ និងវិនិយោគ
- ទីចាត់ការហិរញ្ញវត្ថុ
- ទីចាត់ការរៀបចំក្រុង
- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
- ទីចាត់ការអន្តរវិស័យ
- ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់។

ទីចាត់ការនីមួយៗត្រូវបំពេញតួនាទី ភារកិច្ច ដូចមានចែងក្នុងមាត្រា៥៨ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី

នាយករដ្ឋបាលត្រូវអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ និងទី២ នៃប្រការនេះ។

ក្នុងការចាត់ចែងតួនាទី ភារកិច្ចរបស់ខ្លួន ការិយាល័យនីមួយៗត្រូវផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត បែបបទ នីតិវិធី និងលក្ខខ័ណ្ឌការងារដែលបានកំណត់។

ប្រការ ១២.-

ក្រៅពីទីចាត់ការ និងការិយាល័យខាងលើ គណៈអភិបាលរាជធានីអាចស្នើទៅក្រុមប្រឹក្សារាជធានី ដើម្បីបង្កើត ឬកែសម្រួល ឬរំសាយទីចាត់ការ ឬការិយាល័យណាមួយ ឬមួយចំនួន តាមការចាំបាច់។

ក្នុងករណីមានតម្រូវការបង្កើតទីចាត់ការ ឬការិយាល័យបន្ថែម ទីចាត់ការ ឬការិយាល័យនោះមិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយទីចាត់ការដែលតម្រូវឱ្យបង្កើតដោយអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ និងការិយាល័យដែលតម្រូវឱ្យបង្កើតដោយប្រកាសនេះឡើយ។

ផ្អែកតាមការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានីភ្នំពេញត្រូវលើកសំណើមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច និង/ឬរៀបចំបែបបទក្នុងការបង្កើត ឬរំសាយ ឬកែសម្រួលទីចាត់ការ ឬការិយាល័យខាងលើនេះ។

ផ្នែកទី២
របៀបរបបធ្វើការងាររបស់ទីចាត់ការ និងការិយាល័យចំណុះ

ប្រការ ១៣.-

ទីចាត់ការនីមួយៗ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់នាយកទីចាត់ការ។

នាយកទីចាត់ការនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលារាជធានី។

នាយករដ្ឋបាលសាលារាជធានី ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះគណៈអភិបាល អភិបាលនិងក្រុមប្រឹក្សារបស់ខ្លួន។

ប្រការ ១៤.-

ការិយាល័យនីមួយៗ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានការិយាល័យ។

ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយកទីចាត់ការរបស់ខ្លួន និងនាយករដ្ឋបាលសាលារាជធានី។

ប្រការ ១៥.-

ផ្អែកតាមគោលការណ៍ដូចមានចែងក្នុងអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពី

តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ និងគោលការណ៍នានាដូចមានចែងក្នុងប្រកាសនេះ នាយករដ្ឋបាលសាលារាជធានី ដោយមានទីចាត់ការគ្រប់គ្រងធនធានមនុស្សជាសេនាធិការ ត្រូវដឹកនាំ សម្របសម្រួលទីចាត់ការនានានៃសាលារាជធានី ក្នុងការរៀបចំកំណត់អំពីនីតិវិធីរដ្ឋបាលសម្រាប់ទីចាត់ការ និងការិយាល័យចំណុះទីចាត់ការនីមួយៗ ព្រមទាំងការរៀបចំកំណត់អំពីលក្ខខ័ណ្ឌការងាររបស់នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិកទាំងអស់នៅតាមការិយាល័យចំណុះទីចាត់ការនានានៃសាលារាជធានី ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សារាជធានីពិនិត្យសម្រេច។

នាយករដ្ឋបាលសាលារាជធានី ដោយមានទីចាត់ការហិរញ្ញវត្ថុជាសេនាធិការ ត្រូវរៀបចំកំណត់អំពីនីតិវិធីហិរញ្ញវត្ថុ ការប្រើប្រាស់សំភារៈ ថវិកាសម្រាប់ទីចាត់ការ និងការិយាល័យនានានៃសាលារាជធានី ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សារាជធានីពិនិត្យ សម្រេច។

នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិក ត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី។

គណៈអភិបាលរាជធានីត្រូវដឹកនាំនាយករដ្ឋបាល ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំអំពីការអនុវត្តនូវនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខ័ណ្ឌការងារដែលបានកំណត់ខាងលើនេះ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ប្រការ ១៦.-

គ្រប់កិច្ចការនានាដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន គណៈអភិបាលរាជធានីត្រូវដឹកនាំ ណែនាំដល់នាយករដ្ឋបាលក្នុងការប្រគល់កិច្ចការដល់ទីចាត់ការ និងការិយាល័យដែលទទួលខុសត្រូវការងារនីមួយៗ ដើម្បីសិក្សា ស្រាវជ្រាវ លើកយោបល់ ដោយផ្អែកតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ រួចបញ្ជូនមកនាយករដ្ឋបាល ដើម្បីបញ្ជូនទៅអភិបាលរងទទួលបន្ទុកលើការងារ ឬវិស័យនីមួយៗពិនិត្យ និងផ្តល់យោបល់ មុនដាក់ជូនអភិបាលរាជធានីពិនិត្យ សម្រេច ស្របតាមបែបបទ នីតិវិធី និងសមត្ថកិច្ចរបស់ខ្លួន។

នាយកទីចាត់ការ និងប្រធានការិយាល័យនានាត្រូវធានាចាត់ចែងមន្ត្រី បុគ្គលិកក្នុងការិយាល័យនីមួយៗ ដើម្បីអនុវត្តការងារ ដោយផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងផ្អែកតាមនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលក្ខខ័ណ្ឌការងារដែលបានកំណត់។

ប្រការ ១៧.-

នាយករដ្ឋបាលត្រូវកំណត់ឱ្យមានរបបប្រជុំជាមួយនាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ និងប្រធានអនុប្រធានការិយាល័យចំណុះសាលារាជធានី។

នាយកទីចាត់ការនីមួយៗ ត្រូវកំណត់ឱ្យមានរបបប្រជុំជាមួយប្រធាន អនុប្រធានការិយាល័យចំណុះ។

កិច្ចប្រជុំខាងលើនេះ គឺជាការរួមគ្នា ដើម្បីពិនិត្យអំពីលទ្ធផលការងារ ភាពរីកចម្រើន ឬបញ្ហាប្រឈមនានា ដើម្បី

លើកទិសដៅ វិធានការ ឬស្នើសុំយោបល់ផ្តាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និងដោះស្រាយ ។

រាល់ការប្រជុំនីមួយៗ ត្រូវមានកំណត់ហេតុប្រជុំ ។

ប្រការ ១៨.-

គណៈអភិបាលរាជធានីត្រូវដឹកនាំ ណែនាំដល់នាយករដ្ឋបាលក្នុងការរៀបចំផែនការ កម្មវិធីបណ្តុះបណ្តាល កសាង សមត្ថភាពដល់នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិកទាំងអស់នៃសាលារាជធានី អំពីជំនាញវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ ព្រមទាំងតួនាទី ភារកិច្ច នីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងលំហូរខ្ពស់ការងារ របស់មន្ត្រី បុគ្គលិក សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលារាជធានី ។

ជំពូកទី២
អំពីការិយាល័យចំណុះសាលាខណ្ឌនៃរាជធានីភ្នំពេញ
ផ្នែកទី១
អំពីការបង្កើតការិយាល័យ និងតួនាទី ភារកិច្ច
របស់ការិយាល័យចំណុះសាលាខណ្ឌនៃរាជធានីភ្នំពេញ

ប្រការ ១៩.-

សាលាខណ្ឌ គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ ។

សាលាខណ្ឌ ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ ។

ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ :

- ធ្វើទំនាក់ទំនង និងធ្វើការងារជាមួយក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ
- ទទួលព័ត៌មានអំពីសំណើ និងការងារនានាពីរដ្ឋបាលខណ្ឌ
- ចូលរួមយោបល់ ឬសំណូមពរលើបញ្ហាណាមួយ ។

នៅចន្លោះម៉ោងធ្វើការ ឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវចាត់ឱ្យមានមន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួន ក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួល ឬដោះស្រាយសំណូមពរបន្ទាន់ ពិសេសនានា ។

ប្រការ ២០.-

ផ្អែកតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១១៤ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ សាលាខណ្ឌនីមួយៗត្រូវមានការិយាល័យចាំបាច់ ដូចខាងក្រោម :

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងអភិវឌ្ឍ
- ការិយាល័យអន្តរវិស័យ ។

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានមួយ(០១)រូប និងមានអនុប្រធានមួយ(០១)រូបជាជំនួយការ ។

យោបល់ មុនដាក់ជូនអភិបាលខណ្ឌពិនិត្យ សម្រេច ស្របតាមបែបបទ នីតិវិធី និងសមត្ថកិច្ចរបស់ខ្លួន។

ប្រធានការិយាល័យនានាត្រូវចានាចាត់ចែងមន្ត្រី បុគ្គលិកក្នុងការិយាល័យនីមួយៗ ដើម្បីអនុវត្តការងារផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងផ្អែកតាមនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ និងល័ក្ខខ័ណ្ឌការងារដែលបានកំណត់។

ប្រការ ២៦.-

នាយករដ្ឋបាលសាលាខណ្ឌត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់ជាមួយនាយករងរដ្ឋបាលសាលាខណ្ឌ ប្រធានអនុប្រធានការិយាល័យនានានៃសាលាខណ្ឌ ដើម្បីពិនិត្យអំពីលទ្ធផលការងារ ភាពរីកចម្រើន ឬបញ្ហាប្រឈមនានា ដើម្បីលើកទិសដៅ វិធានការ ឬស្នើសុំយោបល់ថ្នាក់ដឹកនាំតាមឋានានុក្រម ពិនិត្យ និងដោះស្រាយ។

រាល់ការប្រជុំនីមួយៗ ត្រូវមានកំណត់ហេតុប្រជុំ និងត្រូវធ្វើសេចក្តីរាយការណ៍អំពីការប្រជុំនេះជូនក្រុមប្រឹក្សា និងគណៈអភិបាលខណ្ឌ។

ជំពូកទី៣
អន្តរប្បញ្ញត្តិ

ប្រការ ២៧.-

ប្រាក់បំណាច់មុខងារនាយកទីចាត់ការ នាយករងទីចាត់ការ ប្រធាន និងអនុប្រធានការិយាល័យនៃសាលារាជធានី ប្រធាន និងអនុប្រធានការិយាល័យនៃសាលាខណ្ឌ ត្រូវអនុវត្តតាមមាត្រា១៤៥ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ។

ប្រការ ២៨.-

នៅពេលមិនទាន់មានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ យោងតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី អភិបាលរាជធានីត្រូវលើកសំណើតែងតាំងមន្ត្រីក្នុងមុខតំណែងជានាយកទីចាត់ការ នាយករងទីចាត់ការ ប្រធានការិយាល័យ អនុប្រធានការិយាល័យនៃសាលារាជធានី ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យ សម្រេច តាមគោលការណ៍ និងនីតិវិធីកំណត់។ ចំពោះសំណើសុំតែងតាំងប្រធាន និងអនុប្រធានការិយាល័យនៃសាលាខណ្ឌនីមួយៗនៃរាជធានី អភិបាលរាជធានីភ្នំពេញដោយយោងតាមសំណើរបស់អភិបាលខណ្ឌដែលមានការឯកភាពពីក្រុមប្រឹក្សាខណ្ឌ ត្រូវលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ សម្រេច តាមគោលការណ៍ និងនីតិវិធីកំណត់។

ឋានន្តរសក្តិរបស់មន្ត្រីរាជការ ដែលមានឧបនិស្ស័យសម្រាប់តែងតាំងមុខតំណែងខាងលើនេះ ត្រូវកំណត់ដូចខាងក្រោម :

- នាយកទីចាត់ការ មានឋានន្តរសក្តិចាប់ពីនាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- នាយករងទីចាត់ការ មានឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- ប្រធានការិយាល័យនៃសាលារាជធានី មានឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ

- អនុប្រធានការិយាល័យនៃសាលារាជធានី មានឋានន្តរសក្តិចាប់ពីក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- ប្រធានការិយាល័យនៃសាលាខណ្ឌ មានឋានន្តរសក្តិចាប់ពីក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- អនុប្រធានការិយាល័យនៃសាលាខណ្ឌ មានឋានន្តរសក្តិចាប់ពីនាយលេខាធិការរដ្ឋបាល នៃក្របខ័ណ្ឌមន្ត្រីលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ។

ប្រការ ២៩.-

ក្នុងការធ្វើសមាហរណកម្មមន្ត្រី បុគ្គលិកនៃសាលារាជធានី សាលាខណ្ឌបច្ចុប្បន្ន ទៅក្នុងរចនាសម្ព័ន្ធថ្មីនៃប្រកាសនេះ ក្រុមប្រឹក្សា គណៈអភិបាលរាជធានី និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ ត្រូវអនុវត្តតាមមាត្រា១៤៤ នៃអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ។

ជំពូកទី៤
អវសានប្បញ្ញត្តិ

ប្រការ ៣០.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៣១.-

ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ និងអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១

ផែនទីរាជធានីភ្នំពេញ និងរដ្ឋបាលសាលារាជធានីភ្នំពេញ

``

ផែនទីរាជធានីភ្នំពេញ



កំណត់សំគាល់

- ផ្លូវសំខាន់ៗ
- ៧មករា
- ទួលគោក
- ចំការមន
- ឫស្សីកែវ
- ដូនពេញ
- ពោធិ៍សែនជ័យ
- កំបូល
- សែនសុខ
- ព្រែកព្នៅ
- ប្អូស្សីកែវ
- ច្បារអំពៅ
- ជ្រោយចង្វារ
- ដង្កោ
- មានជ័យ

ជំរឿនក្នុងឆ្នាំ ២០១៥

ផ្ទៃដីសរុប	= ៦៥២.៤៦គ.ម^{២}
ប្រជាជន	= ២.១២៥.៣៧១នាក់
ចំនួនស្រីសរុប	= ១.០៤០.១៧៩នាក់
ចំនួនគ្រួសារ	= ៣៩៥.២៣០
ដង់ស៊ីតេ	= ៣.១៩៦ នាក់ ក.ម^{២}
ខណ្ឌ	= ១៤
សង្កាត់	=១០៥
ភូមិ	= ៩៥៣

ប្លង់អគារក្នុងរដ្ឋបាលរាជធានីភ្នំពេញ



កំណត់សំគាល់

-អគារ គណៈអភិបាល (អគារ ក)

- បន្ទប់ប្រជុំ លេខ១ អគារ ក
- បន្ទប់បដិសណ្ឋារកិច្ច ជាន់ទី១ អគារ ក
- បន្ទប់បដិសណ្ឋារកិច្ច ជាន់ទី២ អគារ ក

-អគារ ក្រុមប្រឹក្សារាជធានីភ្នំពេញ (អគារ ខ)

- បន្ទប់ប្រជុំ ការិយាល័យរដ្ឋបាលចាស់ អគារ ខ
- បន្ទប់ប្រជុំតូច ជាន់ទី២ អគារ ខ
- សាលប្រជុំ ជាន់ទី២ អគារ ខ

-អគារ ឯីចាត់ការរដ្ឋបាលរាជធានីភ្នំពេញ (អគារ គ)

- សាលប្រជុំ ជាន់ទី១ អគារ គ
- បន្ទប់បដិសណ្ឋារកិច្ច ជាន់ទី១០ អគារ គ
- សាលសន្និសីទ ជាន់ទី១១ អគារ គ

-អគារ ឯីស្នាក់ការសន្តិសុខ (អគារ ឃ)

- បន្ទប់ស្នាក់សម្រាប់សន្តិសុខ និងអ្នកយាម

``


ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ២០៣៥
Land Use Master Plan of Phnom Penh City 2035
TOUL KORK
AEROPORT
CHAMCHAO
TA KMAU
N
W
E
S
France
គំណត់សំគាល់

``

រដ្ឋបាលសាលារាជធានីភ្នំពេញ

រដ្ឋបាលសាលារាជធានីភ្នំពេញ

``

ឧបសម្ព័ន្ធទី២

រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលសាលារាជធានីភ្នំពេញ

ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣
២០១៩ - ២០២៤

ឯកឧត្តម ប៉ា សុជាតិវង្ស
ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ

ឯកឧត្តម ជួប ខុន
(សមាជិកក្រុមប្រឹក្សា)

លោកជំទាវ អ៊ុំ ក្រសាល
(សមាជិកាក្រុមប្រឹក្សា)

ឯកឧត្តម ឆែ័ត ចន្ថាវី
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម នុត ជា
(សមាជិកក្រុមប្រឹក្សា)

លោកជំទាវ ឃុន គីមនី
(សមាជិកាក្រុមប្រឹក្សា)

ឯកឧត្តម ប៊ី ប្រេម
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ម៉ម ឃុច
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ណាក គាណាឌុច
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ម៉ក់ ថាយ
(សមាជិកក្រុមប្រឹក្សា)

លោកជំទាវ ជា សុគន្ធ
(សមាជិកាក្រុមប្រឹក្សា)

លោកជំទាវ កែវ តែតារា
(សមាជិកាក្រុមប្រឹក្សា)

លោកជំទាវ ចាន់ នីឡា
(សមាជិកាក្រុមប្រឹក្សា)

លោកជំទាវ ម៉ម សុធី
(សមាជិកាក្រុមប្រឹក្សា)

ឯកឧត្តម សេង គួនណូ
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម សេង រតនៈ
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ចុយ សុខន
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម អ៊ិង ស៊ីថាន
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម តួច ម៉ាល័យ
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ខឿក សាមាន
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម គីម សាឌុច
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ឃ្មី សុភាព
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ឡូន សុគៈ
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ស្រ៊ី គីមយូ
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម កែ ប៊ុនឃៀង
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម ថន ជាវី
(សមាជិកក្រុមប្រឹក្សា)

ឯកឧត្តម សរ សុខ
(សមាជិកក្រុមប្រឹក្សា)

អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

ឯកឧត្តម ឃួង ស្រេង

អតិប្បាល រាជធានីភ្នំពេញ

ឯកឧត្តម ស៊ុយ សេរិទ្ធ

អតិប្បាលរង រាជធានីភ្នំពេញ

ឯកឧត្តម កើត ឆែ

អតិប្បាលរង រាជធានីភ្នំពេញ

លោកជំទាវ កែវ សុខពិសី

អតិប្បាលរង រាជធានីភ្នំពេញ

ឯកឧត្តម អាន ចាន់យ៉ាដា

អតិប្បាលរង រាជធានីភ្នំពេញ

ឯកឧត្តម ឆួន ផារ័ត្ន

អតិប្បាលរង រាជធានីភ្នំពេញ

ឯកឧត្តម ហួត ហៃ

អតិប្បាលរង រាជធានីភ្នំពេញ

គណៈនាយករដ្ឋបាល
សាលារាជធានីភ្នំពេញ

លោក សេង វណ្ណៈ
នាយករដ្ឋបាល

លោក ហុក ហួលីម
នាយករងរដ្ឋបាល

លោក ជូ ម៉ៅចាន់
នាយករងរដ្ឋបាល

លោក កែ ពន្លក
នាយករងរដ្ឋបាល

លោកស្រី សក់ ចិន្តារី
នាយិការងរដ្ឋបាល

លោកស្រី តិអា ឥច្ឆិកាល
នាយិការងរដ្ឋបាល

លោក ឃុង សុខុម
នាយករងរដ្ឋបាល

លោក ជិន ប៊ុនធឿន
នាយករងរដ្ឋបាល

ទីចាត់ការ អង្គភាព និង ការិយាល័យប្រជាពលរដ្ឋ នៃសាលារាជធានីភ្នំពេញ

លោកស្រី ជោ សម្ផស្ស
នាយិកាទីចាត់ការរដ្ឋបាល

លោក ឃុន ឥណ្ណា
នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស

លោក អ៊ុក សុផល
នាយកទីចាត់ការហិរញ្ញវត្ថុ

លោក ប៊ុត សារ៉ែត
ប្រធានអង្គភាពលទ្ធកម្ម

លោកស្រី ច័ន្ទ សុគន្ធា
នាយិកាទីចាត់ការអន្តរវិស័យ

លោក ម៉ែត មាសភក្តី
នាយកទីចាត់ការផែនការ និងវិនិយោគ

លោក កាំង លាងគ្រី
នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស

លោក សុិន ឫណ្ឌ៉ាមី
នាយកទីចាត់ការរៀបចំក្រុង

លោក ឆួន សំណាងឆុង
នាយកទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន

លោកស្រី ជាន សុភ័ក្រនីតា
នាយិកាទីចាត់ការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ

លោកស្រី ងួក ឃុវឈ័ក្ខ
ប្រធានអង្គភាពច្រកចេញ-ចូលតែមួយ

លោក ជាម ហេង
ប្រធានការិយាល័យប្រជាពលរដ្ឋ

``

ឧបសម្ព័ន្ធទី៣

រូបភាពសកម្មភាពការងារ និងសមិទ្ធផលរបស់សាលារាជធានីភ្នំពេញ

សកម្មភាពចុះត្រួតពិនិត្យដើមឈើចាស់ៗនៅសួនកាណាឌីយ៉ា និងសកម្មភាពចុះចែកម៉ាស់ជូនបងប្អូនប្រជាពលរដ្ឋតាមបណ្តាខណ្ឌនានា

សកម្មភាពចុះត្រួតពិនិត្យកន្លែងធ្វើតេស្តនៅពហុកីឡាដ្ឋាន និងសកម្មភាពចុះចែកម៉ាស់ជូនបងប្អូនប្រជាពលរដ្ឋតាមបណ្តាខណ្ឌនានា

សកម្មសកម្មភាពចុះចែកអំណោយគ្រោះទឹកជំនន់ជូនបងប្អូនប្រជាពលរដ្ឋក្នុងខណ្ឌដង្កោ និងសកម្មភាពចុះត្រួតពិនិត្យប្រលាយបង្ហូរទឹកក្នុងខណ្ឌដង្កោ

``

គណៈអភិបាលរាជធានីភ្នំពេញបានប្រគល់ ឧបករណ៍ត្រួតពិនិត្យគោលដៅចរាចរណ៍ជូនដល់ស្នងការនគរបាលរាជធានីភ្នំពេញ

សកម្មសកម្មភាពការងារផ្សេងៗ

``

ស្ពានអាកាស និងស្ពានក្រោមដីចោមចៅថ្មី




ស្ពានថ្មើរជើងផ្សារដើមគរថ្មី



``

ទីក្រុងភ្នំពេញ | © 2021, CHHOY THEARA

``

រូបភាពពេលរាត្រីនៅរាជធានីភ្នំពេញ

``

Secondary Road
Main Road
Local Road


A
B
A
B
D
D
C
C

``

ឧបសម្ព័ន្ធទី៤

ការប្រៀបធៀបរូបភាពចុះស្រាវជ្រាវឯកសារ

កម្រងរូបភាពជាមួយ **លោក ឃុន វណ្ណា** នាយកទីចាត់ការ គ្រប់គ្រងធនធានមនុស្សនៃសាលារាជធានីភ្នំពេញ ក្នុងពេលចុះកម្មសិក្សាស្រាវស្រាវឯកសារ

កម្រងរូបភាពជាមួយ **លោកស្រី ឈុន ប៉ាវី** ប្រធានការិយាល័យ គ្រប់គ្រងធនធានមនុស្សនៃសាលារាជធានីភ្នំពេញក្នុងពេលចុះកម្មសិក្សាស្រាវស្រាវឯកសារ

``

កម្រងរូបភាពជាមួយ **លោក ភឹម សុការិន** មន្ត្រី ការិយាល័យ ផ្សព្វផ្សាយពាណិជ្ជកម្មនៃសាលារាជធានីភ្នំពេញ ក្នុងពេលចុះកម្មសិក្សាស្រាវស្រាវឯកសារ



``

កម្រងរូបភាពជាមួយ **លោកស្រី គង់ រ៉ូចគីម** មន្ត្រីទទួល និងប្រគល់ឯកសារ អង្គភាពច្រកចេញចូលតែមួយនៃសាលារាជធានីភ្នំពេញក្នុងពេលចុះកម្មសិក្សាស្រាវស្រាវឯកសារ

``

កម្រងរូបភាពជាមួយសាស្ត្រាចារ្យណែនាំ **បណ្ឌិត ឈុន ណារ៉ត** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទ
នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

``

កម្រងរូបភាពជាមួយសាស្ត្រាចារ្យណែនាំ **បណ្ឌិត ឈុន ណារ៉ែត** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទ
នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

``